# សង្កេតការណ៍

២៨

## ជំនឿរកាត់ទោសមេដឹកនាំខ្មែរក្រហម



កងចល័តបុរសនារី កំពុងលើកទំនប់៧មករា ក្បែរស្ទឹងជីនិត ខេត្តកំពង់ធំ

មជ្ឈមណ្ឌលឯកសារកម្ពុជា ◆ ស្វែងរកការពិតដើម្បីការចងចាំនិងយុត្តិធម៌ ◆ www.dccam.org

ខែកញ្ញា ឆ្នាំ២០១៣

# មាតិកា

ខែកញ្ញា ឆ្នាំ២០១៣



សវនាការស្តាប់សក្ខីកម្ម

០១ សាក្សី ស៊ីវ ហេងឌំរ

២៤ អ្វីទៅជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ?

៣១ សិទ្ធិពិនិត្យមើលសំណុំរឿងក្តីព្រហ្មទណ្ឌ

ក្រុមសង្កេតការណ៍ ៖
លឹម ជ័យទត្ត និង ចាន ប្រាថ្នា

ពិនិត្យ និងផ្ទៀងផ្ទាត់ ដោយ វ៉ាន់ថាន់ ពៅដារ៉ា

ប្រជាជនកំពង់ផលដំណាំក្នុងរបបខ្មែរក្រហម ដើម្បីបញ្ជូនទៅតាមសហករណ៍ (រូបថតមជ្ឈមណ្ឌលឯកសារកម្ពុជា)

# សវនាការស្ដាប់សក្ខីកម្មសាក្សី ស៊ីវ ហេដឌ័រ

## ថ្ងៃទី០៩-១៨ ខែកក្កដា ឆ្នាំ២០១៣

ចាន ប្រាថ្នា

មុននឹងចូលដល់ការស្ដាប់សក្ខីកម្មរបស់សាក្សី ស៊ីវ ហេដឌ័រ ប្រធានអង្គជំនុំជម្រះ លោកចៅក្រម និល ណុន បានតម្រូវឲ្យសាក្សីរូបនេះធ្វើសម្បថនៅចំពោះមុខអង្គជំនុំជម្រះ និងភាគីផ្សេងៗទៀតនៅក្នុងសវនាការ ។ ស៊ីវ ហេដឌ័រ បានធ្វើសម្បថតាមបែបគ្រីស្ដសាសនា ដោយលើកដៃឡើងលើ និងស្បថថា "ខ្ញុំសូមប្រកាសជាឱឡារិក គឺថាខ្ញុំប្រាប់ការពិតទាំងស្រុង គឺខ្ញុំនិយាយតែការពិតទាំងស្រុង គ្មានអ្វីក្រៅពីការពិតនោះឡើយ" ។ បន្ទាប់ពីធ្វើសម្បថរួច លោកចៅក្រម និល ណុន បានប្រាប់អំពីសិទ្ធិ និងករណីកិច្ចរបស់ ស៊ីវ ហេដឌ័រ ដែលត្រូវអនុវត្តក្នុងអំឡុងពេលកិច្ចដំណើរនីតិវិធីសួរដេញដោលរបស់ភាគី ។ ប្រធានអង្គជំនុំជម្រះបានបញ្ជាក់ថា ក្នុងនាមជាសាក្សីម្នាក់ ស៊ីវ ហេដឌ័រ មានសិទ្ធិបដិសេធក្នុងការឆ្លើយតបសំណួរ ឬស្នើសុំឲ្យធ្វើអត្ថាធិប្បាយទាំងឡាយណា ដែលនាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនឯង ។ សិទ្ធិនេះហៅថា "សិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង" ។ ទាក់ទងនឹងករណីកិច្ច ប្រធានអង្គជំនុំជម្រះបានសង្កត់ធ្ងន់ ដោយកំណត់ឲ្យ ស៊ីវ ហេដឌ័រ ត្រូវតែឆ្លើយតបគ្រប់សំណួរទាំងអស់ដែលភាគី ឬចៅក្រមនៃអង្គជំនុំជម្រះបានចោទសួរ លើកលែងតែប្រភេទសំណួរទាំងឡាយណាដែលចម្លើយតបទៅនឹងសំណួរនោះ នាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនឯងប៉ុណ្ណោះ ។ បន្ថែមលើនេះ ស៊ីវ ហេដឌ័រ ត្រូវតែឆ្លើយនូវការណ៍ណាដែលពិត ដែលគាត់បានឃើញ បានដឹង បានឮ ធ្លាប់មានបទពិសោធន៍ឆ្លងកាត់ ឬបានធ្វើការសង្កេតដោយផ្ទាល់នូវព្រឹត្តិការណ៍ណាមួយដែលបានកើតឡើង ពោលគាត់ពុំអាចឆ្លើយដោយធ្វើការប៉ាន់ស្មានឡើយ ។

### ១) ប្រវត្តិសាវតាររបស់ ស៊ីវ ហេដឌ័រ

លោក ស៊ីវ ហេដឌ័រ អាយុ ៦០ឆ្នាំ ជនជាតិអាមេរិកកាំង ជាអ្នកប្រវត្តិសាស្ត្រ និងវិទ្យាសាស្ត្រនយោបាយ ។ ឪពុកឈ្មោះ រ៉ូប៊ឺត ហេដឌ័រ ម្ដាយឈ្មោះ ប្រូទ្រីស៊័រ ម៉ោវើ ប្រពន្ធឈ្មោះ ម៉ារីអែល រីល័រប៊ើក មានកូនចំនួន២នាក់ ។ ស៊ីវ ហេដឌ័រ គឺជាសាស្ត្រាចារ្យផ្នែកវិទ្យាសាស្ត្រ និងនយោបាយ នៅសកលវិទ្យាល័យបូព៌ាប្រទេស និងអាហ្វ្រិក ។ សាក្សីក៏ធ្លាប់ធ្វើជាអ្នកឆ្លើយឆ្លងសារព័ត៌មាននៅប្រទេសចិន តៃវ៉ាន់ ថៃ វៀតណាម កម្ពុជា និងឡាវ សម្រាប់ទស្សនាវដ្ដីថាមស៍ ទស្សនាវដ្ដីញូវស៊ីក និងវិទ្យុ អ៊ិន.ប៊ី.ស៊ី នៅចន្លោះឆ្នាំ១៩៧៣-១៩៧៥ ។ អំឡុងឆ្នាំ១៩៩២-១៩៩៣ ស៊ីវ ហេដឌ័រ ធ្វើការជាមួយអាជ្ញាធរបណ្ដោះអាសន្ននៃអង្គការសហប្រជាជាតិប្រចាំនៅកម្ពុជា (អ៊ុនតាក់) ទទួលបន្ទុកផ្នែកវិភាគ និងវាយតម្លៃព័ត៌មាន និងអប់រំ ។ ស៊ីវ ហេដឌ័រ បានចូលបម្រើ



ស៊ីវ ហេ (រូបថតមជ្ឈមណ្ឌលឯកសារកម្ពុជា)

ការងារនៅការិយាល័យសហព្រះរាជអាជ្ញក្នុងឆ្នាំ២០០៦ និងបន្តធ្វើឲ្យការិយាល័យសហចៅក្រមស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បន្ទាប់ពីសហព្រះរាជអាជ្ញាចេញដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរក្នុងអំឡុងខែសីហា ឆ្នាំ២០០៧ ។

ទាក់ទងទៅនឹងវិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវ និងការធ្វើបទសម្ភាសន៍ ស៊ីវ ហេដឌ័រ បញ្ជាក់ថាកិច្ចការនេះត្រូវធ្វើជាក្រុមមានវិន័យ និងរៀបចំអង្គការលេខឲ្យបានត្រឹមត្រូវ ពោលគឺពុំត្រូវ

មានការបំពានពីប្រធានផ្នែកណាមួយឡើយ ។ ស៊ីវ ហេដឺរ អះអាងនៅចំពោះមុខអង្គជំនុំជម្រះថា មានភាពស្ទាត់ជំនាញក្នុងការនិយាយភាសាខ្មែរ ហើយអាចសម្ភាសន៍ជាមួយប្រជាជនកម្ពុជាដោយប្រើភាសាខ្មែរដែលសូរស័ព្ទសំឡេងដូចម្ចាស់ភាសា ។ ក្រៅពីភាសាខ្មែរ គាត់អាចនិយាយភាសា ចិន ថៃ វៀតណាម និងបារាំង ។

នៅដើមឆ្នាំ១៩៧៩ ស៊ីវ ហេដឺរ បានសម្ភាសន៍ជនភៀសខ្លួន និងមេដឹកនាំខ្មែរក្រហមជាច្រើន នៅតាមព្រំដែនក្នុងទឹកដីនៃប្រទេសថៃ។

## ២) ការសួរដេញដោលសាក្សីដោយតំណាងសហព្រះរាជអាជ្ញា

ក្នុងការសួរដេញដោលសាក្សី ស៊ីវ ហេដឺរ តំណាងសហព្រះរាជអាជ្ញា ឃីត វ៉េន័រ បានផ្តោត សំខាន់ទៅលើសៀវភៅដែលមានចំណងជើងថា "បុគ្គលប្រាំពីររូបដែលត្រូវចោទប្រកាន់" ដែលសាក្សីរូបនេះជាអ្នកនិពន្ធផ្ទាល់ ។ ក្នុងការសួរដេញដោលលោក ឃីត វ៉េន័រ បានដកស្រង់ខ្លឹមសារនៅក្នុងសៀវភៅនេះមកសួរបញ្ជាក់ ព្រមទាំងសួររកប្រភពឯកសារយោងដែលសាក្សីបានប្រើប្រាស់ក្នុងការសរសេរសៀវភៅនេះ ។ ក្រៅពីសៀវភៅនេះ តំណាងសហព្រះរាជអាជ្ញាសួរពាក់ព័ន្ធនឹងឯកសារកិច្ចសម្ភាសន៍មួយចំនួនដែល ស៊ីវ ហេដឺរ បានធ្វើជាមួយជនភៀសខ្លួន និងមេដឹកនាំខ្មែរក្រហមនៅតាមព្រំដែនខ្មែរ-ថៃ និងជាមួយកម្មាភិបាលខ្មែរក្រហមជាច្រើនទៀត ក្នុងអំឡុងពេលបម្រើការងារនៅក្នុងការិយាល័យសហព្រះរាជអាជ្ញា និងការិយាល័យសហចៅក្រមស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

ចាប់ផ្តើមដំបូងលោក ឃីត វ៉េន័រ ដាក់បង្ហាញឯកសារមួយដែលមានចំណងជើងថា "*ការវាយតម្លៃឡើងវិញអំពីតួនាទីមេដឹកនាំជាន់ខ្ពស់ និងមន្ត្រីកម្ពុជាប្រជាធិបតេយ្យ និងបទឧក្រិដ្ឋ ការទទួលខុសត្រូវរបស់កម្ពុជា និងទស្សនៈវិស័យប្រៀបធៀប*" ដើម្បីសួរដេញដោលសាក្សីទាក់ទងនឹងកិច្ចសម្ភាសន៍មួយចំនួន ។

### ក) អំពីកិច្ចសម្ភាសន៍ជាមួយ ខៀវ សំផន និង អៀង សារី

ស៊ីវ ហេដឺរ បញ្ជាក់ថា គាត់បានសម្ភាស ខៀវ សំផន ក្នុងអំឡុងខែសីហា ឆ្នាំ១៩៨០ ដោយមានការថតជាខ្សែអាត់សំឡេង ។ នៅខែធ្នូ ឆ្នាំ១៩៩៦ ស៊ីវ ហេដឺរ ធ្វើការសម្ភាសន៍ជាមួយ អៀង សារី អមដំណើរដោយ អ៊ី ឈាន (ជាសមមិត្តលេខ៣) នៅចាន់បូរី ក្នុងប្រទេសថៃ។ កិច្ចសម្ភាសន៍នេះត្រូវបានថតជាខ្សែអាត់សំឡេង ។ ក្នុងខែមករា ឆ្នាំ១៩៩៩ ស៊ីវ ហេដឺរ បានសម្ភាស អៀង សារី ម្តងទៀតនៅសណ្ឋាគារឡឺរ៉ូយ៉ាល់ ភ្នំពេញ ។

បន្ទាប់ពីសួរនាំពាក់ព័ន្ធនឹងការកំណត់អត្តសញ្ញាណឯកសារបទសម្ភាសន៍មួយចំនួនរួច លោក ឃីត វ៉េន័រ ចាប់ផ្តើមលើកយកឯកសារមួយចំនួនដែល ស៊ីវ ហេដឺរ បាននិពន្ធមកសួរបញ្ជាក់ ។ វិធីសាស្ត្រក្នុងសួរដេញដោលទៅលើឯកសារទាំងនោះ លោក ឃីត វ៉េន័រ ធ្វើការដកស្រង់ខ្លឹមសារសំខាន់មកសួរ ដើម្បីឲ្យ ស៊ីវ ហេដឺរ ធ្វើការពន្យល់ និងបញ្ជាក់អំពីប្រភពដើមនៃឯកសារដែលយកមកធ្វើជាមូលដ្ឋានក្នុងការសរសេរសៀវភៅទាំងនោះ ។

ឯកសារទី១ ដែល ឃីត វ៉េន័រ យកមកសួរដេញដោលមានចំណងជើងថា "កុម្មុយនីស្តកម្ពុជា និងគំរូវៀតណាម" ។ នៅក្នុងឯកសារនេះ តំណាងសហព្រះរាជអាជ្ញដកស្រង់សន្ទរកថារបស់ ស៊ីវ ហេង ដែលបានថ្លែងថា "...មធ្យោបាយសម្រាប់កម្ពុជារស់នៅដោយមានសេរីភាពនោះ គឺត្រូវសម្លាប់ពួកឈ្លានពានចក្រពត្តិឈ្លានពានទាំងអស់..." ។ ស៊ីវ ហេដឺរ បញ្ជាក់ថា សុន្ទរកថានេះត្រូវបានចុះផ្សាយនៅក្នុងសារព័ត៌មានថ្មីៗរបស់វៀតណាម (វី.អ៊ិន.អេស) ហើយអាចរកបាននៅសាកលវិទ្យាល័យខូណែល ។ នៅក្នុងឯកសារនេះដែរបានបញ្ជក់ថា "*នៅពេលដូចគ្នានេះ កម្ពុជាត្រូវតែអនុវត្តការសម្លាប់ពួកក្បត់នៅក្នុងភូមិភាគដែលរំដោះបាន និងដោះស្រាយជាមួយនឹងភ្នាក់ងារសម្ងាត់ជាច្រើនដែលជ្រៀតចូលមកក្នុងចលនាដើម្បីព្យាយាមបង្កវិទ្ធង្សនាដល់បដិវត្តន៍ និងបំផ្លាញអង្គការបដិវត្តន៍*" ។ ស៊ីវ ហេដឺរ បញ្ជាក់ថា ខ្លឹមសារនេះគាត់បានយោងទៅលើវិត្តប័ណ្ណរបស់គណៈកម្មាធិការសន្តិភាពខ្មែរដែលត្រូវបានចុះផ្សាយដោយសារព័ត៌មានវៀតណាម ហើយអាចរកបាននៅក្នុងបណ្ណាល័យរបស់សាកលវិទ្យាល័យខូណែល ។

នៅក្នុងជំពូកទី៣នៃសៀវភៅនេះបានបញ្ជាក់ថា "*នៅក្នុងខែមករា ឆ្នាំ១៩៦០ ថ្នាក់ដឹកនាំបក្សឲ្យមានការបោះបោរជាយុទ្ធសាស្ត្រ ដើម្បីឈានទៅដល់សកម្មភាពយោធា ព្រោះត្រូវតែយក*

ការតស៊ូ នយោបាយរួមជាមួយនិងការតស៊ូអាវុធ ។ បើមិនដូច្នេះគឺថាមិនខ្លាំងគ្រប់គ្រាន់ដើម្បីគ្រប់គ្រងមូលដ្ឋានបដិវត្តន៍ ។ ការតស៊ូនយោបាយ និងប្រដាប់អាវុធ ត្រូវតែរួមបញ្ចូលគ្នាទាំងពីរ ហើយដើរតួយ៉ាងសំខាន់ នៅក្នុងចលនាបដិវត្តន៍” ។ ស៊ីវ ហេដឌ័រ បញ្ជាក់ថាព័ត៌មាននេះគាត់ទទួលបានពីបុគ្គលម្នាក់ដែលធ្លាប់បម្រើការងារជាភ្នាក់ងារសម្ងាត់ផ្នែកយោធា ។

នៅក្នុងជំពូកទី៤នៃសៀវភៅនេះបានលើកឡើងអំពីសមាជបក្សដែលត្រូវបានធ្វើជាសម្ងាត់នៅភ្នំពេញនៅថ្ងៃទី២៨-៣០ ខែកញ្ញា ឆ្នាំ១៩៦០ ។ នៅក្នុងសមាជនេះ ឯកសារចំនួនបី ដែលក្នុងនោះរួមមាន មាគ៌ាយុទ្ធសាស្ត្រ និងយុទ្ធវិធី ត្រូវបាន ប៉ុល ពត



ឃីត វ៉ែន័រ (រូបថតមជ្ឈមណ្ឌលឯកសារកម្ពុជា)

លើកឡើងនៅក្នុងកិច្ចប្រជុំនោះ ហើយទទួលបានការគាំទ្រ ដោយ នួន ជា ។ ក្រៅពីនេះ សមាជបក្សឆ្នាំ១៩៦០ បានសម្រេចបង្កើតគណៈមជ្ឈិមបក្សដែលមានសមាជិក៨រូប រួមមាន ទូ សាមុត ជាលេខាបក្ស, នួន ជា និង ប៉ុល ពត ជាអនុលេខា, អៀង សារី, កែវ មាស, សោ ភឹម មកពីបូព៌ា និងកម្មាភិបាលពីររូបទៀតមកពីមូលដ្ឋាន ។ ស៊ីវ ហេដឌ័រ បញ្ជាក់បន្ថែមថា កែវ មាស ជាអតីតអ្នកកុម្មុយនីស្តក្នុងអំឡុងទសវត្សរ៍ឆ្នាំ៤០-៥០ ។ គាត់ត្រូវបានបក្សសម្រេចឃាត់ខ្លួនឲ្យនៅក្នុងផ្ទះក្នុងអំឡុងឆ្នាំ១៩៧៥ បន្ទាប់មកត្រូវបានបញ្ជូនទៅមន្ទីរសន្តិសុខស-២១ ដើម្បីសួរយកចម្លើយ និងសម្លាប់ចោល ។

បន្ទាប់ពីបញ្ចប់ការសួរដេញដោលទៅលើសៀវភៅនេះ តំណាងសហព្រះរាជអាជ្ញា ឃីត វ៉ែន័រ បន្តដាក់ឯកសារមួយថ្មីទៀត ដែលនិយាយអំពីសង្គ្រាមប្រជាជនបដិវត្តន៍ចន្លោះឆ្នាំ១៩៧០-១៩៧៥ ។ ឯកសារនោះបានបញ្ជាក់ថា ក្នុងរយៈពេល១ខែបន្ទាប់ពីមានរដ្ឋប្រហារទម្លាក់សម្តេច នរោត្តម សីហនុ បក្សពលករវៀតណាមបានកាន់កាប់ទឹកដី ៦០គីឡូម៉ែត្រចូលមកក្នុងទឹកដីប្រទេសកម្ពុជា ហើយបង្កើតបានជាតំបន់រំដោះដែលមានប្រជាជនប្រមាណ១លាននាក់ ។ ខ្លឹមសារទាំងនេះ ស៊ីវ ហេដឌ័រ ដកស្រង់ (យោង) ចេញពីឯកសារមួយដែលមានចំណងជើងថា “វិទ្ធង្សនាកុម្មុយនីស្តវៀតណាមនៅកម្ពុជា” ។ ស៊ីវ ហេដឌ័រ ទទួលបានឯកសារនេះពីស្ថានទូតអាមេរិកប្រចាំនៅសៃហ្គន ប្រទេសវៀតណាម ក្នុងអំឡុងឆ្នាំ១៩៧០ ឬ១៩៧១ ។ នៅក្នុងឯកសារសង្គ្រាមប្រជាជនដដែលនេះបានបញ្ជាក់ថា នៅក្នុងខែសីហា ឆ្នាំ១៩៧០ រណសិរ្សរួបរួមជាតិកម្ពុជាប្រកាសថា ខ្លួនបានបង្ក្រាបទាហាន លន់ នល់ ប្រមាណ ៨ម៉ឺននាក់ ហើយកងកម្លាំងសៃហ្គនរំដោះបានខេត្តចំនួន៥ ។ ប្រភពព័ត៌មាននេះបានមកពីទីភ្នាក់ងារសារព័ត៌មានផ្លូវការរបស់ចិន ។

លោក ឃីត វ៉ែន័រ ដាក់បង្ហាញឯកសារមួយទៀតនិយាយអំពីការជួយជ្រោមជ្រែងរបស់វៀតណាមចំពោះចលនាបដិវត្តន៍ខ្មែរក្រហម ។ ឯកសារនោះបាននិយាយថា ជ័យជម្នះរបស់បក្សកុម្មុយនីស្តបានកើតឡើងដោយសារមានការជួយជ្រោមជ្រែងរបស់វៀតណាមនៅចន្លោះឆ្នាំ១៩៧០-១៩៧២ ។ កិច្ចអន្តរាគមន៍ផ្នែកកងកម្លាំងយោធា នយោបាយ និងការបណ្តុះបណ្តាលរបស់វៀតណាមក្នុងអំឡុងពេលនោះ បានធ្វើឲ្យបក្សកុម្មុយនីស្តកម្ពុជាមានលទ្ធភាពបង្កើតកម្លាំងយោធារបស់ខ្លួន ។ ស៊ីវ ហេដឌ័រ បញ្ជាក់ថា ព័ត៌មានទាំងនេះមានប្រភពមកពីឯកសារសិក្សាស្រាវជ្រាវមួយដែលបោះពុម្ពផ្សាយដោយរដ្ឋាភិបាលសហរដ្ឋអាមេរិក ។

ឯកសារដែលតំណាងសហព្រះរាជអាជ្ញាដាក់បង្ហាញដដែលនេះបានបញ្ជាក់ថា បន្ទាប់ពីបក្សកុម្មុយនីស្តកម្ពុជាបណ្តេញកងទ័ព

វៀតណាមចេញពីតំបន់រំដោះនៅចន្លោះឆ្នាំ១៩៧២-១៩៧៣ បក្សកុម្មុយនីស្តកម្ពុជាកាន់តែមានភាពហិង្សាខ្លាំងឡើងនៅពាក់កណ្តាលឆ្នាំ១៩៧៣ ។ ប្រជាជនដែលរស់នៅក្នុងតំបន់រំដោះ ត្រូវបានកាត់បន្ថយសិទ្ធិសេរីភាពក្នុងការគោរពសាសនា និងការធ្វើដំណើរពីភូមិភូមិទៅភូមិមួយទៀត ។

បន្ទាប់ពីបញ្ចប់ការសួរដេញដោលឯកសារទាំងអស់ខាងលើ លោក យឹត វ៉េន័រ ដាក់បង្ហាញសំណុំឯកសារថ្មីមួយទៀតដើម្បីឲ្យ ស៊ីវ ហេងឌ័រ បញ្ជាក់ ។ នៅក្នុងសំណុំឯកសារនេះ មានឯកសារចំនួន៤ ។ ឯកសារទី១ ជាបទសម្ភាសន៍ដែល ស៊ីវ ហេងឌ័រ បានធ្វើជាមួយបុគ្គលម្នាក់ (មិនបញ្ចេញឈ្មោះ) ដែលជាលេខាតំបន់២២ ក្នុងភូមិភាគបូព៌ា អំពីស្ថានការណ៍នៅភូមិភាគបូព៌ា ។ បុគ្គលនោះបានបញ្ជាក់ថា "ចាប់ផ្តើមពីឆ្នាំ៧៣មក ខ្ញុំចាប់ផ្តើមមានភាពសង្ស័យ ដោយសារតែឃើញសកម្មភាពវានៅឆ្នាំ៧៣ និង ៧៤ ។ វាបោសសម្អាតកម្មាភិបាលផ្ទៃក្នុង និងចាប់កម្មាភិបាលធម្មតា ហើយចោទថាពួកនោះពុករលួយ ពាលាអាវ៉ាសែ ។ ក្នុងពេលនោះ គេចោទដំតែបញ្ហាពីរទេ គឺទី១ សីលធម៌រស់នៅជាមួយស្រីញី និងទី២ គេចាត់ទុកខ្មាំងបង្កប់ស៊ីរ៉ូងផ្ទៃក្នុង" ។ បុគ្គលនោះបានបញ្ជាក់ទៀតថា នៅក្នុងអំឡុងឆ្នាំ១៩៧៣ មានព្រឹត្តិការណ៍សំខាន់ៗចំនួនពីរ គឺការបណ្តេញកងទ័ពវៀតណាមចេញពីប្រទេសកម្ពុជា និងការចាប់ខ្លួនកម្មាភិបាលខ្មែរក្រហមដែលទទួលការបណ្តុះបណ្តាលនៅវៀតណាមជាបណ្តើរៗ ។

ឯកសារទី២ ជាប្រភេទបទសម្ភាសន៍ដែល ស៊ីវ ហេងឌ័រ បានធ្វើជាមួយប្រជាជនខ្មែរដែល ភៀសខ្លួនទៅព្រំដែនខ្មែរ-ថៃ ក្នុងអំឡុងខែកុម្ភៈ ឆ្នាំ១៩៨០ ។ តាមរយៈបទសម្ភាសន៍ទាំងនោះ បានបញ្ជាក់ថា នៅក្នុងឆ្នាំ១៩៧៣ មានការចរចាជាច្រើនដងរវាងមេបញ្ជាការវៀតណាម និងមេបញ្ជាការ ខ្មែរ[ក្រហម] ។ លទ្ធផលនៃការចរចានោះភាគីទាំងពីរបានយល់ព្រមជាគោលការណ៍ថា កងទ័ពវៀតណាម នឹងដកខ្លួនចេញពីកម្ពុជា ប៉ុន្តែអង្គភាពមួយចំនួនរបស់វៀតណាមនឹងមិនដកចេញឡើយ ។ ទោះបីជាយ៉ាងនេះក្តី មានការបង្ហូរឈាមគ្នាយ៉ាងច្រើននៅក្នុងឆ្នាំ១៩៧៣ មុននឹងកងទ័ពវៀតណាមសម្រេចដកខ្លួនចេញពីកម្ពុជា ។ ក្នុងអំឡុងពេលនោះដែរ មានការបណ្តេញជនជាតិវៀតណាមមួយចំនួនឲ្យត្រឡប់ទៅស្រុកកំណើតវិញ ហើយមាគ៌ាបក្សកុម្មុយនីស្តកម្ពុជាបានកំណត់ថា "នរណាម្នាក់ដែលស្រឡាញ់កម្ពុជា អាចរស់នៅបន្តទៀតបាន ។ ប៉ុន្តែប្រសិនបើនៅពេលអនាគតមានវិវាទកាន់តែរីកធំឡើង ប្រជាជនវៀតណាមមិន អាចទទួលយករបបនៅកម្ពុជាបានទេ ពួកគេនឹងមិនត្រូវបានទុកឲ្យនៅទៀតឡើយ" ។

ឯកសារមួយផ្សេងទៀតដែលតំណាងសហព្រះរាជអាជ្ញា យឹត វ៉េន័រ បានដាក់បង្ហាញ គឺជាបទសម្ភាសន៍ ដែល ស៊ីវ ហេងឌ័រ បានធ្វើជាមួយបុគ្គលម្នាក់ (មិនបញ្ចេញឈ្មោះ) មានឋានៈជាលេខាតំបន់២១ ទទួលបន្ទុកខាងសេដ្ឋកិច្ច និងអប់រំ ។ បុគ្គលដែល



ផ្តល់បទសម្ភាសន៍នោះបានបញ្ជាក់ថា ប៉ុល ពត បានកែនយោបាយមួយចំនួនគួរឲ្យកត់សម្គាល់ ។ វណ្ណៈផ្សេងៗក្រៅពីវណ្ណៈកម្មករ និងកសិករ ត្រូវបានបំភ្លេចចោល ។ ឈ្មួញសឹក លន់ នល់ ដែលបានចុះចូលត្រូវបានលុបបំបាត់ចោល ។ ជំនឿអរូបិយ និងការប្រតិបត្តិសាសនា ត្រូវបានហាមឃាត់ ។

### ១) ការជម្លៀសប្រជាជន

ទាក់ទងនឹងការជម្លៀសប្រជាជនចេញពីក្រុងខេត្ត ស៊ីវ

ហេដឌ័រ បញ្ជាក់ថា គាត់ទៅដល់ទីនោះក្នុង ខែមីនា ឆ្នាំ១៩៧៤ ពេលគឺបន្ទាប់ពីមានការវាយប្រហាររវាងទាហាន លន់ នល់ និងយោធាខ្មែរក្រហមភ្លាមៗ ។ បន្ទាប់ពីវាយបានខដុគ្គ យោធាខ្មែរក្រហមបានជម្លៀសប្រជាជនស្ទើរតែទាំងអស់ចេញពីទីនោះ ។ លើកលែងតែប្រជាជនដែលនៅសម្ងំលាក់ខ្លួនប៉ុណ្ណោះ ដែលរួចផុតពីការជម្លៀសនេះ ។ នៅទីនោះ ស៊ីវ ហេដឌ័រ បានឃើញសាកសពដូនជីប្រមាណ ៦-៧ នាក់ ត្រូវបានយោធាខ្មែរក្រហមសម្លាប់នៅនឹងកន្លែង ។ ក្រៅពីនេះក៏មានការសម្លាប់ ទាហាន និងមន្រ្តីរដ្ឋការរបស់សាធារណរដ្ឋខ្មែរដែរ ។ ចំពោះស្ថានភាពនៅក្នុង



ស៊ីវ ហេដឌ័រ (រូបថតមជ្ឈមណ្ឌលឯកសារកម្ពុជា)

ទីក្រុងវិញ គឺមានភាពស្ងាត់ជ្រងំ ហើយផ្ទះសម្បែងជាច្រើនត្រូវបានបំផ្លាញ និងបិទទ្វារ ។

ទាក់ទងនឹងការជម្លៀសប្រជាជននៅខេត្តកំពង់ចាម ស៊ីវ ហេដឌ័រ បញ្ជាក់ថា បានសម្ភាស ប្រជាជនមួយចំនួននៅទីរួមខេត្តកំពង់ចាម ។ ប្រជាជននៅទីនោះបានបញ្ជាក់ថា ប្រជាជនមួយចំនួនធំនៅក្នុងខេត្តនេះ ត្រូវបានខ្មែរក្រហមជម្លៀសចេញ ។ ប្រជាជនមួយចំនួនទៀតត្រូវបានខ្មែរក្រហមសម្លាប់នៅនឹងកន្លែង ។ ប្រជាជនទាំងនោះភាគីច្រើនជាទាហាន និងមន្រ្តីរដ្ឋការរបស់របបសាធារណរដ្ឋខ្មែរ ។ ស៊ីវ ហេដឌ័រ ពុំបានចារកាលបរិច្ឆេទច្បាស់លាស់អំពីការជម្លៀសនេះឡើយ ប៉ុន្តែគាត់បានផ្តល់ការប៉ាន់ស្មានថា គឺក្នុងអំឡុងឆ្នាំ១៩៧៣ ។

ទាក់ទងនឹងផែនការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ តំណាងសហព្រះរាជអាជ្ញា ឃីត វ៉ែន័រ លើកយកឯកសារបទសម្ភាសន៍ដែល ស៊ីវ ហេដឌ័រ បានធ្វើជាមួយ អៀង សារី ។ នៅក្នុងបទសម្ភាសន៍នោះ អៀង សារី បានបញ្ជាក់ថា ផែនការជម្លៀសចេញពីទីក្រុងភ្នំពេញត្រូវបានលើកមកពិភាក្សាជាមួយ ប៉ុល ពត ក្នុងឆ្នាំ១៩៧៤ ។

ឯកសារមួយផ្សេងទៀតដែលតំណាងសហព្រះរាជអាជ្ញា ឃីត វ៉ែន័រ ដាក់បង្ហាញគឺជារបាយការណ៍របស់កាសែតញូវយ៉កថាមស៍ ចុះផ្សាយថ្ងៃទី៩ ខែកក្កដា ឆ្នាំ១៩៨២ ដែលនិយាយអំពីការនិរទេសរបស់សម្តេច នរោត្តម សីហនុ, ខៀវ សំផន និង សុន សេន ។ នៅក្នុងអត្ថបទនោះបានចុះផ្សាយថា ខៀវ សំផន បានទទួលស្គាល់ថា ប្រជាជនកម្ពុជារាប់លាននាក់ត្រូវបានជម្លៀសចេញពីទីក្រុងភ្នំពេញទៅតាមជនបទ ។ ការជម្លៀសនេះធ្វើឡើងបន្ទាប់ពីមានការសម្រេចជាសមូហភាព ដែលក្នុងនោះ ខៀវ សំផន ក៏បានចូលរួមក្នុងការធ្វើសេចក្តីសម្រេចនោះដែរ ។

### ក) រចនាសម្ព័ន្ធបញ្ជា និងរចនាសម្ព័ន្ធអំណាច

ក្នុងការសួរដេញដោលទៅលើប្រធានបទទាំងពីរនេះ តំណាងសហព្រះរាជអាជ្ញាដាក់បង្ហាញឯកសារមួយដែលជាផ្នែកមួយនៅក្នុងសៀវភៅរបស់ ស៊ីវ ហេដឌ័រ មានចំណងជើងថា “ម៉ាក្សនិយម និងពូជសាសន៍និយមប្រល័យពូជសាសន៍” ។ នៅក្នុងផ្នែកនេះនិយាយអំពីទស្សនទានរបស់បក្សកុម្មុយនីស្តកម្ពុជា ការទទួលមរតកពីកុម្មុយនីស្តចិន រចនាសម្ព័ន្ធបក្សថ្នាក់លើ ក្របខណ្ឌនៃអំណាចរបស់រដ្ឋ ដែលរួមមាន ថ្នាក់មជ្ឈិមបក្ស សាខាបក្ស ក្រសួង និងថ្នាក់ក្រោម ។ ស៊ីវ ហេដឌ័រ បានបញ្ជាក់បន្ថែមថា ពាក្យ “មជ្ឈិមបក្ស” ត្រូវបានប្រើដើម្បីសំដៅទៅលើគណៈកម្មាធិការមជ្ឈិមបក្ស ឬហៅថា មជ្ឈិម ។ ទោះបីជាយ៉ាងណាក៏ដោយ ពាក្យនេះស្ថិតនៅក្នុងភាពស្រពិចស្រពិល ពោលគឺពុំត្រូវបានប្រើដើម្បីកំណត់អង្គការដាក់លាក់ណាមួយឡើយ ។

ពាក់ព័ន្ធនឹងរចនាសម្ព័ន្ធនេះដែរ តំណាងសហព្រះរាជអាជ្ញា ឃីត វ៉ែន័រ ដាក់បង្ហាញសៀវភៅ ដែលនិពន្ធដោយ ស៊ីវ ហេដឌ័រ មានចំណងជើងថា "បុគ្គលទាំងប្រាំពីរនាក់ដែលត្រូវកាត់ទោស" ។ នៅក្នុងសៀវភៅនោះបានបញ្ជាក់ថា បក្សផ្ដល់ការណែនាំដល់ថ្នាក់ក្រោមៗ ភូមិភាគ តំបន់... រៀបចំ និងចាត់ចែងកម្មាភិបាលនៅក្នុងបក្ស ក្ដោបក្ដាប់ប្រវត្តិរូប អប់រំនយោបាយ និងមនោគមន៍វិជ្ជាជាប្រចាំ ។ គួរបញ្ជាក់ថា ក្រុមមេធាវីការពារក្ដីជនជាប់ចោទ នួន ជា បានជំទាស់ចំពោះការលើកយកសៀវភៅនេះមកសួរដេញដោល ស៊ីវ ហេដឌ័រ ដោយផ្ដល់ហេតុផលថា សៀវភៅនេះមានសារៈសំខាន់ក្នុងការចោទប្រកាន់កូនក្ដីខ្លួន ហើយនិពន្ធដោយ ស៊ីវ ហេដឌ័រ ដែលធ្លាប់មានតួនាទីយ៉ាងសំខាន់ក្នុងការស៊ើបអង្កេត ។ ទោះបីមានការអះអាងយ៉ាងនេះក្ដី សេចក្ដីជំទាស់របស់មេធាវីការពារក្ដីពុំមានសុពលភាពឡើយ ។ អង្គជំនុំជម្រះបានបញ្ជាក់ថា សៀវភៅនេះត្រូវបានដាក់ក្នុងសំណុំរឿងរួចហើយ ដូច្នេះភាគីអាចយកមកសួរដេញដោលបាន ។ ទោះបីជាយ៉ាងណាក៏ដោយ តម្លៃនៃភស្តុតាងសម្រាប់សៀវភៅនេះ នឹងសម្រេចនៅក្នុងដំណាក់កាលចុងក្រោយ ។

ទាក់ទងទៅនឹងការទទួលបញ្ជា និងការអនុវត្តអំណាចនេះដែរ តំណាងសហព្រះរាជអាជ្ញា ឃីត វ៉ែន័រ បានដាក់បង្ហាញឯកសារបទសម្ភាសន៍ដែល ស៊ីវ ហេដឌ័រ បានធ្វើជាមួយ កែ ពក នៅខេត្តសៀមរាប ក្នុងឆ្នាំ២០០១ ។ គួរបញ្ជាក់ថា ឯកសារបទសម្ភាសន៍នេះជាប្រភេទភស្តុតាងដែលអាចដាក់បន្ទុកទៅលើ កែ ពក និងបុគ្គលផ្សេងៗទៀត ។ ដូច្នេះក្នុងការធ្វើបទសម្ភាសន៍ ស៊ីវ ហេដឌ័រ បានឯកភាពថា នឹងមិនផ្សព្វផ្សាយបទបទសម្ភាសន៍នេះឡើយនៅខណៈដែល កែ ពក នៅមានជីវិត ។

តាមរយៈបទសម្ភាសន៍នោះ បានបញ្ជាក់ថា ក្នុងនាមជាលេខាភូមិភាគឧត្ដរ ក្រោយមកជាលេខា ភូមិភាគកណ្ដាល កែ ពក បានអនុវត្តគោលនយោបាយរបស់បក្សកុម្មុយនីស្ដកម្ពុជា ក្នុងការសម្លាប់មន្ត្រីសាធារណរដ្ឋខ្មែរ ហើយផ្ដួចផ្ដើមឲ្យមានការចាប់ខ្លួន និងបញ្ជាឲ្យសម្លាប់អ្នកស្ថិតនៅក្រោមការគ្រប់គ្រងរបស់គាត់ ដែលត្រូវបានចោទប្រកាន់ថាជាជនក្បត់ ។ កែ ពក បានអនុវត្តតាមបញ្ជារបស់ នួន [ជា] ក្នុងចាត់ចែងទៅលើការចាប់ខ្លួនអ្នកដែលត្រូវបានចោទប្រកាន់ថា ជាជនក្បត់នៅក្នុងជួរបក្សកុម្មុយនីស្ដកម្ពុជា ហើយអ្នកទាំងនោះត្រូវបានបញ្ជូនទៅមន្ទីរសន្តិសុខ ស-២១ និងសម្លាប់ចោលបន្ទាប់ពីសួរយកចម្លើយរួចរាល់ ។

គួរបញ្ជាក់ថា តាមការអះអាងរបស់ ស៊ីវ ហេដឌ័រ បទសម្ភាសន៍ដែលគាត់ធ្វើជាមួយ កែ ពក ពុំមានការថតជាខ្សែអាត់សំឡេងឡើយ គឺមានតែកំណត់ត្រាដោយដៃតែប៉ុណ្ណោះ ហើយកំណត់ត្រាទាំងនោះរក្សាទុកនៅទីក្រុងឡុងប្រទេសអង់គ្លេស ។ តំណាងសហព្រះរាជអាជ្ញា ឃីត វ៉ែន័រ ស្នើឲ្យផ្ដល់ឯកសារទាំងនោះជូនតុលាការ ប៉ុន្តែ ស៊ីវ ហេដឌ័រ បានបញ្ជាក់ថា មានការលំបាកក្នុងការស្វែងរកឯកសារទាំងនោះ ។

## ឃ) ការចាប់ខ្លួន និងសម្លាប់ខ្មាំង

ទាក់ទងនឹងប្រធានបទនេះ តំណាងសហព្រះរាជអាជ្ញា ឃីត វ៉ែន័រ ដាក់បង្ហាញឯកសារបទសម្ភាសន៍ដែល ស៊ីវ ហេដឌ័រ ធ្វើជាមួយបុគ្គលម្នាក់ឈ្មោះ សំអាង (មកពីតំបន់២១ ភូមិភាគបូព៌ា) នៅថ្ងៃទី១០ ខែមីនា ឆ្នាំ១៩៨០ ។ នៅក្នុងបទសម្ភាសន៍នេះ សំអាង បានរៀបរាប់ថា ដើម្បីចាប់ខ្លួនបុគ្គលណាម្នាក់ គេប្រាប់បុគ្គលនោះថាត្រូវទៅរៀនសូត្រ ។ បើសិនបុគ្គលនោះមិនព្រមទៅ គេប្រាប់ថា ជាភារកិច្ចដែលត្រូវចូលរួម ។ បន្ទាប់មកលេខាតំបន់ និងលេខាភូមិភាគ ឬលេខាយោធាតំបន់ ជាអ្នកចាប់បញ្ជូនយកទៅ ។ ចំពោះវិធីសាស្ត្រក្នុងការចាប់ខ្លួនមន្ត្រីរបស់របបសាធារណរដ្ឋខ្មែរក្នុងឆ្នាំ១៩៧០ គេប្រាប់មន្ត្រីទាំងនោះថា ទៅជួបអង្គការថ្នាក់លើ ដើម្បីសុំការលើកលែងទោស ។ ជាលទ្ធផលមន្ត្រីទាំងនោះត្រូវបាននាំយកទៅសម្លាប់ចោល ។ តាមរយៈបទសម្ភាសន៍មួយចំនួនដែល ឃីត វ៉ែន័រ បានដាក់បង្ហាញ បានលើកឡើងថា ទាហាន និងមន្ត្រីរដ្ឋការនៃរបប លន់ នល់ ត្រូវបានចាត់ទុកថាជាខ្មាំង ហើយត្រូវបានសម្លាប់ចោល ។ តាមរយៈឯកសារកិច្ចសម្ភាសន៍ជាមួយ ម៉ាត់ លី ដែលជាអតីតគណៈស្រុក និងជាសមាជិកនៃគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភាបានបញ្ជាក់ថា អ្នកដែលធ្លាប់បម្រើការពីមុន ដែលមានស័ក្ដិ១ ឬស័ក្ដិ២ ត្រូវបានសម្លាប់ចោលដោយចោទថាអ្នកទាំងនោះជាខ្មាំងដែលបម្រើឲ្យ សេ.អ៊ី.អា, កា.ហ្សេ.បេ ឬគិញយួន ។ និស្សិត គ្រូបង្រៀន វេជ្ជបណ្ឌិត និងបញ្ញវន្តជាច្រើនត្រូវបានសម្លាប់ចោល ។ អ្នកទាំងនោះត្រូវបាន

គេណែនាំឲ្យប្រាប់ការពិតអំពីប្រវត្តិការងាររបស់ខ្លួន ដោយបោកបញ្ឆោតថាឲ្យទៅធ្វើការងារនោះវិញ ។ ទោះបីជាយ៉ាងណា នៅមានបញ្ញាជនមួយចំនួននៅមានជីវិត ដោយអ្នកទាំងនោះបានលាក់បាំងប្រវត្តិពិតរបស់ខ្លួន ។

ទាក់ទងនឹងការបោសសម្អាតខ្មាំង តំណាងសហព្រះរាជអាជ្ញា ឃីត វែន័រ ដាក់បង្ហាញឯកសារបទសម្ភាសន៍ដែល ស៊ីវ ហេងឌ័រ បានធ្វើជាមួយអតីតអនុលេខាតំបន់២១ និងជាសមាជិករបស់គណៈអចិន្ត្រៃយ៍ភូមិភាគបូព៌ា (មិនបញ្ចេញឈ្មោះ) ។ តាមរយៈបទសម្ភាសន៍នោះបានបញ្ជាក់ថា នៅខែមេសា ឆ្នាំ១៩៧៥ ប៉ុល ពត បានចេញគោលនយោបាយសម្ងាត់មួយឲ្យបោសសម្អាតសមាសភាពនៃរបប លន់ នល់ ចាប់ពីស័ក្តិ១ រហូតដល់ថ្នាក់ឧត្តមសេនីយ៍ ។ នៅក្នុងខែឧសភា ឆ្នាំ១៩៧៥ ប៉ុល ពត កោះហៅកម្មាភិបាលថ្នាក់ស្រុក ថ្នាក់តំបន់ និងកម្មាភិបាលយោធាចាប់ពីវរសេនាតូចឡើងទៅ នៅទូទាំងប្រទេសមកជួបប្រជុំនៅសាលាបច្ចេកទេសមិត្តភាពកម្ពុជា-សូវៀត ។ នៅក្នុងកិច្ចប្រជុំនោះ ប៉ុល ពត ប្រកាសប្រឆាំងយ៉ាងម៉ឺងម៉ាត់ និងគាស់រំលីងកំអែលនៃរបបចាស់ ដើម្បីសម្រេចគោលដៅនៃការធ្វើបដិវត្តន៍សង្គមនិយម ។

ឯកសារមួយចំនួនទៀតដែលតំណាងសហព្រះរាជអាជ្ញា ឃីត វែន័រ ដាក់បង្ហាញបានបញ្ជាក់ថា ក្នុងការសម្រេចឲ្យសម្លាប់ ឬដោះលែងជនណាម្នាក់ ថ្នាក់ស្រុកត្រូវស្វែងរកការសម្រេចពីថ្នាក់តំបន់ ហើយថ្នាក់តំបន់ចាំបាច់ត្រូវមានការឯកភាពពីគណៈអចិន្ត្រៃយ៍ភូមិភាគ ។ អៀង សារី ធ្លាប់ទទួលបានរបាយការណ៍ពីភូមិភាគ ឬតំបន់ ដែលរាយការណ៍អំពីការសម្លាប់ និងការធ្វើទុក្ខបុកម្នេញទៅលើអ្នកទោស ។

## ង) ការបែងចែកប្រជាជន

ទាក់ទងនឹងការបែងចែកប្រជាជនតំណាងសហព្រះរាជអាជ្ញា ឃីត វែន័រ បានដកស្រង់ខ្លឹមសៀវភៅរបស់ ស៊ីវ ហេងឌ័រ ដែលមានចំណងជើងថា "ជនទាំងប្រាំពីររូបដែលត្រូវកាត់ទោស" ។ សៀវភៅនេះបានបញ្ជាក់ថា ប្រជាជនត្រូវបានបែងចែកជាបីប្រភេទ គឺប្រជាជនពេញសិទ្ធិ ប្រជាជនត្រៀម និងប្រជាជនបញ្ញើ ។ នៅក្នុងដំណាក់កាលដំបូងនៃការចាប់ផ្តើមនៃរបបកម្ពុជាប្រជាធិបតេយ្យ ប្រជាជនពេញសិទ្ធិទទួលបានរបបម្ហូបអាហារគ្រប់គ្រាន់ ឬបានច្រើនជាងប្រជាជនផ្សេងទៀត ហើយមានសិទ្ធិចូលរួមជាមួយអង្គការនយោបាយ និងកងទ័ព ។ ចំណែកប្រជាជនត្រៀម មានសិទ្ធិកាន់កាប់តួនាទីនយោបាយថ្នាក់ក្រោមៗ ។ ចំពោះប្រជាជនបញ្ញើ ត្រូវបានចាត់ទុកថាស្ថិតនៅថ្នាក់ក្រោមបំផុត ដែលគ្មានសិទ្ធិនយោបាយអ្វីទាំងអស់ ហើយប្រឈមទៅនឹងការយកទៅសម្លាប់ចោលតាមទំនើងចិត្ត ។ តាមសម្រង់មួយផ្សេងទៀតដែល ឃីត វែន័រ បានលើកឡើង បានបញ្ជាក់ថា នៅឆមាសទី២ ឆ្នាំ១៩៧៨ ការបែងចែកប្រជាជនជាបីប្រភេទនេះត្រូវបានលុបចោលជាផ្លូវការ ។ ប៉ុន្តែបានធ្លាក់ចូលទៅដល់អ្វីដែល ប៉ុល ពត ហៅថា អ្នកដែលល្អ អ្នកកណ្តាល និងអ្នកដែលមានសមាសធាតុមិនល្អនៅក្នុងចំណោមប្រជាជន និងនៅក្នុងបក្ស ។ ទាក់ទងទៅនឹងការប្រើប្រាស់ពាក្យ ប្រជាជនចាស់ និងប្រជាជនថ្មី ស៊ីវ ហេងឌ័រ បានបញ្ជាក់ថា ពាក្យទាំងពីរនេះត្រូវបានប្រើប្រាស់តាំងពីមុនឆ្នាំ១៩៧៥ម៉្លេះ ។ ប្រជាជនថ្មីត្រូវបានប្រើសំដៅទៅប្រជាជនដែលទើបតែរំដោះបានថ្មីៗ ឬអ្នកដែលទើបមកដល់ថ្មីៗ ដែលខុសពីអ្នកដែលរស់នៅក្នុងតំបន់រំដោះរបស់ខ្មែរក្រហមតាំងពីមុនមក ។

## ច) វិធានការចំពោះព្រះសង្ឃ

តាមដែលលោក ឃីត វែន័រ ដកស្រង់ខ្លឹមសារសៀវភៅដែលនិពន្ធដោយ ស៊ីវ ហេងឌ័រ បានបញ្ជាក់ថា គណៈសង្ឃទាំងអស់ដែលនៅតាមទីប្រជុំជន និងនៅទីក្រុងភ្នំពេញ ត្រូវបានបក្សកុម្មុយនីស្តកម្ពុជារំសាយចោលទាំងអស់ ហើយត្រូវបានបណ្តេញឲ្យទៅរស់នៅតាមទីជនបទ ។ ការធ្វើដូច្នេះ គឺដើម្បីទប់ស្កាត់មិនឲ្យមានការប្រមូលផ្តុំ ដែលអាចឈានទៅដល់ការប្រឆាំងនឹងរបបថ្មីរបស់ខ្លួន ។ បក្សកុម្មុយនីស្តកម្ពុជាចាត់ទុកគណៈសង្ឃស្ថិតនៅក្នុងវណ្ណៈខ្ពស់មួយស្មើនិងអ្នកមានបណ្តាស័ក្តិ ដែលជាគោលដៅនៃការសម្លាប់ភ្លាមៗ ។ លោក ឃីត វែន័រ បានបញ្ជាក់ថា ប្រភពនៃព័ត៌មានទាំងនេះបានមកពីសៀវភៅកំណត់ត្រានៅរបបកម្ពុជាប្រជាធិបតេយ្យរបស់កម្មាភិបាលខ្មែរក្រហមម្នាក់ ដែលកត់ត្រាថា "គណៈដឹកនាំជាន់ខ្ពស់នៃគណៈសង្ឃភាគច្រើន គឺស្ថិតនៅក្រោមឥទ្ធិពលនយោបាយនៃវណ្ណៈខ្ពស់ជាងគេ" ។

## ឆ) ការសួរដេញដោលអំពីសៀវភៅ "ប៉ុល ពត និង ខៀវ សំផន"

លោក ឃីត វ៉េន័រ បានដកស្រង់ខ្លឹមសារនៅក្នុងសៀវភៅនេះ ដែលបានលើកឡើងថា ខៀវ សំផន ធ្វើជាប្រធាននៃសមាជដែលជាកិច្ចប្រជុំរបស់រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ដែលធ្វើនៅក្នុងប្រទេសកម្ពុជា ដោយមានអ្នកតំណាងចូលរួម២៧៣រូប ។ នៅក្នុងសមាជនោះបានសម្រេច និងប្រកាសថា ជនក្បត់ទាំងប្រាំពីរត្រូវសម្លាប់ និងអំពាវនាវឲ្យមន្ត្រីរដ្ឋការ និងទាហាននៃរបប លន់ នល់ ទម្លាក់អាវុធចុះ ហើយចូលរួមជាមួយសម្តេច នរោត្តម សីហនុ ។ សេចក្តីប្រកាស និងការអំពាវនាវនេះ ត្រូវបាន ខៀវ សំផន ធ្វើម្តងទៀតនៅថ្ងៃទី១ ខែមេសា ឆ្នាំ[១៩៧៥] ។ ស៊ីវ ហេដឌ័រ បានបញ្ជាក់បន្ថែមថា សេចក្តីប្រកាស និងការអំពាវនាវទាំងនេះត្រូវបានកាសែតចុះផ្សាយ ហើយអាចរកមើលបាននៅក្នុងស្ថានទូតសហរដ្ឋអាមេរិកប្រចាំនៅទីក្រុងភ្នំពេញ ។

នៅក្នុងសៀវភៅនេះដែរបានបញ្ជាក់ថា ខៀវ សំផន ស្ថិតនៅក្រោមអំណាចរបស់ ប៉ុល ពត ។ នៅក្នុងខែឧសភា ឆ្នាំ១៩៧៥ បក្សកុម្មុយនីស្តកម្ពុជាបានបើកសមាជបក្ស ដោយបញ្ជាក់អំពីសមាជិកភាពរបស់ ខៀវ សំផន ស្ថិតនៅក្នុងគណៈមជ្ឈិម ។ លោក ឃីត វ៉េន័រ បានដកស្រង់បន្ថែមថា កំណត់ហេតុនៃកិច្ចប្រជុំគណៈអចិន្ត្រៃយ៍ដែលបានធ្វើនៅចន្លោះឆ្នាំ១៩៧៥-១៩៧៦ បានបង្ហាញឲ្យឃើញថា ខៀវ សំផន បានចូលរួមប្រជុំគណៈអចិន្ត្រៃយ៍យ៉ាងទៀងទាត់ ។ ស៊ីវ ហេដឌ័រ បានបំភ្លឺថា មានកំណត់ហេតុកិច្ចប្រជុំគណៈអចិន្ត្រៃយ៍ចំនួន ៥ដែលបង្ហាញអំពីវត្តមានរបស់ ខៀវ សំផន ។ កំណត់ហេតុនេះគឺទទួលបានពីលោក ដេវីដ ឆេនដ៍ល័រ ។

### ជ) ការវាយប្រហារចូលទីក្រុងភ្នំពេញ

ស៊ីវ ហេដឌ័រ បានបញ្ជាក់ថា ក្នុងអំឡុងពេលដែលគាត់រស់នៅទីក្រុងភ្នំពេញ ខ្មែរក្រហមបានបាញ់ផ្លោងកាំភ្លើងធំ (មកពីទិសខាងកើត) ជាច្រើនគ្រាប់ចូលមកក្នុងទីក្រុង ។ ការបាញ់ផ្លោងនេះបានបណ្តាលឲ្យប្រជាជនជាច្រើនអ្នកបាត់បង់ជីវិត ហើយផ្ទះសម្បែងជាច្រើនទទួលរងការខូចខាតទាំងស្រុង ។ ស៊ីវ ហេដឌ័រ អះអាងថា កងកម្លាំងដែលបាញ់ផ្លោងនេះគឺដឹកនាំដោយ អ៊ិន លន ហៅ ណាត ដែលភាគច្រើនបាញ់ផ្លោងគ្រាប់ ១០៧ មីលីម៉ែត្រ ហើយគ្រាប់មួយចំនួនទៀតបាញ់ផ្លោងដោយកងពលមកពីភូមិភាគបូព៌ា ដែលស្ថិតនៅក្រោមការបញ្ជារបស់អគ្គសេនាធិការ ដោយមាននាយអគ្គសេនាធិការ សុន សេន ជាអ្នកបញ្ជា និង ប៉ុល ពត ជាអ្នកបញ្ជារួម ។ ក្នុងអំឡុងពេលនៃការវាយប្រយុទ្ធនោះ កងកម្លាំងខ្មែរក្រហមមានអង្គការលេខ និងរចនាសម្ព័ន្ធចាត់តាំងត្រឹមត្រូវ ។ ណាត ត្រូវបានចាត់តាំងឲ្យនៅភូមិភាគពិសេស ដែលមាន វន វេត ជាប្រធានភូមិភាគពិសេស ។ សោ ភឹម ហៅក្រៅ សូ វណ្ណា ជាលេខាភូមិភាគបូព៌ា ។ រស់ ញឹម លេខាភូមិភាគពាយ័ព្យ ។ ចំណែក អ៊ិត សារិន ដែលពីមុនស្ថិតនៅក្នុងក្បាលម៉ាស៊ីននៃរបបសាធារណរដ្ឋខ្មែរបានចុះចូល ហើយត្រូវបានចាត់តាំងឲ្យបម្រើការក្នុងក្បាលម៉ាស៊ីនរបស់កម្លាំងខ្មែរក្រហមដែរ ។

### ឈ) ការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ និងការបង្កើតសភា

ទាក់ទងនឹងវិធីសាស្ត្រក្នុងការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ តំណាងសហព្រះរាជអាជ្ញា ឃីត វ៉េន័រ បានលើកយកឯកសារបទសម្ភាសន៍ដែល ស៊ីវ ហេដឌ័រ សម្ភាសជាមួយ ម៉ាត់ លី (អតីតគណៈស្រុក និងជាសមាជិកនៃគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា) មកដាក់បង្ហាញដើម្បីសួរដេញដោល ។ នៅក្នុងបទសម្ភាសន៍នោះ ម៉ាត់ លី បានរៀបរាប់ថា នៅក្នុងមណ្ឌលមានសន្លឹកឆ្នោតមួយ ដែលមានតែបេក្ខជនម្នាក់ដាក់ឲ្យឈរឈ្មោះ ។ ម៉ាត់ លី ផ្តល់ឧទាហរណ៍ថា រូបគាត់ត្រូវបានជ្រើសរើសឲ្យឈរឈ្មោះ ដែលឈ្មោះរបស់គាត់ត្រូវបានសរសេរនៅលើសន្លឹកឆ្នោត ប៉ុន្តែពុំមានរូបថតឡើយ ។ គេហៅប្រជាជននៅក្នុងមណ្ឌលនោះឲ្យមកបោះឆ្នោត ដោយប្រាប់ថា ប្រសិនបើមិនពេញចិត្តបេក្ខជនឈរឈ្មោះរូបនេះ (ម៉ាត់ លី) អាចគូសចោលបាន ។ ម៉ាត់ លី បញ្ជាក់ថា គ្មាននរណាម្នាក់ហ៊ានគូសឈ្មោះរបស់ខ្លួនចោលឡើយ ។ ម៉ាត់ លី បានបញ្ជាក់ថែមទៀតថា "ដូច្នេះបន្ទាប់ពីការបោះឆ្នោតនៅថ្ងៃទី១១ ខែឧសភា គេបានកោះខ្ញុំទៅកិច្ចប្រជុំ ហើយខ្ញុំចេញពីស្រុក ខ្ញុំនៅក្នុងកិច្ចប្រជុំនៅថ្ងៃទី១២ នៅថ្ងៃទី១៣ខ្ញុំត្រឡប់មកវិញ ។ មកហ្នឹងគេណែនាំឲ្យប្រាប់ថា សភារបស់បក្ស ហើយឥឡូវធ្វើការត្រូវឲ្យបក្សធ្វើ ។ ប៉ុន្តែសភាយើងនេះ គឺមានច្បាប់ និងទម្លាប់អីចឹង ដើម្បីឲ្យអន្តរជាតិគេដឹងថា យើងមានច្បាប់ មានទម្លាប់ មានសភាអីចឹងត្រឹមត្រូវដូចគេដែរ ។ អាហ្នឹងគេប្រាប់យើងអីចឹង ។ ប៉ុន្តែខ្លឹមសារអង្គប្រជុំនោះ

គឺមិននិយាយអំពីការចាត់តាំងរដ្ឋមន្ត្រី ក្រុមប្រឹក្សារដ្ឋមន្ត្រី ឬក៏ក្រុមប្រឹក្សារដ្ឋទេ ។ និយាយពីវិធីចាត់តាំងសភា ។ សភាមានចាត់តាំងក្នុង២៥០នាក់ហ្នឹង គេថាគណៈអចិន្ត្រៃយ៍មាន១០នាក់ ។ ១០នាក់មានប្រធានមួយរូបគឺ នួន ជា ហ្នឹងឯង ។ ហើយមានអនុប្រធានពីររូប ហើយក្រៅពីហ្នឹងសុទ្ធតែសមាជិក ។ ក្នុងហ្នឹងខ្ញុំជាសមាជិកអចិន្ត្រៃយ៍ម្នាក់ដែរ ។ សមាជិកទី៨ គឺ ខ្ញុំ ។ អ៊ីចឹងតើប្រជុំហ្នឹងពិភាក្សាអំពីអ្វី? គឺមិនមានពិភាក្សាអ្វីទេ គេគ្រាន់តែអាន ហើយយើងគ្រាន់តែលើកដៃ ។ ជាឧទាហរណ៍ គេអានអំពីការចាត់តាំងមួយ ពីរ បី ។ អ្នកណាជាប្រធាន អ្នកណាជាអនុប្រធាន អ្នកណាជាសមាជិក ហើយយើងក៏ទះដៃ ។ រីឯរដ្ឋធម្មនុញ្ញតែមួយភ្លែតទេ គេសរសេរល្អណាស់ ។ រដ្ឋធម្មនុញ្ញគេហ្នឹង ជាឧទាហរណ៍គេសរសេរថា ប្រជាជនមានសិទ្ធិជឿសាសនា ឬមិនជឿសាសនាក៏បាន តែហាមដាច់ខាត មិនឲ្យជឿសាសនាប្រតិកិរិយា ។ គេសរសេរអ៊ីចឹង ប៉ុន្តែធាតុពិត មុននឹងការប្រជុំសភាហ្នឹង គេលុបសាសនាអស់ទៅហើយ» ។ ម៉ាត់ លី បានបញ្ជាក់ទៀតថា ប៉ុល ពត ត្រូវបានតែងតាំងជានាយករដ្ឋមន្ត្រី, ហ៊ូ នឹម ជារដ្ឋមន្ត្រីឃោសនាការ និងវប្បធម៌, ខៀវ សំផន ជាប្រធានគណៈប្រធានរដ្ឋ, សោ ភឹម អនុប្រធានទី១[សភា] និង រស់ ញឹម អនុប្រធានទី២ ។ កិច្ចប្រជុំសភាមានតែ២ម៉ោងប៉ុណ្ណោះ គឺចាប់ផ្តើមពីម៉ោង ៧:៣០នាទី ដល់ ៩:៣០នាទី ។ បន្ទាប់ពីបញ្ចប់ការដកស្រង់បទសម្ភាសន៍នេះ ស៊ីវ ហេងឌ័រ បានអះអាងថា បានកត់ត្រាខ្លឹមសារទាំងនេះយ៉ាងត្រឹមត្រូវ នៅពេលលោកធ្វើការសម្ភាសន៍ជាមួយ ម៉ាត់ លី ។

### ៣) តួនាទីរបស់ ខៀវ សំផន

ទាក់ទងនឹងតួនាទីរបស់ ខៀវ សំផន ក្រោយឆ្នាំ១៩៧៩ តំណាងសហព្រះរាជអាជ្ញា ឃីត វ៉េន័រ ដាក់បង្ហាញឯកសារមួយដែលនិយាយអំពីប្រវត្តិរូបរបស់សមាជិករដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ។ ឯកសារនេះបញ្ជាក់ថា នៅខែធ្នូ ឆ្នាំ១៩៧៩ ពោល ១១ខែក្រោយរបបកម្ពុជាប្រជាធិបតេយ្យត្រូវបានផ្តួលរំលំដោយកងទ័ពវៀតណាម រដ្ឋាភិបាលនៃរបបកម្ពុជាប្រជាធិបតេយ្យត្រូវបានកែប្រែ ។ ខៀវ សំផន ត្រូវបានតែងតាំងជានាយករដ្ឋមន្ត្រី បន្ទាប់ពី ប៉ុល ពត សម្រេចចុះចេញពីអំណាច ។ តាមការបញ្ជាក់របស់ ស៊ីវ ហេងឌ័រ ឯកសារនេះត្រូវបានកម្មាភិបាលខ្មែរក្រហមឈ្មោះ ចាន់ យូរ៉ាន់ (មិនច្បាស់) ផ្តល់ជូនអ្នកកាសែត ហើយអ្នកកាសែតបានផ្តល់ឯកសារនេះជូនគាត់ ។

ស៊ីវ ហេងឌ័រ បានបញ្ជាក់បន្ថែមថា នៅខែសីហា ឆ្នាំ១៩៨០ លោកបានសម្ភាសជាមួយ ខៀវ សំផន នៅជិតកំពូលភ្នំដងរែក ដោយមានវត្តមានរបស់ ជួន ម៉ុម និង សុន សេន ។ នៅពេលនោះ ខៀវ សំផន បានលើកឡើងអំពីការបោសសំអាតខ្មាំងក្នុងអំឡុងឆ្នាំ១៩៧៧-១៩៧៨ ។ ខៀវ សំផន បានទទួលស្គាល់ថាពិតជាមានការសម្លាប់មនុស្ស ប៉ុន្តែការសម្លាប់នោះដោយសារការជ្រៀតចូលពីវៀតណាមតាមរយៈការបញ្ជ្រៀបភ្នាក់ងារសម្ងាត់



ខៀវ សំផន (រូបថតមជ្ឈមណ្ឌលឯកសារកម្ពុជា)

មកក្នុងបក្សកុម្មុយនីស្តកម្ពុជា ។ ចំណែក សុន សេន បានលើកឡើងថា រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យកំពុងតែតស៊ូប្រយុទ្ធប្រឆាំងជាមួយវៀតណាម ។

ទាក់ទងនឹងតួនាទីរបស់ ខៀវ សំផន ដែរ តំណាងសហព្រះរាជអាជ្ញាដាក់បង្ហាញឯកសារដែល ស៊ីវ ហេងឌ័រ សម្ភាសជាមួយ អៀង សារី ក្នុងខែមករា ឆ្នាំ១៩៩៩ ។ នៅក្នុងបទសម្ភាសន៍នោះ អៀង សារី បញ្ជាក់ថា «ខៀវ សំផន បានក្លាយជាសមាជិកគណៈមជ្ឈិមនៅឆ្នាំ១៩៧៦ ។ ក្នុងនាមជាប្រធាន៨៧០ ការបញ្ជូន និងការដកកម្មាភិបាល គឺត្រូវតែឆ្លងកាត់គាត់...» ។ តំណាងសហព្រះ

រាជអាជ្ញា ឃីត វ៉ែន ដាក់បង្ហាញឯកសារមួយទៀតដែល ស្ទីវ ហេដឌ័រ បានអះអាងថាបានសម្ភាសជាមួយ វ៉ាន់រិទ្ធិ នៅស្រុកស្អាង ខេត្តកណ្តាល ក្នុងខែមីនា ឆ្នាំ២០០៤ ។ ក្នុងបទសម្ភាសន៍នោះ វ៉ាន់រិទ្ធិ បានបញ្ជាក់ថា ខៀវ សំផន ជាប្រធានមន្ទីរ៨៧០ បន្ទាប់ពីឌឿន ។ ទាក់ទងនឹងតួនាទីនេះដែរ លោក ឃីត វ៉ែន ដាក់បង្ហាញសៀវភៅមួយមានចំណងជើងថា "បុគ្គលប្រាំពីរនាក់ដែលត្រូវចោទប្រកាន់" ។ សៀវភៅនេះបានបញ្ជាក់ថា ក្នុងនាមជាប្រធានមន្ទីរ៨៧០នេះ ខៀវ សំផនជាអ្នកធ្វើកំណត់ហេតុកិច្ចប្រជុំសម្ងាត់មួយដែលមានវត្តមាន ប៉ុល ពត, នួន ជា និង សុន សេន ។ កិច្ចប្រជុំនេះបានសម្រេចឲ្យមានការបោសសម្អាត និងសម្លាប់ សោ ភឹម លេខាភូមិភាគបូព៌ា និងកម្មាភិបាលជាច្រើនទៀតនៅក្នុងភូមិភាគនេះ ។

### ង) មាគ៌ាពង្រីងប្រជាជនពីខ្មាំង

ទាក់ទងនឹងការពង្រីងប្រជាជនពីខ្មាំង តំណាងសហព្រះរាជអាជ្ញា ឃីត វ៉ែន ដាក់បង្ហាញឯកសារទង់បដិវត្តន៍លេខពិសេសរបស់បក្សកុម្មុយនីស្តកម្ពុជា ចុះផ្សាយសម្រាប់ខែធ្នូ-មករា ឆ្នាំ ១៩៧៦-១៩៧៧ ដោយដកស្រង់ខ្លឹមសារមួយចំនួន ដើម្បីសួរសាក្សីបញ្ជាក់ ។ ខ្លឹមសារនោះបញ្ជាក់ថា "ការវាយប្រហារខ្មាំងតាមរូបភាពនយោបាយ សូមជូនជាឧទាហរណ៍មួយ ដូចជាការវៃដើម្បីដណ្តើមប្រជាជននៅទូទាំងពិភពលោកនេះ គេមិនដែលវាយប្រហារ វាយប្រយុទ្ធដើម្បីដណ្តើមប្រជាជនទេ ។ មាគ៌ារបស់យើងវាយប្រយុទ្ធដើម្បីដណ្តើមប្រជាជន ។ នៅពេលយើងដណ្តើមបានយើងយកប្រជាជនម្នាក់ក៏យើងយក ពីរនាក់ក៏យក ១០០ក៏យក ២០០ក៏យក ១ពាន់នាក់ក៏យើងត្រូវតែប្រមូលជាដើម ។ល។ រហូតដល់យើងវាយប្រយុទ្ធ និងក្តាប់ប្រមូលបានប្រជាជនទីក្រុងភ្នំពេញទាំងអស់ ។ មាគ៌ាពង្រីងប្រជាជនពីខ្មាំងនេះគឺជាមាគ៌ាត្រឹមត្រូវហើយ ។ មាគ៌ានេះមិនដែលកើតមាននៅក្នុងពិភពលោកទេ ។ នៅពេលខ្មាំងមានប្រជាជន ខ្មាំងមានទាំងយោធា ខ្មាំងមានទាំងសេដ្ឋកិច្ច ។ ពេលណាខ្មាំងមិនមានប្រជាជន ខ្មាំងមិនមានកងទ័ព ខ្មាំងមិនមានកម្លាំងកងទ័ព កម្លាំងសេដ្ឋកិច្ចទេ ។ ហេតុផលរបស់យើងនេះត្រឹមត្រូវហើយ ។ ដូច្នេះមាគ៌ារបស់យើងនេះត្រឹមត្រូវហើយ ។ យើងវាយប្រយុទ្ធដើម្បីដណ្តើមប្រជាជននៅគ្រប់ទីកន្លែងទាំងអស់ ។ ឧទាហរណ៍មួយ ការវាយនៅបាណាម ក្នុងឆ្នាំ១០៧៣ យើងបានដណ្តើមប្រជាជនទាំងអស់នៅទីក្រុងបាណាម ដែលជនជាតិវៀតណាម ជនជាតិចិន យោធា នគរបាល យើងដណ្តើមយកទាំងអស់ គឺដើម្បីពង្រីងប្រជាជនពីខ្មាំង ។...ដោយសារតែយើងដណ្តើមយកប្រជាជន នៅពេលយើងទាញយកប្រជាជនអស់ហើយពេលនោះ គឺគេលែងមានកម្លាំងអីតទៅទៀតហើយ ។ ឧទាហរណ៍យើង រំដោះឧដុង្គនៅឆ្នាំ១៩៧៤ យើងទាញយកប្រជាជន ។ នេះគឺជាមាគ៌ាយុទ្ធសាស្ត្រដ៏សំខាន់ក្នុងការគ្រប់គ្រងនិងក្នុងការដណ្តើមប្រជាជន" ។ ស្ទីវ ហេដឌ័រ បានបញ្ជាក់បន្ថែមថា មានបទសម្ភាសន៍ជាច្រើន ដែលបានធ្វើជាមួយប្រជាជន ក៏បានលើកឡើងអំពីការដណ្តើម និងអូសទាញយកប្រជាជនដែរ ។ ពាក្យទាំងនេះ គឺសំដៅថា ធ្វើយ៉ាងណាត្រូវដណ្តើមគ្រប់គ្រងប្រជាជនឲ្យបាននៅពេលមានការវាយប្រយុទ្ធគ្នា ។

ពាក់ព័ន្ធនឹងមាគ៌ាពង្រីងប្រជាជននេះដែរ តំណាងសហព្រះរាជអាជ្ញា ឃីត វ៉ែន លើកយកសុន្ទរកថាដែល ខៀវ សំផន បានថ្លែង ហើយត្រូវបានផ្សព្វផ្សាយដោយវិទ្យុភ្នំពេញនៅថ្ងៃទី ២១ ខែមេសា ឆ្នាំ១៩៧៥ ។ នៅពេលនោះ ខៀវ សំផន បានថ្លែងថា "នេះគឺជាជ័យជំនះប្រវត្តិសាស្ត្រមហាធំធេងរបស់ប្រជាជន និងប្រជាជាតិកម្ពុជាយើង ។ ប្រជាជាតិយើងទាំងមូល និងកងទ័ពរំដោះជាតិកម្ពុជា ក៏ដូចជាប្រជាជននៅទូទាំងពិភពលោក និងបណ្តាប្រទេសជាមិត្តទាំងអស់ ទាំងជិត ទាំងឆ្ងាយ បានស្វាគមន៍មហាជ័យជម្នះនេះយ៉ាងកក់ក្តៅបំផុត ។ នេះគឺជាបើកឡើងនូវមាគ៌ាប្រកបទៅដោយភាពត្រឹមត្រូវ និងអនុញ្ញាតឲ្យប្រជាជនកម្ពុជា និងកងទ័ពរំដោះជាតិកម្ពុជា នៅក្នុងការបង្កសង្គ្រាមប្រយុទ្ធជាមួយខ្មាំង ទាំងផ្នែកកងទ័ព ទាំងផ្នែកនយោបាយ ទាំងផ្នែកសេដ្ឋកិច្ច និងកិច្ចខិតខំប្រឹងប្រែង ដើម្បីពង្រីងប្រជាជនចេញពីតំបន់ដែលគ្រប់គ្រង [ដោយខ្មាំង] ហើយបានកម្ទេចខ្មាំងយ៉ាងជោគជ័យ ហើយយើងបានវាយប្រយុទ្ធឥតនឿយណាយ និងបានធ្វើឲ្យខ្មាំងរីងស្ងួតទាំងផ្នែកនយោបាយ យោធា សេដ្ឋកិច្ច ហិរញ្ញវត្ថុ ហើយ និងមិនមានទាំងស្បៀងអាហារ ស្រូវ អង្ករ រហូតដល់ចុងបញ្ចប់ខ្មាំងបានស្លាប់យ៉ាងកំសាក" ។ ស្ទីវ ហេដឌ័រ បានអះអាងបន្ថែមថា បានស្តាប់ឮការផ្សព្វផ្សាយនេះនៅថ្ងៃទី២១ ខែមេសា ឆ្នាំ ១៩៧៥ ។ ព័ត៌ទាំងនេះត្រូវបានចែកចាយទៅដល់ស្ថានទូតសហ

រដ្ឋអាមេរិកប្រចាំនៅទីក្រុងបាងកក ។

### ឃ) ការវាយផ្តាច់ទន្លេមេគង្គ

ទាក់ទងនឹងការវាយប្រហាររបស់យោធាខ្មែរក្រហមនៅតាមដងទន្លេមេគង្គ ស៊ីវ ហេងឌ័រ បានបញ្ជាក់ថា ការវាយប្រហារនេះក្នុងគោលបំណងទប់ស្កាត់ការផ្គត់ផ្គង់ស្បៀងអាហារ និងគ្រាប់យុទ្ធភណ្ឌ ដែលដឹកមកពីសៃហ្គន ប្រទេសវៀតណាមខាងត្បូង មកតាមដងទន្លេមេគង្គដើម្បីផ្តល់ជូនទីក្រុងភ្នំពេញ ។ នៅតាមដងទន្លេមេគង្គ យោធាខ្មែរក្រហម (របស់ភូមិភាគបូព៌ា និងភូមិភាគពិសេស) បានដាក់បង្កប់គ្រាប់មីន ដើម្បីកុំឲ្យនាវាឆ្លងកាត់ ។ នាវាដែលព្យាយាមបើកចូលទីក្រុងភ្នំពេញ បានទទួលរងការបាញ់ប្រហារ និងផ្ទុះដោយសារគ្រាប់មីន ។

### ២) អំពើប្រល័យពូជសាសន៍

ទាក់ទងនឹងប្រធានបទស្តីអំពីអំពើប្រល័យពូជសាសន៍ តំណាងសហព្រះរាជអាជ្ញា ឃីត វិន័រ ដាក់បង្ហាញឯកសារដែល ស៊ីវ ហេងឌ័រ បានសម្ភាស អៀង សារី ដោយដកស្រង់ខ្លឹមសារមួយចំនួនមកសួរបញ្ជាក់ ។ តំណាងសហព្រះរាជអាជ្ញាដកស្រង់សម្តីរបស់ អៀង សារី ដែលបញ្ជាក់ថា *"...អំពើប្រល័យពូជសាសន៍បង្កើតឡើង គឺដោយសារតែគោលនយោបាយដែលវាមានបញ្ហាបរាជ័យ ។ ទី១) មានផែនការអនុវត្តដោយអង្គការមហាជន គឺដោយសារការបង្ខិតបង្ខំ និងដោយជឿនលឿនបំផុត ។ ទី២) មានផែនការអនុវត្ត គឺធ្វើការជាតួបនីយកម្មខ្មែរដោយលឿនបំផុត ។ ទី៣) អ្នកណាម្នាក់ហ៊ានតវ៉ាជំទាស់ ឬខកខានមិនបានអនុវត្តផែនការនេះអាចត្រូវបានគេចាត់ទុកថាជាខ្មាំង ឬពួកក្បត់ជាតិ និងក្បត់បក្ស ។ ដោយសារផែនការទាំងនេះត្រូវបានពិចារណាថាចាំបាច់ណាស់ ដើម្បីធ្វើឲ្យប្រទេសកម្ពុជាហ្នឹងក្លាយទៅជារបបសង្គមនិយមមួយដ៏ខ្លាំង ឯករាជ្យចេញពីពួកចក្រពត្តិ និងវៀតណាម ។ ទី៤) អ្នកណាម្នាក់ដែលត្រូវបានគេចោទប្រកាន់ថា ជាខ្មាំង ឬជាពួកក្បត់ អាចត្រូវបានចាប់ខ្លួនដោយសន្តិសុខ ធ្វើទារុណកម្ម បង្ខំសួរចម្លើយ ដើម្បីឆ្លើយដាក់អ្នកដទៃទៀត ហើយក្រោយមកត្រូវបានគេសម្លាប់ចោល ។ សិទ្ធិអំណាចក្នុងការចាប់ខ្លួន ធ្វើទារុណកម្ម និងសម្លាប់ គឺកើតមានជាផ្លូវការ ឬមិនផ្លូវការពីមជ្ឈិមចុះ រហូតទៅដល់ភូមិភាគ ថ្នាក់តំបន់ និងថ្នាក់ស្រុក រហូតធ្លាក់ទៅដល់ថ្នាក់សហករណ៍ឯណោះ និងក្នុងចំណោមជួរកងទ័ព ។ ហើយការប្រើប្រាស់ការធ្វើទារុណកម្មនេះ ត្រូវបានបង្កើតឡើងតាមរបៀបរបបច្រើន ដោយយោងទៅលើចំនួនខ្មាំង ។ ហើយនៅក្នុងពេលជាមួយគ្នានេះ ការខកខានខាងផ្នែកយោធា និងនយោបាយរបស់បដិវត្តន៍បណ្តាលឲ្យមានមនុស្សស្លាប់យ៉ាងច្រើន ហើយមានការចោទប្រកាន់ច្រើនឡើងថា មានការក្បត់នៅក្នុងជួរបក្ស ដែលនាំឲ្យកើតមាននូវអំពើប្រល័យពូជសាសន៍ ។ បើទោះណា ជាមិនមានផែនការបែបនេះក៏ដោយ"* ។ ស៊ីវ ហេងឌ័រ បានបញ្ជាក់ថា អៀង សារី ពិតជាបានឆ្លើយដូចអ្វីដែលគាត់បានកត់ត្រាទាំងនេះប្រាកដមែន ។

គួរបញ្ជាក់ថា នៅក្នុងកិច្ចសម្ភាសន៍នេះដែរ អៀង សារី បានប្រាប់ ស៊ីវ ហេងឌ័រ ថា នៅខែកញ្ញា ឆ្នាំ១៩៧៥ គណៈអចិន្ត្រៃយ៍របស់បក្សកុម្មុយនីស្តកម្ពុជាបានជួបប្រជុំដោយមានសមាសភាពចូលរួមដូចជា ប៉ុល ពត, នួន ជា, សោ ភឹម, តាម៉ុក, វន វេត, រូបគាត់ផ្ទាល់ (អៀង សារី) ដែលសុទ្ធសឹងជាសមាជិកគណៈអចិន្ត្រៃយ៍ ។ ក្រៅពីនេះមាន ខៀវ សំផន, រស់ ញឹម, កុយ ធួន និងមេទ័ពមួយចំនួនទៀតដែលមិនទាន់ក្លាយជាសមាជិករបស់គណៈអចិន្ត្រៃយ៍នៅឡើយ ក៏ចូលរួមក្នុងកិច្ចប្រជុំនេះដែរ ។ នៅក្នុងកិច្ចប្រជុំនោះបានសម្រេចថា "ត្រូវធ្វើយ៉ាងណាកុំឲ្យវៀតណាមមកត្រួតត្រាកម្ពុជា" ។ គួរបញ្ជាក់ថា ទាក់ទងនឹងកិច្ចប្រជុំនេះ តំណាងសហព្រះរាជអាជ្ញា ឃីត វិន័រ ពុំបានសួរលម្អិតតទៅទៀតឡើយ ។

### ៣) ការសួរដេញដោលសាក្សីដោយមេធាវីដើមបណ្តឹងរដ្ឋប្បវេណី

បន្ទាប់ពីបញ្ចប់ការសួរដេញដោលដោយតំណាងសហព្រះរាជអាជ្ញា អង្គជំនុំជម្រះបានផ្តល់វេទិកា ជូនក្រុមមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីបន្តសួរសាក្សី ស៊ីវ ហេងឌ័រ ។ ក្នុងការសួរដេញដោលរបស់សហមេធាវីអន្តរជាតិនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី អេលីហ្សាបេត ស៊ីម៉ុនណូហូត ផ្តោតសំខាន់អំពីការជម្លៀសប្រជាជនក្នុងដំណាក់កាលទី១ (ជម្លៀសចេញពីភ្នំពេញថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥) និងជម្លៀសប្រជាជនដំណាក់កាលទី២ (ជម្លៀសពីតំបន់មួយ ទៅតំបន់មួយទៀត នៅក្នុង

របបកម្ពុជាប្រជាធិបតេយ្យ) ។ វិធីសាស្ត្រក្នុងការសួរដេញដោលមេធាវី ស៊ីម៉ុនណូហុត ធ្វើការដកស្រង់ ដោយអានឡើងវិញនូវសក្ខីកម្មរបស់សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួនហើយ ចោទសួរ ស៊ីវ ហេដឌ័រ ថាធ្លាប់បានដឹង ឬមានបទសម្ភាសន៍ណាដែលមានព័ត៌មានប្រដៀងគ្នាទៅនិងសក្ខីកម្មដែលបានដកស្រង់នោះដែរឬទេ ។ គួរបញ្ជាក់ថា ក្នុងការប្រើប្រាស់វិធីសាស្ត្រចោទសំណួរនេះ ទទួលរងការជំទាស់ពីមេធាវីអន្តរជាតិ វិចទ័រ កូប៉េ ដោយផ្តល់សំអាងថា មេធាវី ស៊ីម៉ុនណូហុត ប្រើប្រាស់សំណួរនាំមុខក្នុងការសាកសួរសាក្សី ។ មេធាវី ស៊ីម៉ុនណូហុត បានឆ្លើយតបថា ក្រុមមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានប្រើប្រាស់វិធីសាស្ត្រនេះជាយូរមកហើយក្នុងការសួរដេញដោលសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីផ្សេងៗទៀត ហើយពុំដែលមានការជំទាស់ពីក្រុមមេធាវីការពារក្តីឡើយ ។ ជាលទ្ធផលអង្គជំនុំជម្រះសម្រេចថា ការជំទាស់របស់មេធាវីការពារក្តី នួន ជា ពុំមានសុពលភាព ហើយអនុញ្ញាតឲ្យមេធាវី ស៊ីម៉ុន ណូហុត បន្តអនុវត្តវិធីសាស្ត្រនេះក្នុងការសួរដេញដោលសាក្សី ស៊ីវ ហេដឌ័រ ។

តាមសក្ខីកម្មរបស់ ស៊ីវ ហេដឌ័រ បានបញ្ជាក់ថា មានបទសម្ភាសន៍ជាច្រើនដែលបានរៀបរាប់ព្រឹត្តិការណ៍នៃការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ មានលក្ខណៈស្រដៀងគ្នាទៅនឹងសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សីផ្សេងៗទៀតដែលលើកឡើងដោយមេធាវី ស៊ីម៉ុនណូហុត ។ ដូចគ្នា ភាគច្រើនត្រង់ការបង្ខំឲ្យប្រជាជនចេញពីលំនៅដ្ឋានបន្ទាប់ពីខ្មែរក្រហមចូលកាន់កាប់ទីក្រុងភ្នំពេញ ។ នៅក្នុងសក្ខីកម្មដែលមេធាវី ស៊ីម៉ុនណូហុត លើកឡើងបានបញ្ជាក់ថា បន្ទាប់ពីយោធាខ្មែរក្រហមចូលកាន់កាប់ទីក្រុងភ្នំពេញ យោធាទាំងនោះ បានដើរស្រែកប្រកាសឲ្យប្រជាជនចាកចេញពីផ្ទះជាប្រញាប់ ដើម្បីគេចពីការទម្លាក់គ្រាប់បែករបស់សហរដ្ឋអាមេរិក និងដើម្បីឲ្យអង្គការអាចរៀបចំទីក្រុងឲ្យមានរបៀបរៀបរយ ។ សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីមួយរូបទៀតបានបញ្ជាក់ថា គាត់បានឃើញយោធាខ្មែរក្រហមបាញ់សម្លាប់ប្រជាជនចំនួន២-៣ នៅជិតផ្សារដើមគរ ដោយសារប្រជាជនទាំងនោះរឹងទទឹងមិនព្រមចាកចេញពីផ្ទះ ។ សក្ខីកម្មរបស់ដើមបណ្តឹងមួយរូបទៀតបានបញ្ជាក់ថា ប្រជាជនដែលជម្លៀស


កងទ័ពខ្មែរក្រហមធ្វើដំណើរទៅសមរភូមិ ក្នុងទសវត្សរ៍ឆ្នាំ៨០ ថតដោយ ជេ ខូសម៉ាន់ (រូបថតមជ្ឈមណ្ឌលឯកសារកម្ពុជា)

ចេញពីទីក្រុងភ្នំពេញ ត្រូវបានគេហៅថាប្រជាជនថ្មី ។ ប្រជាជនថ្មីមានសិទ្ធិតិចតួចជាងប្រជាជនចាស់ (ប្រជាជនមូលដ្ឋាន) ។ ប្រជាជនចាស់ទទួលបានរបបអាហារ និងសិទ្ធិសេរីភាពប្រសើរជាងប្រជាជនថ្មី ។ ប្រជាជនថ្មីត្រូវបានដាក់ឲ្យធ្វើការធ្ងន់ធ្ងរ ប៉ុន្តែទទួលបានរបបអាហារតិចតួច ។ ដូច្នេះត្រូវស្វែងរកចាប់សត្វល្អិត គីង្កក់ កង្កែបហូបបន្ថែម ហើយមានពេលខ្លះដណ្ដើមយកបាយដែលគេដាក់ឲ្យសត្វឆ្កែយកមកបរិភោគ ។ ដើមបណ្ដឹងរដ្ឋប្បវេណីជាច្រើនរូបទៀតបានរៀបរាប់អំពីព្រឹត្តិការណ៍អមនុស្សធម៌ដែលបានកើតឡើងក្នុងអំឡុងពេលជម្លៀសប្រជាជនរាប់លាននាក់ចេញពីក្រុងភ្នំពេញ ដែលអ្នកជំងឺ មនុស្សចាស់ជរា ត្រូវបានបង្ខំឲ្យធ្វើដំណើរនៅក្រោមកំដៅថ្ងៃ ។ មនុស្សជាច្រើននាក់បានស្លាប់ និងសម្លាប់នៅតាមផ្លូវ ។

ទាក់ទងនឹងការជម្លៀសប្រជាជននៅតំណាក់កាលទី២ ស៊ីវ ហេងឌ័រ បានផ្ដល់សក្ខីកម្មថា មានបទសម្ភាសន៍ជាច្រើនដែលគាត់ធ្វើជាមួយប្រជាជនខ្មែរដែលភៀសខ្លួនទៅព្រំដែនថៃក្នុងឆ្នាំ១៩៧៨ បញ្ជាក់ថា ប្រជាជនត្រូវបានជម្លៀសពីភូមិភាគមួយទៅភូមិភាគមួយទៀត ។ ប្រជាជនទាំងនោះត្រូវបានដឹកតាមរថយន្ត និងតាមទូរថភ្លើង ដែលមានសភាពណែនណាន់តាន់តាប់ ដោយមានយោធាខ្មែរក្រហមប្រដាប់ ដោយអាវុធនៅយាមជាប់រហូត ។ សុខភាពប្រជាជនមានការធ្លាក់ចុះទ្រុឌទ្រោមជាខ្លាំងដោយសារលក្ខខណ្ឌនៃការដឹកជញ្ជូន ខ្វះម្ហូបអាហារ ការងារ និងការរស់នៅក្នុងតំបន់ថ្មី ។ លក្ខខណ្ឌទាំងនេះធ្វើឲ្យប្រជាជនស្លាប់ជាច្រើន ។

ក្រៅពីសួរដេញដោលអំពីការជម្លៀសប្រជាជនដំណាក់កាលទី១ និង ទី២ មេធាវី ស៊ីម៉ុនណូហ្វូត សួរសំណួរមួយចំនួនទាក់ទងនឹងស្ថានភាពរស់នៅរបស់ជាជនក្នុងតំបន់រំដោះចន្លោះឆ្នាំ១៩៧-១៩៧៥ ជារយៈពេលដែល ស៊ីវ ហេងឌ័រ រស់នៅក្នុងប្រទេសកម្ពុជា ។ ជាការឆ្លើយតប ស៊ីវ ហេងឌ័រ បញ្ជាក់ថា ក្នុងអំឡុងពេលនោះគាត់ទទួលបានព័ត៌មានតិចតួចបំផុតទាក់ទងនឹងតំបន់រំដោះរបស់ខ្មែរក្រហម ។ គាត់បានព្យាយាមរកព័ត៌មានទាក់ទងនឹងការបង្កើតសហករណ៍ ការបង្កបង្កើនផល រចនាសម្ព័ន្ធនៃការចាត់តាំងជាដើម ។ គាត់បានព្យាយាមទៅដល់តំបន់រំដោះនៅ ខេត្តកំពង់ចាម បាត់ដំបង ដើម្បីទៅយកព័ត៌មាន ប៉ុន្តែទទួលបានព័ត៌មានតិចតួចតែប៉ុណ្ណោះ ។

បន្ទាប់ពីមេធាវី ស៊ីម៉ុនណូហ្វូត បញ្ចប់សំណួររបស់ខ្លួន មេធាវីឡោ ជុនធី បានបន្តចោទសំណួរមួយចំនួនទាក់ទងនឹងកិច្ចប្រជុំនៅសាលាបច្ចេកទេសមិត្តភាពកម្ពុជា-សូវៀត ។ ឆ្លើយតបនឹងសំណួរទាំងនោះ ស៊ីវ ហេងឌ័រ បានបញ្ជាក់ថា កិច្ចប្រជុំនេះធ្វើឡើងក្នុងឆ្នាំ១៩៧៥ ដោយមានការចូលរួមពីកម្មាភិបាលទាំងអស់នៅទូទាំងប្រទេស ។ កិច្ចប្រជុំនេះធ្វើឡើងក្នុងគោលបំណងផ្សព្វផ្សាយគោលនយោបាយនានារបស់បក្សកុម្មុយនីស្តកម្ពុជា ។ គោលនយោបាយទាំងនោះរួមមាន ការជម្លៀសប្រជាជន ការលុបបំបាត់ការចាយលុយ ការស្វែងរក និងសម្លាប់អតីតអ្នកមន្ត្រីរដ្ឋការ និងទាហានរបស់របប លន់ នល់ និងគោលនយោបាយទាក់ទងនឹងព្រះសង្ឃកាន់ពុទ្ធសាសនាជាដើម ។

ឆ្លើយតបនឹងសំណួរចុងក្រោយរបស់មេធាវី ឡោ ជុនធី ពាក់ព័ន្ធនឹងប្រព័ន្ធទំនាក់ទំនងការងារ ស៊ីវ ហេងឌ័រ បញ្ជាក់ថា មធ្យោបាយក្នុងការធ្វើទំនាក់ទំនងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យមានបី ។ ទី១) តាមរយៈសារទូរលេខៈ ថ្នាក់ដឹកនាំបក្ស និងកម្មាភិបាលថ្នាក់ក្រោមផ្ញើសារទូរលេខទាក់ទងគ្នាទៅវិញទៅមក ។ ទី២) តាមរយៈរបាយការណ៍ ៈ ថ្នាក់ក្រោមធ្វើរបាយការណ៍ជាលាយលក្ខណ៍អក្សរដើម្បីរាយការណ៍ទៅថ្នាក់លើ និងទី៣) តាមរយៈកិច្ចប្រជុំផ្ទាល់ ដែលព័ត៌មានផ្សេងៗត្រូវបានចែករំលែក ឬរាយការណ៍នៅក្នុងកិច្ចប្រជុំតែម្ដង ។

### ៤) ការសួរដេញដោលសាក្សីដោយក្រុមមេធាវីការពារក្ដី នួន ជា

#### ក) អំពីគុណវុឌ្ឍិរបស់សាក្សី ស៊ីវ ហេងឌ័រ

មុននឹងចូលទៅដល់ការសួរដេញដោលអំពីអង្គហេតុដែលត្រូវបានកំណត់ដោយអង្គជំនុំជម្រះ លោក វិចទ័រ កូប៉េ ជាសហមេធាវីអន្តរជាតិការពារក្ដីជនជាប់ចោទ នួន ជា បានចោទសំណួរមួយចំនួនទាក់ទងនឹងមូលហេតុដែលជំរុញឲ្យ ស៊ីវ ហេងឌ័រ សម្រេចចិត្តមិនផ្ដល់សក្ខីកម្មក្នុងឋានៈជាសាក្សីជំនាញ ។ ឆ្លើយតបទៅនឹងសំណួរទាំងនោះ ស៊ីវ ហេងឌ័រ បញ្ជាក់ថា ពេលគាត់បម្រើការនៅការិយាល័យសហចៅក្រមស៊ើបអង្កេត សហចៅក្រមស៊ើបអង្កេត ឡឺម៉ុងដ៍ បានចាត់ទុក ស៊ីវ ហេងឌ័រ ជាអ្នកជំនាញ ។ ប៉ុន្តែសម្រាប់រូបគាត់ផ្ទាល់ពុំគិតដូច្នេះឡើយ ។ មានហេតុផលចំនួន

៣ ដែល ស៊ីវ ហេដឌ័រ សម្រេចចិត្តមិនផ្តល់សក្ខីកម្មក្នុងនាមជា សាក្សីជំនាញ ។ ហេតុផលទី១ ស៊ីវ ហេដឌ័រ បញ្ជាក់ថា ក្នុងនាមជា អ្នកជំនាញត្រូវមានការសិក្សាស្រាវជ្រាវ បន្ទាប់មកត្រូវសរសេរ និងបោះពុម្ពជាសៀវភៅបន្ទាប់ពីមានការត្រួតពិនិត្យម្តងហើយម្តង ទៀត ។ សៀវភៅនោះនឹងត្រូវចំណាយពេលជាច្រើនខែក្នុងការ បោះពុម្ព បន្ទាប់មកត្រូវការពារទៅនឹងការសួរដេញដោលទៅលើ ខ្លឹមសារដែលបានសរសេរនៅក្នុងសៀវភៅនោះ ។ ហេតុផលទី២ ស៊ីវ ហេដឌ័រ បញ្ជាក់ថា ប្រសិនបើសម្រេចចិត្តសរសេររបាយ ការណ៍ដូចអ្នកជំនាញនោះ សាក្សីនឹងត្រូវចំណាយពេលជាច្រើន ដើម្បីបញ្ចប់របាយការណ៍នោះ ។ ហេតុទី៣ ស៊ីវ ហេដឌ័រ ឈប់ ផ្តោតការយកចិត្តទុកដាក់ទៅលើសាលាក្តីខ្មែរក្រហមចាប់តាំងពីឆ្នាំ ២០១១ មកម្ល៉េះ ហើយក៏មិនចង់គិតពីរឿងខ្មែរក្រហមទៀត ដែរ ។ ស៊ីវ ហេដឌ័រ មានបំណងសិក្សាស្រាវជ្រាវអំពីបញ្ហា ផ្សេងទៀត ជាពិសេសពាក់ព័ន្ធនឹងគោលនយោបាយរបស់បណ្តា ប្រទេសអាស៊ីអាគ្នេយ៍ ។ គួរបញ្ជាក់ថា ការសួរដេញទៅលើបញ្ហា ទាំងនេះ ត្រូវបានអង្គជំនុំជម្រះសម្រេចឲ្យបញ្ចប់ ដោយផ្តល់ហេតុ ផលថា សំណួរចម្លើយទាំងនោះស្ថិតនៅក្រៅវិសាលភាពនៃអង្គ ហេតុដែលអង្គជំនុំជម្រះចង់ស្តាប់ ។ មេធាវី វិចទ័រ កូប៉េ ធ្វើការកត់ សម្គាល់ថា ហេតុផលដែលគាត់សួរនាំអំពីបញ្ហាទាំងនេះ ក្នុងគោល បំណងបញ្ជាក់ភាពអាចទុកចិត្តបានរបស់សាក្សី ស៊ីវ ហេដឌ័រ ។ សំណួរចុងក្រោយពាក់ព័ន្ធនឹងបញ្ហានេះ មេធាវី វិចទ័រ កូប៉េ ចោទ សួរថា ហេតុអ្វីបានជាសាស្ត្រាចារ្យ ប៉ែន ឃៀនិន ហៅ ស៊ីវ ហេដឌ័រ ថា ជាភ្នាក់ងារសម្ងាត់? ស៊ីវ ហេដឌ័រ បានបកស្រាយថា "...គឺ ដោយសារតែមូលដ្ឋាននៃការយល់ច្រឡំទំនាក់ទំនងរវាងខ្ញុំ និង ដាយអាណា ដែលខ្ញុំបានពន្យល់ហើយថា វាជាការយល់ច្រឡំរវាង កិច្ចសន្យាដែលកំណត់ខ្ញុំនោះថា ជានិយោជករបស់សហរដ្ឋអាមេ- រិក ។ ក៏ដូចជាយល់ច្រឡំរវាងការបានមូលនិធិពីស្ថានទូតអង់គ្លេស ក៏ដូចជាយូនីស្កូ ដែលបានពីប្រទេសថៃ ដែលរដ្ឋាភិបាលថៃគេផ្តល់ កិច្ចសន្យាមកឲ្យខ្ញុំ ។ ដូចខ្ញុំបានជម្រាប ហើយទាក់ទងទៅនឹងកិច្ចការ របស់ខ្ញុំនេះ កិច្ចសន្យាដែលខ្ញុំបានទទួលនេះ គឺខ្ញុំប្រមូលព័ត៌មាន សម្ងាត់ និងវិភាគព័ត៌មានសម្ងាត់មែន ។ ប៉ុន្តែគេអាចអ្នកខ្លះៗ កាលណាឃើញការងារបែបនេះ អាចនិយាយថា ជាភ្នាក់ងារ សម្ងាត់ហើយ" ។ គួរបញ្ជាក់ថា ពាក់ព័ន្ធនឹងចំណុចនេះ ស៊ីវ ហេដឌ័រ ធ្លាប់បានផ្តល់សក្ខីកម្មថា គាត់ទទួលបានមូលនិធិពីរដ្ឋាភិបាលសហ រដ្ឋអាមេរិក (តាមរយៈក្រសួងការពារជាតិ) រដ្ឋាភិបាលប្រទេស អង់គ្លេសនិងរដ្ឋាភិបាលថៃ ដើម្បីធ្វើការសិក្សាស្រាវជ្រាវឯកសារ នៅមជ្ឈមណ្ឌលឯកសារកម្ពុជា ។

នៅក្នុងអំឡុងពេលនៃការសួរដេញដោលអំពីគុណវុឌ្ឍិរបស់ ស៊ីវ ហេដឌ័រ នេះដែរ មេធាវី វិចទ័រ កូប៉េ បានផ្តល់ការកត់សម្គាល់ ថា សៀវភៅ និងអត្ថបទជាច្រើនរបស់ ស៊ីវ ហេដឌ័រ ភាគច្រើនពាក់ ព័ន្ធទៅនឹងគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ។ ប៉ុន្តែ



នួន ជា (រូបថតមជ្ឈមណ្ឌលឯកសារកម្ពុជា)

ស៊ីវ ហេដឌ័រ ពុំធ្លាប់ដែលជួបសម្ភាសន៍ជាមួយ ប៉ុល ពត, នួន ជា, ឈិត ជឿន ហៅ ម៉ុក, សុន សេន, វ៉ន វ៉េត, សោ ភឹម ឬ រស់ ញឹម ឡើយ ។ ស៊ីវ ហេដឌ័រ ផ្តល់ការបដិសេធភ្លាមចំពោះការលើកឡើង នេះ ដោយបញ្ជាក់ថាការលើកឡើងរបស់មេធាវី វិចទ័រ កូប៉េ ជាការពុំត្រឹមត្រូវ ។ ស៊ីវ ហេដឌ័រ អះអាងថា គាត់ធ្លាប់បានជួប សុន សេន, តាម៉ុក និង នួន ជា ។ ទោះបីជាយ៉ាងណា ស៊ីវ ហេដឌ័រ បានទទួលស្គាល់ថា គាត់ពុំបានសម្ភាសន៍ អ្នកទាំងនោះឲ្យបាន ល្អិតល្អន់ឡើយ ។

ទាក់ទងទៅនឹងគុណវុឌ្ឍិរបស់ ស៊ីវ ហេដឌ័រ នេះដែរ មេធាវី

រិចឆ័រ កូប៉េ បានចោទសំណួរមួយចំនួនទាក់ទងទៅនឹងការបំពេញការងាររបស់សាក្សីរូបនេះ នៅក្នុងការិយាល័យសហព្រះរាជអាជ្ញា និងការិយាល័យសហចៅក្រមស៊ើបអង្កេត ។ ក្នុងការសួរដេញដោលលើប្រធានបទនេះ បានបង្កឲ្យមានភាពចម្រូងចម្រាស់ខ្លាំង ដោយសារសំណួររបស់មេធាវីការពារក្តីភាគច្រើនត្រូវបានតំណាងសហព្រះរាជអាជ្ញាជំទាស់ ។ មុនដំបូងមេធាវី រិចឆ័រ កូប៉េ ផ្តល់ការបញ្ជាក់ថា ដើមឡើយបម្រើការងារនៅការិយាល័យសហចៅក្រមស៊ើបអង្កេតបន្ទាប់មកត្រូវបានបញ្ជូនឲ្យមកបម្រើការងារនៅការិយាល័យសហព្រះរាជអាជ្ញា ហើយចុងក្រោយត្រឡប់ទៅ



រិចឆ័រ កូប៉េ (រូបថតមជ្ឈមណ្ឌលឯកសារកម្ពុជា)

ការិយាល័យចៅក្រមស៊ើបអង្កេតវិញ ។ បន្ទាប់មកមេធាវីចោទសំណួរថា តើការដែល ស៊ីវ ហេងឌ័រ ធ្វើការងារនៅក្នុងការិយាល័យទាំងពីរនេះមានទំនាស់ផលប្រយោជន៍ដែរឬទេ? ហើយនៅពេលដែល ស៊ីវ ហេងឌ័រ បម្រើការងារនៅការិយាល័យចៅក្រមស៊ើបអង្កេត «តើចៅក្រម ឡឺម៉ុងដឺ ដែលស្នើឲ្យស្វែងរកតែភ័ស្តុតាងដាក់បន្ទុក ដោយមិនឲ្យរកភ័ស្តុតាងដោះបន្ទុកដែរឬទេ?» ។ ទោះបីជាយ៉ាងណា សំណួរទាំងនេះពុំត្រូវបានអង្គជំនុំជម្រះអនុញ្ញាតឲ្យស៊ីវ ហេងឌ័រ ឆ្លើយតបឡើយ ដោយផ្តល់ហេតុផលថា សំណួរទាំងនោះស្ថិតនៅក្រៅវិសាលភាពនៃអង្គហេតុដែលត្រូវជំនុំជម្រះ ។ អង្គជំនុំជម្រះបញ្ជាក់បន្ថែមថា អង្គបុរេជំនុំជម្រះបានដោះស្រាយរួចរាល់ហើយ ពាក់ព័ន្ធនឹងបញ្ហាទំនាស់ផលប្រយោជន៍ដូចដែលមេធាវីចោទសួរ ។

បន្ទាប់ពីទទួលបានការណែនាំរបស់អង្គជំនុំជម្រះដូចបានបញ្ជាក់ខាងលើមេធាវី រិចឆ័រ កូប៉េ ចាប់ផ្តើមសួរទាក់ទងនឹងបទសម្ភាសន៍ដែល ស៊ីវ ហេងឌ័រ បានសម្ភាស កែ ពក នៅថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០១ ក្នុងខេត្តសៀមរាប ។ គួរបញ្ជាក់ថា ដើម្បីទទួលបានការយល់ព្រមផ្តល់បទសម្ភាសន៍ពី កែ ពក សាក្សី ស៊ីវ ហេងឌ័រ បានសន្យាថា ឯកសារបទសម្ភាសន៍នេះនឹងមិនដាក់បង្ហាញជាសាធារណៈឡើយ ដរាបណា កែ ពក នៅមានជីវិត ព្រោះព័ត៌មានដែល កែ ពក បានផ្តល់ជូននោះ ភាគច្រើនជាព័ត៌មាន ដែលដាក់បន្ទុកលើខ្លួនឯង (កែ ពក) និងអ្នកផ្សេងៗទៀត ។ នៅក្នុងបទសម្ភាសន៍នេះ កែ ពក បានបញ្ជាក់ថា ក្នុងនាមជាលេខាភូមិភាគឧត្តរ គាត់បានអនុវត្តគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ក្នុងការសម្លាប់មន្ត្រីរបបសាធារណរដ្ឋខ្មែរ ក្រោមការណែនាំរបស់ នួន ជា ។ មន្ត្រីរបប លន់ នល់ ត្រូវបានចាប់ខ្លួន និងសម្លាប់ចោលបន្ទាប់ពីសួរចម្លើយរួច ។ កម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជាជាច្រើនទៀត ក៏ត្រូវបានចាប់ខ្លួន ដោយទទួលរងការចោទប្រកាន់ថាជាជនក្បត់ ។ កម្មាភិបាលទាំងនោះត្រូវបានបញ្ជូនយកទៅសួរចម្លើយនៅមន្ទីរសន្តិសុខស-២១ បន្ទាប់មកយកទៅសម្លាប់ចោល ។ កែ ពក បានលើកឡើងថា នួន ជា ក៏បានជួយជ្រោមជ្រែងក្នុងការចាប់ខ្លួនកម្មាភិបាលទាំងនេះដែរ ។ ស៊ីវ ហេងឌ័រ បានបញ្ជាក់បន្ថែមថា ក្រៅពីសក្ខីកម្មរបស់ កែ ពក មានភ័ស្តុតាងជាច្រើនទៀតដែលបង្ហាញថា នួន ជា មានការជាប់ពាក់ព័ន្ធនឹងគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជាក្នុងការកាប់សម្លាប់មន្ត្រីរបប លន់ នល់ ។

ទាក់ទងនឹងកិច្ចសម្ភាស៍ជាមួយ អៀង សារី មេធាវី រិចឆ័រ កូប៉េ បានចោទសំណួរបឋមមួយចំនួន ដោយស្នើឲ្យ ស៊ីវ ហេងឌ័រ ពន្យល់អំពីរបៀបដែលគាត់អាចទទួលបានការផ្តល់បទសម្ភាសន៍ពី អៀង សារី ។ ស៊ីវ ហេងឌ័រ បានផ្តល់ការយល់ឃើញថា ការដែល អៀង សារី យល់ព្រមផ្តល់បទសម្ភាសន៍នេះ ដោយសារ អៀង សារី ចង់បង្ហាញថា ខ្លួនពុំមែនជាបងធំទី២ ដូចការអះអាងរបស់

សាស្ត្រាចារ្យ ប៉ែន យៀនិន ឡើយ ពោលគឺ នួន ជា ទើបជាបងធំទី២ ។ គួរបញ្ជាក់ថា តាមការផ្តល់សក្ខីកម្មរបស់ ស៊ីវ ហេងឌ័រ មានការខ្វែងគំនិតគ្នារវាងសាស្ត្រាចារ្យ ប៉ែន យៀនិន និង ស៊ីវ ហេងឌ័រ ក្នុងការកំណត់ឋានៈរបស់ អៀង សារី ។ សាស្ត្រាចារ្យ ប៉ែន យៀនិន ធ្លាប់បានកំណត់និងហៅ អៀង សារី ថា ជាបងធំទី២ ។ សម្រាប់ ស៊ីវ ហេងឌ័រ ពុំបានរកឃើញដូច្នេះឡើយ ។ ស៊ីវ ហេងឌ័រ អះអាងថា នួន ជា ទើបជាបងធំទី២ នៃបក្សកុម្មុយនីស្តកម្ពុជា ។ ស៊ីវ ហេងឌ័រ បានបញ្ជាក់បន្ថែមថា រហូតមកដល់ពេលបច្ចុប្បន្ន នួន ជា ត្រូវបានទទួលស្គាល់ថា ជាបងធំទី២ ពុំមែនជា អៀង សារី ទៀតឡើយ ។

ទាក់ទងនឹងកិច្ចសម្ភាសន៍នេះដែរ មេធាវី វិចទ័រ កូប៉េ ស្នើឲ្យ ស៊ីវ ហេងឌ័រ ផ្តល់ការបញ្ជាក់ថាតើមានផ្នែកណាមួយនៃកំណត់ហេតុនេះដែល អៀង សារី បានផ្តល់ចម្លើយដោយភូតកុហកដែរឬទេ? ប៉ុន្តែសំណួរនេះត្រូវបានតំណាងសហព្រះរាជអាជ្ញា ឃីត វ៉ែន័រ ធ្វើការជំទាស់ភ្លាមៗ ដោយផ្តល់ហេតុផលថា "...លោក ស៊ីវ ហេងឌ័រ គាត់ជាសាក្សី គាត់មិនអាចសម្រេចបាន ឬក៏មិនអាចឆ្លើយបានថា តើផ្នែកណាមួយដែល អៀង សារី និយាយពិត ផ្នែកណាមួយដែល អៀង សារី និយាយកុហកនោះទេ វាមិនអាចទេ ។ ទោះបីថាលោក អៀង សារី និយាយពិត ឬមិនពិតក៏ដោយ វាជាបញ្ហារបស់អង្គជំនុំជម្រះសាលាដំបូងជាអ្នកសម្រេច មិនមែនជាសិទ្ធិ ឬកាតព្វកិច្ចរបស់លោក ស៊ីវ ហេងឌ័រ ដែលត្រូវឲ្យគេសួរឆ្លើយបែបនេះនោះទេ" ។ សេចក្តីជំទាស់នេះត្រូវបានអង្គជំនុំជម្រះសម្រេចថាមានសុពលភាព ដោយបញ្ជាក់ថា តំណាងសហព្រះរាជអាជ្ញាផ្តល់សំអាងហេតុសមស្រប ។ ដូច្នេះអង្គជំនុំជម្រះពុំអនុញ្ញាតឲ្យសាក្សីឆ្លើយតបឡើយ ។

### ខ) អំពីមន្ទីរសន្តិសុខនៅភូមិភាគបូព៌ា

ស៊ីវ ហេងឌ័រ បានបញ្ជាក់ថានៅក្នុងភូមិភាគបូព៌ាមានរចនាសម្ព័ន្ធមន្ទីរសន្តិសុខស្រដៀងគ្នានឹងភូមិភាគផ្សេងៗទៀតដែរ ។ មន្ទីរសន្តិសុខរបស់ភូមិភាគនេះហៅថា មន្ទីរសន្តិសុខស-៧៩ មានទីតាំងនៅក្នុងទីរួមខេត្តព្រៃវែង ។ មន្ទីរសន្តិសុខនេះស្ថិតនៅក្រោមការគ្រប់គ្រងរបស់សេនាធិការរបស់ភូមិភាគ ហើយត្រូវបានប្រើប្រាស់សម្រាប់ឃុំខ្លួនកម្មាភិបាលរបស់ភូមិភាគបូព៌ា ។ ក្រៅពីមន្ទីរសន្តិសុខស-៧៩ មានមន្ទីរសន្តិសុខជាច្រើនទៀតត្រូវបានបង្កើតឡើងនៅតាមតំបន់ និងស្រុក ដែលរចនាសម្ព័ន្ធនេះមានលក្ខណៈស្មើរដូចគ្នានៅទូទាំងប្រទេស ។ មន្ទីរសន្តិសុខទាំងនោះភាគច្រើនប្រើសម្រាប់ឃុំឃាំងប្រជាជនសាមញ្ញ ។ ស៊ីវ ហេងឌ័រ បានអះអាងថា សេចក្តីសម្រេចក្នុងការសម្លាប់ប្រជាជនភាគច្រើនធ្វើត្រឹមថ្នាក់ស្រុក ។ ប៉ុន្តែមានករណីខ្លះត្រូវមានការអនុញ្ញាតពីថ្នាក់តំបន់ ។ ចំណែកនៅក្រោមស្រុកនីមួយៗ មានសហករណ៍នៅតាមឃុំ ដែលក្នុងនោះមានកងឈ្លបជាអ្នកមានតួនាទីចាប់ខ្លួនប្រជាជន ។

ស៊ីវ ហេងឌ័រ បានបញ្ជាក់បន្ថែមថា ការសម្លាប់ប្រជាជននៅតាមភូមិត្រូវបានធ្វើឡើងដោយស្របតាមគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ព្រោះការកាប់សម្លាប់ទាំងនោះធ្វើឡើងដោយហេតុផលដូចគ្នា ដំណើរការដូចគ្នា ហើយត្រូវបានអនុវត្តនៅទូទាំងប្រទេស ។

### គ) អំពើប្រល័យពូជសាសន៍លើជនជាតិវៀតណាម

ទាក់ទងនឹងប្រធានបទនេះ មេធាវី វិចទ័រ កូប៉េ បានដាក់បង្ហាញសៀវភៅរបស់ ស៊ីវ ហេងឌ័រ មានចំណងជើងថា "ការវាយតម្លៃឡើងវិញអំពីតួនាទីរបស់មេដឹកនាំខ្មែរក្រហម និងកម្មាភិបាលនៅថ្នាក់មូលដ្ឋាន អំពីឧក្រិដ្ឋកម្មរបស់ខ្មែរក្រហម" ដើម្បីសួរដេញដោល ។ មេធាវីដកស្រង់ខ្លឹមសារនៅក្នុងសៀវភៅ នោះដែលបានសរសេរថា "ភស្តុតាងផ្សេងៗជាប់ពាក់ព័ន្ធនឹង ហេង សំរិន ហើយនឹងឧក្រិដ្ឋកម្មសង្គ្រាម ក្នុងការសម្លាប់ជនស៊ីវិលដែលបានប្រព្រឹត្តឡើងក្រោមការបញ្ជារបស់គាត់ ក្នុងពេលឆ្លងព្រំដែនចូលទៅប្រទេសវៀតណាមនៅក្នុងឆ្នាំ១៩៧៧" ។ ស៊ីវ ហេងឌ័រ បញ្ជាក់ថាខ្លឹមសារទាំងនេះបានយោងទៅលើសៀវភៅ និងឯកសារផ្សេងៗទៀតដែលគាត់មាន ។ ស៊ីវ ហេងឌ័រ បានបន្ថែមថា នៅក្នុងទំព័រ៥៣ និង៥៤ នៃសៀវភៅស្តីពីការវាយតម្លៃឡើងវិញនេះ មានផ្នែកមួយទាក់ទង ទៅនឹងវៀតណាម ដែលបានបញ្ជាក់ថា អង្គភាពយោធាដែលពាក់ព័ន្ធការប្រព្រឹត្តអំពើប្រល័យពូជសាសន៍ទៅលើជនជាតិវៀតណាម ស្ថិតនៅក្រោមការបញ្ជា និងការទទួលខុសត្រូវរបស់ ហេង សំរិន ។

ពាក់ព័ន្ធនឹងសម្តេច ហេង សំរិន ដែរ មេធាវី វិចទ័រ កូប៉េ

បានដកស្រង់ខ្លឹមសារសៀវភៅដដែលនេះ ដែលបានបញ្ជាក់ថា "ហេង សំរិន ត្រូវបានបញ្ជាឲ្យបញ្ជូនកងទ័ពរបស់គាត់ ដើម្បីវាយប្រយុទ្ធសម្រុកមកកាន់ទីក្រុងភ្នំពេញ ។ បាទគាត់ដឹកនាំអង្គភាពកងទ័ពភូមិភាគបូព៌ា គឺមានវរសេនាធំ៣៥, ១៦៤ ដែលត្រូវពង្រាយនៅទិសខាងកើតនៃទីក្រុងភ្នំពេញ មានកងពលរបស់ ចាន់ ចក្រី ។ ចាន់ ចក្រី ជាមេបញ្ជាការកងពល ហេង សំរិន គឺជាអនុមេបញ្ជាការកងពល ហើយក្នុងនោះក៏មាន ហេង ថាល ក៏វាយប្រយុទ្ធនៅភាគខាងកើតនៃទន្លេមេគង្គផងដែរ ។ ហើយក្នុងនោះក៏មានកងម៉ារីន ដែលស្ថិតនៅក្រោមបញ្ជាការឈ្មោះ ឈឿន ។



កងទ័ពខ្មែរក្រហមកំពង់អង្គុយមុខភ្នក់ភ្លើងដើម្បីប្រជុំនាងទសវត្សរ៍ឆ្នាំ៨០ (រូបថតមជ្ឈមណ្ឌលឯកសារកម្ពុជា)

មេបញ្ជាការកងភូមិភាគបូព៌ានេះ គឺស្លៀកឯកសណ្ឋានខុសពីកងទ័ពកុម្មុយនីស្តដទៃទៀត ហើយជាអ្នកមាននិន្នាការនិយម សីហនុ" ។ ស៊ីវ ហេងឌ័រ បានបំភ្លឺថា បងប្រុស របស់សម្តេច ហេង សំរិន ឈ្មោះ ហេង ប៉ាល់ ពុំមែនឈ្មោះ ថាល នោះទេ ។ ប៉ាល់ មានតួនាទីជាលេខាពុំមែនជាមេបញ្ជាការកងទ័ពឡើយ ។ ស៊ីវ ហេងឌ័រ បញ្ជាក់បន្ថែមថា គាត់ពុំយល់ស្របទាំងស្រុងឡើយ ដែលថាកងពលមកពីភូមិភាគមានលក្ខណៈខុសពីគេនោះ ។ កងពលរបស់ភូមិភាគនីមួយៗដែលមានតួនាទីវាយដណ្តើមយកទីក្រុងភ្នំពេញ ទទួលការចាត់តាំងយ៉ាងច្បាស់លាស់ ហើយគ្រប់គ្រងដោយអង្គភាពជាក់លាក់ ។ អង្គភាពខ្លះទទួលបន្ទុកសម្លាប់ អង្គភាពខ្លះទទួលបន្ទុកប្រមូលជ័យភណ្ឌ ហើយអង្គភាពខ្លះទៀត ត្រូវបានចាត់តាំងឲ្យល្បាតចុះឡើងៗ ។

ពាក់ព័ន្ធនឹងប្រធានបទនេះដែរ មេធាវី វិចទ័រ កូប៉េ ស្នើដាក់បង្ហាញសៀវភៅដែលនិពន្ធដោយសាស្ត្រាចារ្យ ប៉ែន ឃៀវនិន ដើម្បីឲ្យសាក្សីពន្យល់បន្ថែម ។ ប៉ុន្តែសំណើនេះពុំត្រូវបានអនុញ្ញាតឡើយ ដោយសារអង្គជំនុំជម្រះធ្លាប់បានសម្រេចថា មិនអនុញ្ញាតឲ្យយកសៀវភៅរបស់សាស្ត្រាចារ្យ ប៉ែន ឃៀវនិន មកសួរដេញដោលសាក្សី ស៊ីវ ហេងឌ័រ ឡើយ ។ អង្គជំនុំជម្រះបានរំឭកបន្ថែមថា ក្នុងករណីមេធាវី វិចទ័រ កូប៉េ ពុំមានសំណួរជាសារធាតុ ដែលមានប្រយោជន៍ដើម្បីការពារកូនក្តីខ្លួន នោះនឹងប្រគល់វេទិកាជូនក្រុមមេធាវីការពារក្តីជនជាប់ចោទ ខៀវ សំផន ដើម្បីសួរដេញដោលសាក្សី ។ ភ្លាមនោះ មេធាវី វិចទ័រ កូប៉េ បានផ្តល់ការកត់សម្គាល់ថា ព្រះរាជអាជ្ញាធ្លាប់បានចោទសំណួរមួយចំនួនទាក់ទងទៅនឹងសៀវភៅនោះ ។ បន្ទាប់ពីនេះមក មេធាវី វិចទ័រ កូប៉េ បានអានខ្លឹមសារនៅក្នុងជើងទំព័រ ទី៩៧ នៅក្នុងសៀវភៅរបស់សាស្ត្រាចារ្យ ប៉ែន ឃៀវនិន ដែលបានយោងទៅលើទៅលើការលើក ឡើងរបស់ ស៊ីវ ហេងឌ័រ ។ នៅក្នុងជើងទំព័រនេះបានបញ្ជាក់ថា "ហេងឌ័រ ដំបូងបានបញ្ជាក់ថា ភូមិភាគបូព៌ាដឹកនាំដោយ ហេង

សរិន ដែលបានបញ្ជូនឯកសារសម្ងាត់និយាយអំពីបក្សកុម្មុយនីស្ត កម្ពុជាទៅដល់វៀតណាម ។ យោងតាមលោក ហេងឌ័រ នៅក្នុងឆ្នាំ ១៩៥៩ ហេង សរិន បានជ្រៀតចូលនៅក្នុងតួនាទីបក្សកុម្មុយ នីស្តកម្ពុជា តួនាទីនេះផ្តល់ដោយវៀតណាម ។ ហើយគាត់ក៏ ឡើងឋានៈទៅតាមនោះ ។ ហេតុដូច្នេះហើយបានជាគាត់ទៅវៀត ណាម ដូច គិម ហ៊ុល ដែលបានភៀសខ្លួនទៅសហរដ្ឋអាមេរិក អ៊ីចឹងដែរ" ។ គួរបញ្ជាក់ថា ការលើកឡើងអំពីខ្លឹមសារទាំងនេះ ត្រូវបានសហមេធាវីនាំមុខជាតិតំណាង ដើមបណ្តឹងរដ្ឋប្បវេណី ពេជ អង្គ ធ្វើការជំទាស់ ដោយផ្តល់ហេតុផលថា អង្គហេតុទាំងនោះ ពុំស្ថិតនៅក្នុងវិសាលភាពនៃអង្គហេតុដែលត្រូវជំនុំជម្រះក្នុងសំណុំ រឿង ០០២/០១ ។ មេធាវី វិចទ័រ កូប៉េ បានឆ្លើយតបថា មូលហេតុដែលគាត់ដកស្រង់ខ្លឹមសារទាំងនេះមក ដើម្បីឲ្យ ស៊ីវ ហេងឌ័រ បញ្ជាក់ថា បានឬមិនបានសរសេរខ្លឹមសារទាំងនេះ ។ ជាលទ្ធផល អង្គជំនុំជម្រះសម្រេចថា ការជំទាស់របស់មេធាវី ពេជ អង្គ ពុំមានសុពលភាព និងបង្គាប់ឲ្យសាក្សីឆ្លើយតបសំណួររបស់ មេធាវី វិចទ័រ កូប៉េ ។ ឆ្លើយតបទៅនឹងខ្លឹមសារដែលត្រូវបានដក ស្រង់ខាងលើនេះ ស៊ីវ ហេងឌ័រ បញ្ជាក់ថា "ខ្ញុំគិតថា ដូចជាខ្ញុំមិន បានសរសេរអញ្ចឹងទេ គឺខ្ញុំដកស្រង់នូវអ្វីដែលគេបាននិយាយ" ។

### ឃ) សេចក្តីថ្លែងការណ៍របស់ជនជាប់ចោទ នួន ជា

នៅក្នុងឡុងពេលសវនាការស្តាប់សក្ខីកម្មសាក្សី ស៊ីវ ហេងឌ័រ អង្គជំនុំជម្រះបានអនុញ្ញាតាមសំណើរបស់ក្រុមមេធាវីការពារក្តី នួន ជា ដែលសុំឲ្យកូនក្តីខ្លួនធ្វើសេចក្តីថ្លែងការណ៍មួយចំនួនទាក់ទង នឹងកិច្ចដំណើរការជំនុំជម្រះ ។ នៅពេលនោះ នួន ជា បានថ្លែង ខ្លាំងៗ ចេញពីបន្ទប់ឃុំខ្លួននៅក្រោមសាលសវនាការដោយលើក ឡើងថា "សូមគោរពលោក លោកស្រីចៅក្រម ។ ខ្ញុំសូមលើកឡើង នូវការជូនដំណឹងទៅលោក លោកស្រីចៅក្រម ។ ដូចដែលខ្ញុំតែង តែបានលើកឡើងមកហើយថា តុលាការនេះមិនបានគោរពទៅ លើគោលការណ៍នៃការកាត់សេចក្តីត្រឹមត្រូវ និងយុត្តិធម៌នោះ ទេ ។ ខ្ញុំបានសង្កេតឃើញការប្រព្រឹត្តមកលើជនជាប់ចោទក៏ដូចជា ក្រុមមេធាវីការពាររបស់ខ្ញុំ វិវត្តពីអាក្រក់ ទៅកាន់តែអាក្រក់ ថែមទៀត ។ ខ្ញុំក៏អស់ជំនឿនឹងតុលាការនេះដូចលោក ខៀវ សំផន ដែរ ។ ការប្រព្រឹត្តរបស់តុលាការមកលើខាងយើងខ្ញុំ គឺនៅភពម្ខាង ហើយខាងព្រះរាជអាជ្ញា នៅភពម្ខាង ។ ជាក់ស្តែងដូចជានៅពេល ថ្មីៗនេះ មេធាវីរបស់ខ្ញុំត្រូវបានកាត់ផ្តាច់មិនឲ្យសួរសំណួរសារ ធាតុ ដើម្បីដោះបន្ទុកមកលើរូបខ្ញុំនោះទេ ។ នេះជាភាពអយុត្តិធម៌ មួយដែលរារាំងមិនឲ្យមេធាវីរបស់ខ្ញុំបំពេញនូវតួនាទីការពារខ្ញុំ ដោយពេញលេញ ។ នេះជារឿងក្តីនៃអាយុជីវិតរបស់ខ្ញុំ មិនមែន ជាធ្វើលេងៗឲ្យតែឆាប់រហ័ស ដើម្បីដាក់ទោសខ្ញុំនោះទេ ។ ដោយភាព អស់ជំនឿនឹងការប្រព្រឹត្តដោយលម្អៀងបែបនេះ ខ្ញុំសូមជូនដំណឹង ថា ខ្ញុំមិនឆ្លើយតបទៅនឹងសំណួររបស់ព្រះរាជអាជ្ញា និងភាគីពានា



សូ វណ្ណា ហៅ សោ ភឹម (រូបកណ្តាល ក្នុងសម្លៀកបំពាក់ពណ៌ខ្មៅ) និងកងទ័ព កុម្មុយនីស្តរបស់វៀតណាម ក្នុងឆ្នាំ១៩៧៣ ។ រូបថតនេះ ត្រូវបានថតក្នុង ឃុំក្រពៅ ក្នុងខេត្តកំពង់ចាម ដែលជាផ្នែកមួយនៃសង្គ្រាមស៊ីវិលប្រឆាំងនឹងរដ្ឋ

នៅក្នុងតុលាការដែលមិនយុត្តិធម៌នេះទេ ។ ក្នុងគ្រានេះ ការពិត យុត្តិធម៌ និងផលប្រយោជន៍ ត្រូវបានបំផ្លាញដោយតុលាការ នេះ" ។

បន្ទាប់ពីជនជាប់ចោទ នួន ជា ធ្វើសេចក្តីថ្លែងការណ៍ចប់ភ្លាម តំណាងសហព្រះរាជអាជ្ញា ថារិក អាប់ឌុលហាក់ បានស្នើឲ្យអង្គជំនុំ ជម្រះពិចារណាអំពីទម្ងន់នៃភស្តុតាងដែល នួន ជា បានផ្តល់ និង

ប្រាប់អំពីផលវិបាកដែលកើតចេញពីការនៅស្ងៀមមិនឆ្លើយតបនេះ ។ សហមេធាវីអន្តរជាតិនាំមុខដើមបណ្តឹងរដ្ឋប្បវេណី ស៊ីម៉ុនណូហ្វុត បានបន្ថែមថា គាត់ពុំមានការភ្ញាក់ផ្អើលឡើយចំពោះសេចក្តីថ្លែងការណ៍របស់ នួន ជា ព្រោះនេះគឺជាឥរិយាបទរបស់ជនជាប់ ចោទ នួន ជា និង ខៀវ សំផន ។ បន្ថែមលើនេះទៀត មេធាវីរបស់ជនជាប់ចោទតែងតែគិតថាខ្លួនជាជនរងគ្រោះ ដោយចោទប្រកាន់ថា មិនមានការគោរពគោលការណ៍ចំពោះមុខ ហើយលើកឡើងជាសាធារណៈថា ក្រុមរបស់ខ្លួនមិនត្រូវបានអនុញ្ញាតឲ្យសួរ



...ខ្មែរក្រហមធ្វើដំណើរទស្សនកិច្ចទៅកាន់កងមួយនៃកងកម្លាំងប្រយុទ្ធស្មគ្រចិត្ត ...២ បន្ទាប់ពីកងទ័ពខាងសម្ព័ន្ធមិត្តចាប់ផ្តើមធ្វើការវាយប្រហារទៅលើមូលដ្ឋានទ័ព ...ាភិបាលនៃរបបសាធារណរដ្ឋខ្មែរ ដឹកនាំដោយលោកសេនាប្រមុខ លន់ នល់ ។
(រូបថតមជ្ឈមណ្ឌលឯកសារកម្ពុជា)

សំណួរ ។ ចុងក្រោយមេធាវី ស៊ីម៉ុនណូហ្វុត បញ្ជាក់ថា មានការសោកស្តាយយ៉ាងខ្លាំងចំពោះមេធាវីការពារក្តី និងជនជាប់ចោទទាំងពីរ ។

## ៩) ការសួរដេញដោលដោយក្រុមមេធាវីការពារក្តី ខៀវ សំផន

ក្នុងការសួរដេញដោលសាក្សី ស៊ីវ ហេងឌ័រ ក្រុមមេធាវីការពារ ខៀវ សំផន បានផ្តោតទៅ លើការទម្លាក់គ្រាប់បែករបស់សហរដ្ឋអាមេរិកមកលើប្រទេសកម្ពុជាមុនឆ្នាំ១៩៧៥ របនាសម្ព័ន្ធរបស់ចលនាខ្មែរក្រហមក្នុងដំណាក់កាលតស៊ូ តួនាទី និងសិទ្ធិអំណាចរបស់ ខៀវ សំផន និង សិទ្ធិអំណាចរបស់ថ្នាក់មជ្ឈិមជាដើម ។ ក្នុងការសួរដេញដោលនេះ ក្រុមមេធាវីការពារក្តី ខៀវ សំផន បានលើកយកឯកសារមួយចំនួនមកសួរបញ្ជាក់ ។

### ក) ការទម្លាក់គ្រាប់បែករបស់សហរដ្ឋអាមេរិក

ឆ្លើយតបនឹងសំណួរមេធាវីអន្តរជាតិ អង់តា ហ្គីសេ ទាក់ទងនឹងការទម្លាក់គ្រាប់បែកពីសំណាក់សហរដ្ឋអាមេរិកមកលើប្រទេសកម្ពុជា សាក្សី ស៊ីវ ហេងឌ័រ បានបញ្ជាក់ថា សភារបស់សហរដ្ឋអាមេរិក បានអនុម័តច្បាប់ឈប់ឲ្យមានការទម្លាក់គ្រាប់បែកមកលើប្រទេសកម្ពុជានៅថ្ងៃទី១៥ ខែមីនា ឆ្នាំ១៩៧៣ ។ ទោះបីជាយ៉ាងណារដ្ឋាភិបាលសហរដ្ឋអាមេរិកនៅតែបន្តទម្លាក់គ្រាប់បែកមកលើប្រទេសកម្ពុជារហូតដល់ខែសីហា ឆ្នាំ១៩៧៣ ។ ភាគខាងត្បូង (ភូមិភាគនិរតី) និងភាគខាងលិចនៃប្រទេសកម្ពុជាទទួលរងការទម្លាក់គ្រាប់បែកច្រើនជាងគេ ។ ប្រជាជនជាច្រើនបានរងរបួស និងស្លាប់ដោយសារការទម្លាក់គ្រាប់បែកនេះ ។ ដលដំណាំកសិកម្ម ទ្រព្យសម្បត្តិ និងផ្ទះសម្បែងជាច្រើនទទួលរងការបំផ្លិចបំផ្លាញ ។

### ខ) អង្គការលេខរបស់ចលនាកុម្មុយនីស្តកម្ពុជា

ស៊ីវ ហេងឌ័រ បានផ្តល់សក្ខីកម្មថា យោងតាមឯកសារដែលបានមកពី អ៊ុក សំ (ជាបុគ្គលម្នាក់ ដែលស្ថិតនៅក្នុងជួរថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជា បន្ទាប់មករត់ចូលរដ្ឋាភិបាល លន់ នល់) បានបញ្ជាក់ថា ប៉ុល ពត ជាមេដឹកនាំកំពូលនៃចលនាតស៊ូរបស់បក្សកុម្មុយនីស្តកម្ពុជា ។ ក្រៅពីនេះមាន វ៉ន វ៉េត ជាលេខាភូមិភាគពិសេស, សោ ភឹម លេខាភូមិភាគ និងមានឈ្មោះបុគ្គលមួយចំនួនទៀត ដូចជា ឈិត ជឿន ហៅ ម៉ុក, កុយ ធួន និងមេដឹកនាំមួយចំនួនទៀត ។ នៅពេលនោះក៏មានការវិភាគទៅលើបុគ្គលបីរូប (ក្នុងនោះមាន ខៀវ សំផន ម្នាក់) ដែលត្រូវបានគេហៅថា "ខ្មោចទាំងបី" ស្ថិតនៅក្នុងជួរថ្នាក់កំពូលរបស់ចលនាខ្មែរក្រហមប្អត់ ។ ស៊ីវ ហេងឌ័រ បានបញ្ជាក់ថា មានបទសម្ភាសន៍មួយចំនួនបានអះអាងថា បុគ្គលទាំងបីរូបនេះមិនស្ថិតនៅក្នុងជួរថ្នាក់ដឹកនាំកំពូលរបស់ចលនាបក្សកុម្មុយនីស្តកម្ពុជាឡើយ ។ បន្ថែមលើនេះទៀតមានការជជែក

គ្នាយ៉ាងក្តៅគគុកក្នុងការពិនិត្យមើលថា តើមេដឹកនាំចលនាបក្សកុម្មុយនីស្តមានភាពឯករាជ្យពីបក្សកុម្មុយនីស្តវៀតណាម ឬយ៉ាងណា ។ ស៊ីវ ហេងឌ័រ បានបញ្ជាក់ថា នៅពេលនោះភ្នាក់ងារ សេ.អ៊ី.អា នៅតែវ៉ាន់ បានកំណត់ថា ចលនាខ្មែរក្រហមគឺស្ថិតនៅក្រោមការគ្រប់គ្រងរបស់បក្សកុម្មុយនីស្តវៀតណាម ។ ប៉ុន្តែការកំណត់ដូច្នេះត្រូវបានជំទាស់ដោយអ្នកវិភាគមួយចំនួននៅក្នុងអំឡុងពេលនោះ ។ ស៊ីវ ហេងឌ័រ បញ្ជាក់បន្ថែមថា ក្រោយមកភ្នាក់ងារស៊ើបការណ៍របស់ស្ថានទូតអាមេរិកជឿថា ខ្មែរក្រហមមិនស្ថិតនៅក្រោមការគ្រប់គ្រងរបស់វៀតណាមឡើយ ។

### គ) តួនាទី និង សិទ្ធិអំណាចរបស់ ខៀវ សំផន

ទាក់ទងនឹងប្រធានបទនេះ មេធាវីអន្តរជាតិ អង់តា ហ្គីសេ ដាក់បង្ហាញឯកសារដែល ស៊ីវ ហេងឌ័រ សម្ភាសជាមួយ ជួន ប្រសិទ្ធ នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ២០០៩ ដើម្បីសួរដេញដោល ។ មេធាវីដកស្រង់សម្តីរបស់ ជួន ប្រសិទ្ធ ដែលថា «...ខៀវ សំផន ល្បីថាជាជនសុចរិតបំផុត ។ នៅភ្នំពេញខ្ញុំមានឱកាសជួបគាត់ប៉ុន្មានដងដែរ ។ គាត់គឺជារដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និងជាតំណាងរាស្ត្រ គាត់ជាអ្នកនយោបាយនៅក្នុងរបប សីហនុ និង ប៉ុល ពត ។ គាត់ជាបណ្ឌិតផ្នែកសេដ្ឋកិច្ច ។ ខ្ញុំមិនដឹងថាគាត់ជា សមាជិកគណៈកម្មការមជ្ឈិមឬទេ ទោះបីជាគាត់ជាប្រធានគណៈប្រធានរដ្ឋក៏ដោយ ។ មុនឆ្នាំ១៩៧៥ គាត់ជាឧបនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ជាមេបញ្ជាការយោធាដែលជាតំណែងមានតែឈ្មោះ ព្រោះថា ប៉ុល ពត ជាមេបញ្ជាការពិតប្រាកដ ។ នៅពេលនេះដដែល នៅពេលដែលគាត់ធ្វើដំណើរទៅបរទេសគឺ អៀង សារី ជាអ្នកមានអំណាច ចំណែក ខៀវ សំផន គឺជាប្រធានគណៈប្រតិភូ ។ នៅពេលដែលមានគណៈប្រតិភូដឹកនាំដោយ អៀង សារី គឺ អៀង សារី នេះហើយជាអ្នកមានអំណាចពិតប្រាកដ» ។ ស៊ីវ ហេងឌ័រ បានបញ្ជាក់បន្ថែមថា ជួន ប្រសិទ្ធ ពិតជាបានអះអាងថា ខៀវ សំផន ជាមេបញ្ជាការដែលមានតែឈ្មោះប្រាកដមែន ។

### ឃ) សិទ្ធិអំណាចរបស់ភូមិភាគ

សិទ្ធិអំណាចរបស់ភូមិភាគជាប្រធានបទមួយដែលមេធាវីអន្តរជាតិ អង់តា ហ្គីសេ បានផ្តោតការយកចិត្តទុកដាក់សួរដេញដោលសាក្សី ស៊ីវ ហេងឌ័រ ។ មេធាវីការពារក្តីហាក់ដូចជាព្យាយាមបង្ហាញឲ្យឃើញថា កម្មាភិបាលនៅភូមិភាគបានអនុវត្តអំណាចរបស់ខ្លួនដោយឯករាជ្យ និងមិនគោរពតាមការណែនាំរបស់មជ្ឈិមបក្ស ។ ទាក់ទងទៅនឹងប្រធានបទនេះ មេធាវី អង់តា ហ្គីសេ បានដាក់បង្ហាញឯកសារបទសម្ភាសន៍មួយដែល ស៊ីវ ហេងឌ័រ ធ្វើជាមួយអតីតកម្មាភិបាលម្នាក់ (មិនបញ្ចេញឈ្មោះ) ចុះថ្ងៃទី៩ ខែមីនា ឆ្នាំ១៩៨០ នៅស្រះកែវ ព្រំដែនខ្មែរ-ថៃ ។ មេធាវីការពារក្តីបានដកស្រង់ខ្លឹមសារដែលសាក្សីនោះបានបញ្ជាក់ថា «នៅពេលនោះគឺថាមានភាពល្មៀងជាច្រើន ។ ថ្នាក់លើពុំបានស្វែងយល់សភាពការណ៍ជាក់ស្តែងឡើយ គិតតែអង្គុយក្នុងការិយាល័យអានតែរបាយការណ៍ ហើយចេះតែជឿ ។ រីឯថ្នាក់ក្រោមវិញ ពួកកម្មាភិបាលវិញចេះតែផ្គាប់ចិត្តមជ្ឈិមបក្ស ហើយលាក់បាំងការពិត ។ ជាលទ្ធផល គឺមានគម្លាតគ្នាឆ្ងាយរវាងថ្នាក់លើ និងប្រជាជន ។ នៅភូមិភាគពាយ័ព្យ ភ្នាក់ងារវៀតណាមដូចជា រស់ ញឹម បានយកស្រូវអង្ករពីសហករណ៍ទុកសម្រាប់ខ្លួនឯង ។ គាត់លាក់ទុកត្រូវអង្ករនៅក្នុងឃ្លាំង ដើម្បីប្រើប្រាស់ប្រឆាំងនឹងបក្សទៅថ្ងៃក្រោយ ។ ពួកវាបានទុកស្រូវអង្ករពីដៃមជ្ឈិមបក្ស និងប្រជាជន ។ ហេតុនេះ ពួកវាជាអ្នកក្បត់ប្រជាជន និងមជ្ឈិម» ។ ស៊ីវ ហេងឌ័រ បញ្ជាក់បន្ថែមថា មានបទសម្ភាសន៍ជា ច្រើនទៀតដែលក្នុងនោះមានទាំងអតីតកម្មាភិបាលខ្មែរក្រហម និងប្រជាជនសាមញ្ញបាននិយាយអំពីបញ្ហាទាំងនេះ ។

បទសម្ភាសន៍មួយផ្សេងទៀតបានបញ្ជាក់ថា នៅមុនពេលរដូវស្ទូងម្តងៗ ភូមិភាគនីមួយៗបាន បើកកិច្ចប្រជុំដើម្បីសម្រេចថា ត្រូវស្ទូងស្រូវប៉ុន្មាន និងត្រូវស្ទូងដោយរបៀបណា ។ បន្ទាប់ពីស្ទូង និងច្រូតកាត់រួចរាល់ហើយ ភូមិភាគបើកកិច្ចប្រជុំមួយទៀតដើម្បីសម្រេចថា តើត្រូវរក្សាស្រូវទុកចំនួនប៉ុន្មានសម្រាប់ប្រជាជន និងស្រូវប៉ុន្មានទៀតសម្រាប់បញ្ជូនទៅមជ្ឈិម ។ សាក្សីដដែលនេះបានបន្ថែមថា «ភូមិភាគនីមួយៗត្រូវបានសន្មត់ថា មានស្រូវអង្ករគ្រប់គ្រាន់សម្រាប់ផ្គត់ផ្គង់ប្រជាជន និងកងទ័ពនៅក្នុងភូមិភាគរបស់ខ្លួន ។ នៅសល់ពីនេះ ទើបបញ្ជូនទៅថ្នាក់លើដើម្បីលក់ទៅឲ្យបរទេស ។ ប៉ុន្តែដោយសារតែមានជនក្បត់នៅក្នុងភូមិភាគនានាដែលចង់មានកេរ្តិ៍ឈ្មោះល្អសម្រាប់ពួកគេ បានបញ្ជូនស្រូវយ៉ាងច្រើន ទៅថ្នាក់មជ្ឈិម ហើយទង្វើបែបនេះហើយដែលបណ្តាលឲ្យ

ប្រជាជនជាច្រើនបានស្លាប់នៅក្នុងភូមិភាគទាំងនោះ ។ ជនក្បត់ទាំងនោះមិនបានគិតពីរបបអាហាររបស់ប្រជាជនជាមុន តាមដែលពួកគេត្រូវបានតម្រូវឲ្យធ្វើឡើយ ។ តែផ្ទុយទៅវិញ ពួកគេបញ្ជូនស្រូវអង្ករទៅថ្នាក់មជ្ឈិមដើម្បីបានឡើងបុណ្យស័ក្តិ ។ បញ្ហាសំខាន់គឺថា នៅតាមលំដាប់ថ្នាក់ទាំងអស់មិនមានការស៊ើបអង្កេតឲ្យបានជាក់លាក់គ្រប់គ្រាន់អំពីស្ថានភាពពិតឡើយ ។ ពួកគេគ្រប់រូបជឿទៅលើរបាយការណ៍នៅលើក្រដាសរបស់អ្នកផ្សេងទៀត ។ ដូច្នេះកម្មាភិបាលក្បត់បានសរសេររបាយការណ៍ក្លែងក្លាយ ហើយបានទុកស្រូវអង្ករទាំងអស់សម្រាប់ពួកខ្លួន ហើយមិនបានចែកជូនប្រជាជនឡើយ» ។ ស៊ីវ ហេងឌ័រ បានបញ្ជាក់បន្ថែមថា មានសាក្សីមួយចំនួនទៀតបានបញ្ជាក់ដូចគ្នានេះដែរដែលថា មជ្ឈិមបក្សពុំបានកំណត់ចំនួនកូតាក្នុងការទទួលបានទិន្នផលស្រូវឡើយ ។

ទាក់ទងនឹងប្រធានបទនេះដែរ មេធាវី អង់តា ហ្គីសេ ដាក់បង្ហាញឯកសារមួយទៀតដែល ស៊ីវ ហេងឌ័រ ធ្វើការសង្ខេបទៅលើបទសម្ភាសន៍មួយដែល ហេង ហាំខេង និង តូច វណ្ណារិទ្ធ សម្ភាស ខៀវ សំផន នៅថ្ងៃទី១៧ ខែសីហា ឆ្នាំ២០០៥ ។ នៅក្នុងកិច្ចសម្ភាសន៍នោះ ខៀវ សំផន បានបញ្ជាក់ថា នៅក្នុងរបបខ្មែរក្រហម ភូមិភាគនីមួយៗ ជាពិសេសលេខាភូមិភាគទាំងអស់នោះ សុទ្ធជាស្ដេចត្រាញ់ ។ លេខាភូមិភាគទាំងនោះបានបែងចែកការងារនៅតាមភូមិភាគតាមតែចិត្តរបស់ខ្លួន ។ ថ្នាក់មជ្ឈិមពុំបានត្រួតត្រាដោយផ្ទាល់ឡើយ គឺទទួលបានតែរបាយការណ៍តែប៉ុណ្ណោះ ។ ខៀវ សំផន បានបញ្ជាក់ទៀតថា នៅភូមិភាគឧត្តរថ្មី ក្រោយពីចាត់តាំង កង ចាប ទៅកាន់កាប់ភ្លាម ភូមិភាគនេះចាប់ផ្ដើមមានការចាប់មនុស្សដាក់គុក ។ ការចាប់ខ្លួនទាំងនោះថ្នាក់លើមិនបានដឹងឡើយ រហូតដល់ឆ្នាំ១៩៧៨ នៅពេលដែលថ្នាក់មជ្ឈិម និងមន្ទីរប-១ បញ្ជូនមនុស្សទៅរៀបចំទទួលភ្ញៀវនៅភូមិភាគនេះប៉ុណ្ណោះ ទើបថ្នាក់មជ្ឈិមបានដឹង ។

គួរបញ្ជាក់ថា ខ្លឹមសារដែល ខៀវ សំផន បានលើកឡើងទាំងនេះពុំត្រូវបាន ស៊ីវ ហេងឌ័រ បញ្ជាក់ឲ្យបានច្បាស់ថា មានភាពត្រឹមត្រូវកម្រិតណាឡើយ ។ ម្យ៉ាងវិញទៀត ស៊ីវ ហេងឌ័រ ពុំបានចូលរួមដោយផ្ទាល់នៅក្នុងកិច្ចសម្ភាសន៍ដែលធ្វើឡើងដោយ ហេង ហាំខេង និង តូច វណ្ណារិទ្ធ ជាមួយ ខៀវ សំផន នៅថ្ងៃទី១៧ ខែសីហា ឆ្នាំ២០០៥ នេះឡើយ ។

## បញ្ហាផ្សេងៗ

នៅពេលចាប់ផ្ដើមថ្ងៃទី២នៃការស្ដាប់សក្ខីកម្មរបស់សាក្សី ស៊ីវ ហេងឌ័រ លោក វិចទ័រ កូប៉េ ជាមេធាវីអន្តរជាតិការពារក្ដីជនជាប់ចោទ នួន ជា បានលើកឡើងថា គាត់មានសំណើបន្ទាន់មួយសុំឲ្យអង្គជំនុំជម្រះដោះស្រាយពាក់ព័ន្ធនឹងសាក្សី ស៊ីវ ហេងឌ័រ ហើយស្នើសុំឲ្យធ្វើការពិភាក្សាជាសាធារណៈ ។ ការលើកឡើងនេះបានធ្វើឲ្យមានការភ្ញាក់ផ្អើលយ៉ាងខ្លាំងដល់ក្រុមតំណាងសហព្រះរាជអាជ្ញា និងអង្គជំនុំជម្រះ ព្រោះក្រុមមេធាវីការពារក្ដីជនជាប់ចោទ នួន ជា ពុំបានជូនដំណឹងជាមុន ។ តំណាងសហព្រះរាជអាជ្ញា ឃីត វែន័រ បានធ្វើការកត់សម្គាល់ថា ក្រុមមេធាវីការពារក្ដីមិនបានជូនដំណឹងដល់ភាគីទាំងអស់ជាមុន ដូច្នេះមិនអាចយកមកសម្រេចភ្លាមៗនោះទេ ។ ជាងនេះទៅទៀត តំណាងសហព្រះរាជអាជ្ញាបានប្រឆាំងចំពោះសំណើរបស់មេធាវីការពារក្ដីសុំឲ្យបើកសវនាការជាសាធារណៈ ។ បន្ទាប់ពីមានការពិភាក្សាគ្នារវាងចៅក្រមនៃអង្គជំនុំជម្រះ លោកចៅក្រម និល ណុន បានសម្រេចថា សវនាការត្រូវធ្វើជាអសាធារណៈ ដោយបង្គាប់ឲ្យ ស៊ីវ ហេងឌ័រ ចាកចេញពីបន្ទប់សវនាការ ព្រមទាំងផ្ដាច់ប្រព័ន្ធសោតទស្សន៍ដែលជាទូទៅត្រូវបានប្រើសម្រាប់ផ្សាយរូបភាព និងសំឡេងចេញមកខាងក្រៅបន្ទប់សវនាការ ។ បន្ទាប់ពីសវនាការបានប្រព្រឹត្តទៅជាអសាធារណៈអស់មួយរយៈពេលខ្លី អង្គជំនុំជម្រះបានសម្រេចបើកសវនាការជាសាធារណៈឡើងវិញ ព្រមទាំងអនុញ្ញាតឲ្យក្រុមមេធាវីការពារក្ដីជនជាប់ចោទ នួន ជា លើកឡើងនូវបញ្ហាដែលមេធាវីសុំឲ្យដោះស្រាយនោះ ។ បន្ទាប់ពីទទួលបានការអនុញ្ញាតនេះ វិចទ័រ កូប៉េ បានលើកឡើងថា លោក រ៉ប់ លឹមគិន ដែលជាសហអ្នកនិពន្ធម្នាក់ក្នុងខ្សែភាពយន្ត «១ថ្ងៃនៅទួលពោធិ៍ជ្រៃ» បានផ្ញើសារអេឡិចត្រូនិច (អ៊ីម៉ែល) មួយមកកាន់គាត់ ។ នៅក្នុងសំបុត្រនោះ រ៉ប់ លឹមគិន បានសរសេរថា «លោក វិចទ័រ ជាទីរាប់អាន តាមរយៈការអានរឿងរ៉ាវការសែតភ្នំពេញប៉ុស្ដិ៍ក្នុងការដំណើរការសវនាការពីម្សិលមិញទំនងជាមានការយល់ច្រឡំពីអ្វីដែលលោក នួន ជា និយាយនៅក្នុង ឌី.វី.ឌី របស់យើង ។ គាត់មិនបានយល់ស្របថាមន្ត្រីកំពូល លន់ នល់ ត្រូវបានគេសម្លាប់នោះទេ

គាត់និយាយថា ពាក់កណ្តាលនៃគណៈរដ្ឋមន្ត្រីរបស់ នល់ នល់ ហើយនឹងមន្ត្រីកំពូលៗ ត្រូវបានសម្រេចត្រឹមត្រូវតាមគោលការណ៍តុលាការយោធារបស់បដិវត្តន៍ ។ លោក នួន ជា មិនបានចូលរួមក្នុងការសម្រេចនោះទេ ហើយវិទ្យុភ្នំពេញបានផ្សាយជាផ្លូវការថា ការកាប់សម្លាប់នៅពេលនោះដែរ ហើយបានផ្តល់នូវមូលហេតុដូចលោក នួន ជា បានបញ្ជាក់នៅក្នុង ឌី.វី.ឌី របស់យើងដែរ ។ លោក នួន ជា មិនបានទទួលស្គាល់ថា មានការទទួលខុសត្រូវដោយផ្ទាល់ចំពោះការសម្លាប់សមាជិកគណៈរដ្ឋមន្ត្រី លន់ នល់ ទេ ក៏ប៉ុន្តែគាត់បានអះអាងពីមូលហេតុនោះថាត្រឹមត្រូវ ។ តាមពិតមូលហេតុមិនមានអ្វីខុសពីអ្វីដែលសហរដ្ឋអាមេរិកប្រកាសសម្លាប់ប៊ិនឡាឌិន នោះទេ ។ ខ្ញុំសង្ឃឹមថា ភស្តុតាងនេះមិនមាន លក្ខណៈជាការចោទប្រកាន់ដែលមានតម្លៃធំធេងនោះទេ ។ ដូច្នេះវាមានការបញ្ជាក់នៅក្នុងករណីខ្សែភាពយន្តរបស់យើង ។ ប៉ុន្តែផ្ទុយទៅវិញ ទាក់ទងទៅនឹងទួលពោធិ៍ជ្រៃនេះ គឺជាបញ្ជាសម្លាប់ដែលធ្វើដោយ រស់ ញឹម មិនមែនក្រោមមជ្ឈិមនោះទេ ។ យើងបានប្រមូលភស្តុតាងដ៏ច្រើនអំពីកម្មវិធីរបស់ រស់ ញឹម ប៉ុន្តែយើងមិនមានលទ្ធភាពបញ្ចប់ខ្សែភាពលើកទី២ បានទេ ដោយសារថា ថេត សម្បត្តិ បានទៅសហរដ្ឋអាមេរិក ដោយសារមូលហេតុផ្ទាល់ខ្លួន ។ ដោយក្តីគោរព រ៉ប់ លឹមគិន» ។

បន្ទាប់ពីអានខ្លឹមសារសំបុត្រនេះចប់ វិចទ័រ កូប៉េ បានលើកឡើងថា លោក លឹមគិន មានព័ត៌មានជាច្រើនដែលអាចធ្វើជាភស្តុតាងដោះបន្ទុកសម្រាប់ នួន ជា ចំពោះបទចោទប្រកាន់ដែលទាក់ទងនឹងការសម្លាប់មនុស្សនៅទួលពោធិ៍ជ្រៃ ។ ជាងនេះទៅទៀត លឹមគិន អាចពន្យល់ខ្សែភាពយន្ត«១ថ្ងៃនៅ ទួលពោធិ៍ជ្រៃ ដែលសហព្រះរាជអាជ្ញាបានយកមកធ្វើជាភស្តុតាងដាក់បន្ទុក គឺជាភស្តុតាងដោះបន្ទុក សម្រាប់ នួន ជា ។ ចុងក្រោយ វិចទ័រ កូប៉េ ស្នើសុំអង្គជំនុំជម្រះ៖ ទី១) សុំឲ្យទទួលយកសារអេឡិច ត្រូនិចនោះធ្វើជាភស្តុតាងដាក់ក្នុងសំណុំរឿង ទី២) សុំឲ្យកោះហៅ លឹមគិន មកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ និងទី៣) សូមឲ្យផ្អាកសវនាការស្តាប់សក្ខីកម្មសាក្សី ស៊ីវ ហេងឌ័រ រហូតមានការស៊ើបអង្កេតករណីលោក រ៉ប់ លឹមគិន បានចប់សព្វគ្រប់ ។

តំណាងសហព្រះរាជអាជ្ញា ឃីត វ៉េន័រ បានបដិសេធចំពោះសំណើរបស់មេធាវីការពារក្តី ដោយបានឆ្លើយតបថា សារអេឡិចត្រូនិចនោះពុំមានការជាប់ពាក់ព័ន្ធឡើយ ហើយមានតម្លៃតិចតួចបំផុត ។ ចំពោះសំណើសុំឲ្យកោះហៅ រ៉ប់ លឹមគិន មកផ្តល់សក្ខីកម្មក៏ពុំមានភាពចាំបាច់ដែរ ព្រោះអង្គជំនុំជម្រះ និងភាគីទាំងអស់អាចមើល និងស្តាប់ដឹងនូវអ្វីដែល នួន ជា បាននិយាយនៅក្នុង ឌី.វី.ឌី នោះ ដោយពុំចាំបាច់មានជំនួយពី រ៉ប់ លឹមគិន ឡើយ ។ ទោះបីជាយ៉ាងណា តំណាងសហព្រះរាជអាជ្ញាលើកទឹកចិត្តឲ្យក្រុមមេធាវីការពារក្តីយកភស្តុតាងដែលទាក់ទងនឹងការសម្លាប់មនុស្សនៅទួលពោធិ៍ជ្រៃ ជៀសជាងសុំផ្អាកកិច្ចដំណើរការស្តាប់សក្ខីកម្មសាក្សី ស៊ីវ ហេងឌ័រ ។ ចុងក្រោយ ឃីត វ៉េន័រ បានផ្តល់ការកត់សម្គាល់ថា មេធាវីការពារក្តីជនជាប់ចោទ នួន ជា គឺជាមនុស្សជំនិតរបស់អ្នកផលិតខ្សែភាពយន្តនេះ ហើយអ្នកនិពន្ធនេះធ្លាប់បានបដិសេធសំណើរបស់សហព្រះរាជអាជ្ញា និងសហចៅក្រមស៊ើបអង្កេតដែលសុំផ្តល់ខ្សែភាពយន្តនេះជូនតុលាការ ។ ក្រុមមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានគាំទ្រទាំងស្រុងចំពោះការលើកឡើងរបស់ក្រុមតំណាងសហព្រះរាជអាជ្ញា ព្រមទាំងស្នើសូមឲ្យអង្គជំនុំជម្រះច្រានចោលនូវសំណើរបស់ក្រុមមេធាវីការពារក្តីជនជាប់ចោទ នួន ជា ទាំងស្រុង ។ បន្ទាប់ពីបញ្ចប់ការពិភាក្សានេះភ្លាមអង្គជំនុំជម្រះបានសម្រេចថា សំណើរបស់មេធាវីការពារក្តីសុំឲ្យទទួលយកឯកសារថ្មី [សារអេឡិចត្រូនិច] មិនបានបំពេញតាមលក្ខខណ្ឌដូចបានកំណត់នៅក្នុងវិធានផ្ទៃក្នុងរបស់តុលាការ ។ បន្ថែមលើនេះ បដិសេធនូវសំណើសុំឲ្យផ្អាកសវនាការស្តាប់សក្ខីកម្មសាក្សី ស៊ីវ ហេងឌ័រ ។

នៅក្នុងការសួរដេញដោល ស៊ីវ ហេងឌ័រ តំណាងសហព្រះរាជអាជ្ញា ឃីត វ៉េន័រ តែងតែលើកយកសៀវភៅ ឬបទសម្ភាសន៍ ដែលសាក្សីរូបនេះជាអ្នកនិពន្ធផ្ទាល់មកសួរបញ្ជាក់ថា តើពិតជាត្រឹមត្រូវ ឬបានកត់ត្រាត្រឹមត្រូវតាមអ្វីដែលអ្នកផ្តល់សម្ភាសន៍បានឆ្លើយដែរឬទេ? អាកទួរ វ៉ែកហ្គេន ជាមេធាវីការពារក្តី ខៀវ សំផន បានលើកឡើងថា ការអនុវត្តវិធីសាស្ត្រនេះគឺគ្មានន័យអ្វីទាំងអស់ និងជារបៀបនៃការចោទសួរចោទឆោតល្ងង់ទៅសាក្សី ស៊ីវ ហេងឌ័រ ។ ទោះបីជាយ៉ាងណា សេចក្តីជំទាស់នេះពុំមានប្រសិទ្ធិភាពឡើយ ហើយតំណាងសហព្រះរាជអាជ្ញា

ត្រូវបានអនុញ្ញាតឲ្យប្រើប្រាស់វិធីសាស្ត្រនេះដដែល ។

បញ្ហាដ៏ចម្រូងចម្រាស់មួយទៀតក្នុងអំឡុងពេលសួរដេញដោល ស៊ីវ ហេងឌ័រ ពាក់ព័ន្ធនឹងទម្រង់សំណួរដែលត្រូវសួរដេញដោលសាក្សីរូបនេះ ។ ស៊ីវ ហេងឌ័រ មកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះក្នុងឋានៈជាសាក្សីធម្មតា ពោលពុំមែនក្នុងឋានៈជាសាក្សីជំនាញឡើយ ។ ដូច្នេះក្នុងការសួរដេញដោល សាក្សី ស៊ីវ ហេងឌ័រ ភាគីទាំងអស់ត្រូវបានកំណត់សួរតែអង្គហេតុណាដែលសាក្សីបានដឹង និងស្ថិតនៅក្នុងវិសាលភាពនៃអង្គហេតុដែលត្រូវជំនុំជម្រះក្នុងសំណុំរឿង០០២/០១តែប៉ុណ្ណោះ ។ ភាគីពុំអាចស្នើឲ្យ ស៊ីវ ហេងឌ័រ ផ្តល់មតិយោបល់ ឬការយល់ឃើញណាមួយដូចជាអ្នកជំនាញឡើយ ។ ប៉ុន្តែសម្រាប់ការអនុវត្តជាក់ស្តែង ការសួរដេញដោលសាក្សី ស៊ីវ ហេងឌ័រ មានការជំទាស់តវ៉ាគ្នាយ៉ាងខ្លាំង ។ ជារឿយៗ ភាគីនីមួយៗតែងតែស្នើឲ្យ ស៊ីវ ហេងឌ័រ ផ្តល់មតិយោបល់ទៅលើខ្លឹមសារដែលភាគីទាំងនោះ បានលើកឡើង ដោយសារសាក្សីរូបនេះធ្លាប់មានបទពិសោធន៍ការងារស្រាវជ្រាវ និងធ្លាប់បានសម្ភាសជាច្រើន ។ ប៉ុន្តែការប្រើវិធីសាស្ត្រនេះត្រូវបានជំទាស់ដោយភាគីបដិបក្ខ ដោយផ្តល់ហេតុផលថាភាគីពុំអាចសួរ ឬស្នើឲ្យសាក្សីផ្តល់ការយល់ឃើញដូចអ្នកជំនាញឡើយ ។ ពេលខ្លះអង្គជំនុំជម្រះមានការលំបាកក្នុងការសម្រេចអំពីសេចក្តីជំទាស់ទាំងនោះ ដោយសារពេលខ្លះភាគីបានដកស្រង់ខ្លឹមសារនៅក្នុងសៀវភៅរបស់ ស៊ីវ ហេងឌ័រ ដែលបានសរសេរក្នុងនាមជាអ្នកជំនាញ ។ ពាក់ព័ន្ធនឹងបញ្ហានេះ ក្រុមមេធាវីការពារក្តីជនជាប់ចោទ នួន ជា បានលើកឡើងថា អង្គជំនុំជម្រះហាក់ដូចជាមានភាពលម្អៀងក្នុងការសម្រេចសេចក្តីឲ្យភាគីទាំងអស់សួរដេញដោលសាក្សី ។ នៅក្នុងសេចក្តីសេចក្តីថ្លែងការណ៍ នួន ជា បានចោទប្រកាន់ថា អង្គជំនុំជម្រះបានបែងចែកឲ្យក្រុមសហព្រះរាជអាជ្ញានៅភពម្ខាង ហើយក្រុមមេធាវីការពារក្តីនៅភពម្ខាងទៀត ព្រោះមេធាវីរបស់ខ្លួនពុំត្រូវបានអនុញ្ញាតឲ្យសួរសំណួរដូចសហព្រះរាជអាជ្ញាឡើយ ។ នួន ជា អះអាងថា ដោយសារហេតុផលទាំងនេះហើយទើបគាត់សម្រេចចិត្តនៅស្ងៀមមិនឆ្លើយតបសំណួរ ។



*សុន សេន (រូបកណ្តាល) កំពុងនាំគណៈប្រតិភូចិន ទៅពិនិត្យមើលសភាវុធនៅភូមិភាគបូព៌ា ក្នុងឆ្នាំ១៩៧៨ ។ ពីឆ្វេងទៅស្តាំ អ្នកបកប្រែភាសា, ស៊ូ ហាវ អគ្គរដ្ឋទូតចិនប្រចាំរបបកម្ពុជាប្រជាធិបតេយ្យ, ប្រធានក្រុមប្រឹក្សាចិនប្រចាំរបបកម្ពុជាប្រជាធិបតេយ្យ ។ (រូបថតមជ្ឈមណ្ឌលឯកសារកម្ពុជា)*

# អ្វីទៅជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ?

លឹម ជ័យទ័ត្ត

ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ជាបទល្មើសធ្ងន់ធ្ងរមួយក្នុងចំណោមបទល្មើសធ្ងរធ្ងន់ដទៃផ្សេងទៀតនៅក្នុងច្បាប់អន្តរជាតិ និងត្រូវបានផ្តល់និយមន័យផ្សេងៗគ្នា[1] ដោយតុលាការអន្តរជាតិនានាទៅតាមបរិបទជាក់ស្តែងនៃរឿងក្តីដែលបានកើតឡើង ។

បទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ត្រូវបានឃើញកើតមាននៅក្នុងប្រទេសកម្ពុជាអំឡុងពេលនៃរបបខ្មែរក្រហមចន្លោះពីថ្ងៃទី ១៧ ខែមេសា ឆ្នាំ១៩៧៥ រហូតដល់ថ្ងៃទី៦ ខែមករា ឆ្នាំ ១៩៧៩ ។ តុលាការដែលមានសមត្ថកិច្ចជំនុំជម្រះលើបទឧក្រិដ្ឋកម្មនេះ គឺអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដែលត្រូវបានបង្កើតឡើងតាមរយៈកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា នៅក្នុងឆ្នាំ២០០៣ ។ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ជាបទឧក្រិដ្ឋកម្មមួយដែលពុំមានអាជ្ញាយុកាល មានន័យថា ទោះបីជាបទឧក្រិដ្ឋកម្មនេះ ត្រូវបានប្រព្រឹត្តនៅក្នុងអតីតកាលអស់រយៈពេលយូរឆ្នាំហើយ ក៏ដោយបុគ្គលជាអ្នកប្រព្រឹត្តនៅតែពុំអាចរួចផុតពីការចោទប្រកាន់ ។

យោងតាមមាត្រា៥ នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាឧក្រិដ្ឋកម្ម ប្រឆាំងមនុស្សជាតិ ស្តែងឡើងតាមរយៈការប្រព្រឹត្តបទល្មើសមួយចំនួនដូចជា ៖

- ការធ្វើមនុស្សឃាត
- ការសម្លាប់រង្គាល
- ការធ្វើឲ្យទៅជាទាសករ
- ការនិរទេស
- ការដាក់ក្នុងមន្ទីរឃុំឃាំង
- ការធ្វើទារុណកម្ម
- ការរំលោភលើផ្លូវភេទ
- ការធ្វើទុកបុកម្នេញដោយហេតុផលនយោបាយ ពូជសាសន៍ ឬសាសនា និង
- រួមទាំងអំពើអមនុស្សធម៌ផ្សេងទៀត ដូចជា អាពាហ៍ពិពាហ៍ដោយបង្ខំ អំពើហិង្សាផ្លូវភេទ ការបាត់ខ្លួនដោយបង្ខំ និងការជម្លៀសប្រជាជនដោយបង្ខំ ។[2]

ទោះបីជាយ៉ាងណា ដើម្បីចាត់ទុកជាបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិបាន បទល្មើសទាំងអស់ខាងលើ ចាំបាច់ត្រូវតែកើតឡើងនៅក្នុងក្របខណ្ឌនៃការវាយប្រហារ ហើយការវាយប្រហារនោះត្រូវតែធ្វើឡើងមានលក្ខណៈជាទូទៅ ឬជាប្រព័ន្ធ សំដៅប្រឆាំងនឹងប្រជាជនស៊ីវិល ដោយសារមូលហេតុ ជាតិ នយោបាយ ជាតិពន្ធុ ពូជសាសន៍ ឬសាសនា ។ ម្យ៉ាងវិញទៀត ដើម្បីចោទប្រកាន់បុគ្គលណាម្នាក់ថាបានប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ចាំបាច់ត្រូវតែបង្ហាញឲ្យឃើញថា ការវាយប្រហារដែលកើតឡើងពិតជាមានជាប់ទាក់ទងនឹងអំពើរបស់ជនដែលត្រូវបានចោទប្រកាន់ ហើយជននោះចាំបាច់ត្រូវតែបានដឹងអំពីការវាយប្រហារ ។[3] ទាំងអស់នេះ គឺជាធាតុផ្សំទូទៅនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ។

គួរកត់សម្គាល់ថា នៅក្នុងច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ពុំបានដាក់លក្ខខណ្ឌតម្រូវឲ្យមានទំនាក់ទំនងរវាងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនឹងជម្លោះប្រដាប់អាវុធនោះទេ ។

## ធាតុផ្សំទូទៅដែលបង្កើតឲ្យមានឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ

### ១) ការវាយប្រហារ

ការវាយប្រហារ គឺជាការប្រព្រឹត្តិនូវអំពើហិង្សាច្រើនៗ ជនជាប់ចោទមិនចាំបាច់ប្រព្រឹត្តិអំពើហិង្សាទាំងអស់ ដែលបង្កើតបានជាការវាយប្រហារនោះទេ (អំពើរបស់ជនជាប់ចោទគ្រាន់តែជាផ្នែក នៃការវាយប្រហារទូទៅក៏បានដែរ) ។ នៅក្នុងការវាយប្រហារតែមួយ អាចកើតមានអំពើហិង្សាច្រើន ឧទាហរណ៍ អំពើមនុស្សឃាត រំលោភលើផ្លូវភេទ និងទារុណកម្ម ។[4]

ទោះបីជាសញ្ញាណនៃការវាយប្រហារ មានលក្ខណៈខុសគ្នាពីសញ្ញាណនៃជម្លោះប្រដាប់អាវុធក៏ដោយ ការវាយប្រហារ សំដៅ

ប្រឆាំងនឹងប្រជាជនស៊ីវិលអាចកើតមានឡើងមុនអាចអូសបន្លាយពេលយូរ ឬបន្តមានរហូតក្នុងអំឡុងពេលនៃជម្លោះប្រដាប់អាវុធ ។[5]

## ២) លក្ខណៈទូទៅ ឬជាប្រព័ន្ធ

អនុលោមតាមច្បាប់ទំនៀមទម្លាប់អន្តរជាតិ ការវាយប្រហារត្រូវតែមានលក្ខណៈជាទូទៅ ឬជាប្រព័ន្ធ ។ ពាក្យ *លក្ខណៈជាទូទៅ* គឺសំដៅលើការវាយប្រហារដែលមានលក្ខណៈទូលំទូលាយ និងមានចំនួនជនរងគ្រោះច្រើន ។ រីឯពាក្យថា *ជាប្រព័ន្ធ* គឺសំដៅទៅលើអំពើហិង្សាដែលមានការរៀបចំ ហើយអំពើនោះមិនអាចកើតមានដោយចៃដន្យនោះទេ ។ ការបែងចែកលក្ខណៈវិនិច្ឆ័យនៃការវាយប្រហារទាំងពីរទម្រង់ឲ្យដាច់ពីគ្នា គឺជាការលំបាកនៅក្នុងការអនុវត្តជាក់ស្តែង ។ ការវាយប្រហារលក្ខណៈទូទៅដែលកំណត់គោលដៅលើចំនួនជនរងគ្រោះច្រើន ជាទូទៅត្រូវផ្អែកលើទម្រង់មួយចំនួននៃការរៀបចំផែនការ ឬចាត់ចែង ។ ការវាយប្រហារលក្ខណៈជាទូទៅអាចសំដៅលើទាំងអនុភាពត្រួតគ្នានៃអំពើអមនុស្សធម៌ជាច្រើន ទាំងអំពើមនុស្សធម៌តែមួយដែលមានទ្រង់ទ្រាយធំ ។[6]

ដើម្បីកំណត់ថាការវាយប្រហារដែលកើតឡើងមានលក្ខណៈទូទៅ ឬជាប្រព័ន្ធ ឬការវាយប្រហារនោះមានលក្ខណៈទាំងពីរ ចាំបាច់ត្រូវពិចារណាលើផលវិបាកដែលកើតចេញពីការវាយប្រហារ លើប្រជាជនដែលបានកំណត់ថាជាគោលដៅ ជនរងគ្រោះដែលទទួលរងពីការវាយប្រហារនោះមានចំនួនច្រើន ចរិតលក្ខណៈនៃអំពើវាយប្រហារ លទ្ធភាពនៃការចូលរួមរបស់មន្ត្រី ឬអាជ្ញាធរ ឬគំរូនៃឧក្រិដ្ឋកម្មផ្សេងទៀតដែលអាចកត់សម្គាល់បាន ។[7]

## ៣) សំដៅប្រឆាំងលើប្រជាជនស៊ីវិល

ការវាយប្រហារដែលបានរៀបរាប់ខាងលើ គឺត្រូវតែសំដៅប្រឆាំងលើប្រជាជនស៊ីវិល ។ ពាក្យថា *ប្រជាជន* មិនមែនមានន័យថា ទាល់តែមានប្រជាជនទាំងអស់នៅក្នុងទីតាំងភូមិសាស្ត្រណាមួយ ដែលមានការវាយប្រហារទើបចាត់ទុកថាជាគោលដៅនៃការវាយប្រហារនោះទេ ។ គ្រាន់តែប្រជាជននៅក្នុងក្រុមមួយចំនួនល្មម ត្រូវបានគេកំណត់ថាជាគោលដៅនៃការវាយប្រហារ ឬគោលដៅនៃការវាយប្រហារនោះត្រូវបានបង្ហាញឲ្យឃើញថាធ្វើឡើងដើម្បីសំដៅប្រឆាំងលើប្រជាជនស៊ីវិល គឺមានលក្ខណៈគ្រប់គ្រាន់នឹងអាចចាត់ទុកថាជាការវាយប្រហារសំដៅប្រឆាំងប្រជាជនស៊ីវិល ។ ប៉ុន្តែ ប្រសិនបើការវាយប្រហារនោះសំដៅប្រឆាំងលើតែបុគ្គលមួយចំនួនតូចដែលបានកំណត់ ឬត្រូវបានជ្រើសរើសខ្លះៗនោះ គឺមិនទាន់មានលក្ខណៈគ្រាប់គ្រាន់នៅឡើយទេ ។ រីឯពាក្យថា *ជនស៊ីវិល* គឺជាជនដែលមិនមានឋានៈជាសមាជិកនៃកងកម្លាំងប្រដាប់អាវុធ និងអ្នកប្រយុទ្ធផ្សេងទៀត (កងជីវពល ទាហានស្ម័គ្រចិត្ត និងសមាជិករបស់ក្រុមចលនាតស៊ូដែលមានការចាត់តាំង) ។

ដូច្នេះពាក្យថា *ប្រជាជនស៊ីវិល* អាចកំណត់បានថា គឺជាជនដែលមិនមែនជាសមាជិកនៃកងកម្លាំងប្រដាប់អាវុធ ឬមិនមែនជាជនត្រូវទទួលស្គាល់ថាជាអ្នកប្រយុទ្ធ ។ បុគ្គលមួយរូបត្រូវបានចាត់ទុកថាជា *ជនស៊ីវិល* ប្រសិនបើឋានៈរបស់បុគ្គលនោះមិនមានលក្ខណៈច្បាស់លាស់ ។

ចំពោះទាហាន ឬសមាជិកនៃកងកម្លាំប្រដាប់អាវុធ ដែលមិនបានចូលរួមនៅក្នុងការប្រយុទ្ធ ឬបាត់បង់សមត្ថភាពក្នុងការប្រយុទ្ធ មិនត្រូវបានចាត់ទុកថាជាជនស៊ីវិលឡើយ ។ ប៉ុន្តែ វត្តមានរបស់បុគ្គលមួយចំនួនដែលមិនស្ថិតនៅក្រោមនិយមន័យនៃជនស៊ីវិល ហើយបុគ្គលទាំងនោះស្ថិតនៅក្នុងចំណោមប្រជាជនស៊ីវិល មិនអាចដកហូតលក្ខណៈជាជនស៊ីវិលរបស់ប្រជាជនទាំងនោះបានទេ ។

ដើម្បីបង្ហាញឲ្យឃើញថា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិបានកើតឡើងនៅអំឡុងពេលនៃជម្លោះប្រដាប់អាវុធ ចាំបាច់ត្រូវតែបញ្ជាក់ឲ្យច្បាស់ថា ប្រជាជនស៊ីវិលត្រូវបានកំណត់ជាគោលដៅចម្បងនៃការវាយប្រហារ ។ ច្បាប់ទំនៀមទម្លាប់អន្តរជាតិតម្រូវឲ្យភាគីនានានៃជម្លោះ ញែកឲ្យដាច់ពីគ្នាគ្រប់ពេលទាំងអស់រវាងប្រជាជនស៊ីវិល និងអ្នកប្រយុទ្ធ និងតម្រូវមិនឲ្យវាយប្រហារលើគោលដៅយោធា ប្រសិនបើការវាយប្រហារនោះ ទំនងជាបង្កឲ្យមានចំនួនអ្នកស្លាប់ ឬប៉ះពាល់ដល់ជនស៊ីវិលច្រើនលើសលុប គឺលើសពីផលប្រយោជន៍យោធាដែលគេអាចប៉ាន់ស្មានទុកមុន ។

តើត្រូវធ្វើដូចម្តេចដើម្បីកំណត់ថា ការវាយប្រហារមួយជាការវាយប្រហារមានគោលដៅ ឬគ្មានគោលដៅប្រឆាំងជនស៊ីវិល?

ដើម្បីកំណត់ថាការវាយប្រហារមួយមានគោលដៅប្រឆាំងនឹងជនស៊ីវិល ចាំបាច់ត្រូវពិនិត្យមើលលើកត្តាទាំងឡាយដែលពាក់ព័ន្ធរួមមាន៖

- មធ្យោបាយ និងវិធីសាស្ត្រដែលប្រើប្រាស់នៅក្នុងការវាយប្រហារ
- ឋានៈរបស់ជនរងគ្រោះ
- ចំនួនជនរងគ្រោះ
- លក្ខណៈនៃឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅក្នុងការវាយប្រហារ និងការបង្ក្រាបអ្នកតស៊ូ នាអំឡុងពេលនោះ និង
- ទំហំនៃកម្លាំងវាយប្រហារដែលអាចនិយាយបានថា បានគោរពតាម ឬមានចេតនាគោរពតាមលក្ខខណ្ឌប្រុងប្រយ័ត្នទាំងឡាយនៃច្បាប់សង្គ្រាម ។

នៅក្នុងករណីដែលការវាយប្រហារសំដៅត្រង់ៗលើប្រជាជនស៊ីវិលជាទូទៅ នៅពេលនោះ គឺពុំចាំបាច់បង្ហាញថា ជនរងគ្រោះទាំងនោះជាប់ទាក់ទងជាមួយក្រុមពិសេសណាមួយ ខាងនយោបាយ ជាតិពន្ធុ ឬផ្សេងឡើយ ។ មានន័យថា ឲ្យតែការវាយប្រហារនោះសំដៅយកប្រជាជនស៊ីវិលជាគោលដៅដើម្បីធ្វើការវាយប្រហារ ទោះបីជាអ្នកស្ថិតនៅក្នុងចំណោមក្រុមប្រជាជនស៊ីវិលនោះមានឋានៈបុគ្គលជាអ្វីក៏ដោយ អំពើនោះគឺជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ។

ហេតុដូច្នេះ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិអាចរួមបញ្ចូលទាំងការវាយប្រហាររបស់រដ្ឋមួយលើប្រជាជនរបស់រដ្ឋខ្លួនឯងដែរ ។[៨]

### ៤) មូលហេតុ ជាតិ នយោបាយ ជាតិពន្ធុ ពូជសាសន៍ ឬសាសនា

ដើម្បីកំណត់ថា ការវាយប្រហារប្រឆាំងនឹងប្រជាជនស៊ីវិលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ចាំបាច់ត្រូវមើលលើលក្ខខណ្ឌតម្រូវមួយទៀត គឺការវាយប្រហារនោះ ត្រូវតែជាការវាយប្រហារដោយសារមូលហេតុជាតិ នយោបាយ ជាតិពន្ធុ ពូជសាសន៍ ឬសាសនា ។ ធាតុផ្សំនេះសំដៅទៅលើលក្ខណៈនៃការវាយប្រហារពុំមែនជាធាតុផ្សំនៃបទល្មើសណាមួយជាក់លាក់ឡើយ ។ ក្នុងការអនុវត្តការវាយប្រហារ ចាំបាច់ត្រូវតែមានចេតនារើសអើង ។[៩]

គួរកត់សម្គាល់ថា នៅត្រង់លក្ខខណ្ឌនៃការវាយប្រហារត្រូវតែធ្វើឡើងដោយសារមូលហេតុ ជាតិ នយោបាយ ជាតិពន្ធុ ពូជសាសន៍ ឬសាសនា គឺមានលក្ខណៈផ្សេងគ្នាពីតុលាការអន្តរជាតិមួយទៅតុលាការអន្តរជាតិមួយទៀត ដូចជា អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា តុលាការព្រហ្មទណ្ឌអន្តរជាតិ តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរវ៉ាន់ដាជាដើម ។ ឧទាហរណ៍ នៅត្រង់មាត្រា៥ នៃច្បាប់របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានចែងថា ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដែលគ្មានអាជ្ញាយុកាល គឺអំពើណាមួយដូចខាងក្រោម ដែលវាយប្រហារជាទូទៅ ឬដោយមានការរៀបចំប្រឆាំងទៅលើប្រជាជនស៊ីវិលដោយមូលហេតុ ជាតិ នយោបាយ ជាតិពន្ធុ ពូជសាសន៍ ឬសាសនា ណាមួយ ។ អង្គជំនុំជម្រះសាលាដំបូងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានបកស្រាយមាត្រានេះថាជាយុត្តាធិការបន្ថែម ដែលចែងទាក់ទងនឹងលក្ខណៈនៃ ការវាយប្រហារ មិនមែនទាក់ទងនឹងបទល្មើសជាក់លាក់នោះទេ ។ អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់បន្ថែមទៀតថា នៅក្រោមធម្មនុញ្ញ ណូរ៉េមបឺក (Nuremberg) ធម្មនុញ្ញ តូក្យូ (Tokyo) និងច្បាប់លេខ១០របស់ក្រុមប្រឹក្សាគ្រប់គ្រងបានបញ្ជាក់ថា រាល់ធាតុផ្សំជាមូលដ្ឋាននៃការរើសអើងត្រូវបានកំណត់ត្រឹមបទល្មើសដែលជាការធ្វើទុកបុកម្នេញ ក្នុងនោះធាតុចេតនានៃការរើសអើងតម្រូវឲ្យមានជាចាំបាច់ ។

រីឯ យុត្តិសាស្ត្រ និងលក្ខន្តិកៈរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ បានបញ្ជាក់ច្បាស់ថា ផ្អែកតាមច្បាប់ទំនៀមទម្លាប់អន្តរជាតិ ធាតុផ្សំចេតនានៃការរើសអើងមិនមែនជាធាតុផ្សំផ្លូវច្បាប់នៅក្នុងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ លើកលែងតែការធ្វើទុកបុកម្នេញដែលតម្រូវឲ្យមានធាតុចេតនានៃការរើសអើងនេះ ។

ដូច្នេះឃើញថា នៅក្នុងយុត្តិសាស្ត្រ និងលក្ខន្តិកៈរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ មានការកំណត់ផ្សេងគ្នាពីអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាទាក់ទងនឹងធាតុផ្សំចេតនានៃ ការរើសអើង ។

### ៥) ទំនាក់ទំនងរវាងអំពើរបស់ជនជាប់ចោទនឹងការវាយប្រហារ

អំពើរបស់ជនជាប់ចោទ ត្រូវតែជាផ្នែកមួយនៃការវាយ




ផែនទីរណ្តៅសាកសព (រូបថតមជ្ឈមណ្ឌលឯកសារកម្ពុជា)

ប្រហារជាសត្យានុម័ត ទោះជាអំពើនោះជាអំពើប្រភេទណាក៏ដោយ ឬមានផលវិបាកយ៉ាងណាក៏ដោយ ដរាបណាអំពើទាំងនោះមិនត្រូវបានកាត់ផ្ដាច់ទាំងស្រុងចេញពីបរិបទនៃការវាយប្រហារ ។

ឧក្រិដ្ឋកម្មមួយដែលត្រូវបានប្រព្រឹត្តឡើងមុន ឬក្រោយការវាយប្រហារជាចម្បងប្រឆាំងលើប្រជាជនស៊ីវិល ក៏អាចចាត់ទុកថាជាផ្នែកមួយនៃការវាយប្រហារដែរ ប្រសិនបើឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តមានទំនាក់ទំនងជិតស្និតជាមួយនឹងការវាយប្រហារនោះ ។[១០] ក៏ប៉ុន្តែ ប្រសិនបើឧក្រិដ្ឋកម្មមួយកើតឡើងនៅដាច់ឆ្ងាយពីកន្លែងដែលមានការវាយប្រហារ ហើយមិនមានហេតុផលសមស្របណាមួយ អាចនិយាយបានថាឧក្រិដ្ឋកម្មនោះជាផ្នែកមួយនៃការវាយប្រហារនៅពេលនោះឧក្រិដ្ឋកម្មដែលកើតឡើងពុំអាចចាត់ទុកជាការវាយប្រហារបានទេ ។

### ៦) លក្ខខណ្ឌដឹង

ជនជាប់ចោទនៃបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ត្រូវតែបានដឹងថា មានការវាយប្រហារលើប្រជាជនស៊ីវិល ព្រមទាំងដឹងថាអំពើរបស់ខ្លួនគឺជាផ្នែកមួយនៃការវាយប្រហារនោះ ។ ជនជាប់ចោទ ត្រូវដឹងអំពីបរិបទទាំងមូលដែលអំពើនោះកើតឡើង ប៉ុន្តែមិនចាំបាច់ត្រូវដឹងលម្អិតអំពីការវាយប្រហារ ឬរួមចំណែកដឹងអំពីគោលបំណង ឬគោលដៅនៃការវាយប្រហារនោះទេ ។

តើធ្វើយ៉ាងណាដើម្បីបង្ហាញថា ជនជាប់ចោទបានដឹង ឬមិនបានដឹងអំពីឧក្រិដ្ឋកម្មដែលបានកើតឡើង?

ចម្លើយនៃសំណួរនេះ គឺថាគេមិនអាចកំណត់អំពីលក្ខខណ្ឌជាក់លាក់បានទេ ប៉ុន្តែភស្តុតាងនៃការដឹង គឺអាស្រ័យលើអង្គហេតុនៃករណីជាក់លាក់នីមួយៗ ហើយការបង្ហាញធាតុផ្សំតាមផ្លូវច្បាប់ថាយ៉ាងណានោះ គឺអាស្រ័យតាមកាលៈទេសៈជាក់ស្ដែងនីមួយៗ ។[១១]

សូមបញ្ជាក់ថា ប្រសិនបើអវត្តមានធាតុផ្សំណាមួយ ក្នុងចំណោមធាតុផ្សំទូទៅទាំងអស់ខាងលើបទល្មើសទាំងឡាយដែលចែងនៅក្នុងមាត្រា៥ នៃច្បាប់ស្ដីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ពុំទាន់អាចចាត់ទុកថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិបាននៅឡើយទេ ។ បទល្មើសដែលកើតឡើង អាចចាត់ទុកបានត្រឹមតែជាឧក្រិដ្ឋកម្មសង្គ្រាម ឬបទល្មើសព្រហ្មទណ្ឌដែលស្ថិតនៅក្រោមច្បាប់ជាតិតែប៉ុណ្ណោះ ។[១២]

### បទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្នុងសំណុំរឿង០០១ និងសំណុំរឿង០០២

ក្នុងសំណុំរឿង០០១ អង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានរកឃើញថា ឌុច បានប្រព្រឹត្តបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិរួមមាន ៖

- ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ដែលរួមបញ្ចូលនូវបទល្មើសការសម្លាប់រង្គាល (រួមបញ្ចូលទាំងការធ្វើមនុស្សឃាត)
- ការធ្វើឲ្យទៅជាទាសករ
- ការដាក់ក្នុងមន្ទីរឃុំឃាំង
- ការធ្វើទារុណកម្ម (រួមទាំងការរំលោភលើផ្លូវភេទមួយករណី) និង
- អំពើអមនុស្សធម៌ផ្សេងៗទៀត ។[១៣]

ក្រៅពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ អង្គជំនុំជម្រះសាលាដំបូងក៏បានផ្ដន្ទាទោស ឌុច ពីបទបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ដែរ ហើយបានសម្រេចដាក់ពន្ធនាគាររយៈ៣៥ឆ្នាំ ។

ទោះបីជាយ៉ាងណា អង្គជំនុំជម្រះតុលាការកំពូលនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានសម្រេចបដិសេធការរកឃើញរបស់អង្គជំនុំជម្រះសាលាដំបូង នៅត្រង់ចំណុចស្រូបបញ្ចូលបទឧក្រិដ្ឋ មូលដ្ឋានដទៃទៀតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិទៅក្នុងបទធ្វើទុក្ខបុកម្នេញនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលអង្គជំនុំជម្រះសាលាដំបូងបានរកឃើញថា ឌុច ជាអ្នកទទួលខុសត្រូវ ។[១៤] ប៉ុន្តែបានបន្ថែមទម្ងន់ទោសចំពោះ ឌុច ពីបទសម្លាប់រង្គាល (រួមបញ្ចូលអំពើមនុស្សឃាត) បទធ្វើឲ្យទៅជាទាសករ បទដាក់ក្នុងមន្ទីរឃុំឃាំងបទធ្វើទារុណកម្ម និងអំពើអនុស្សធម៌ផ្សេងៗទៀត ។ ដោយសារការបន្ថែមទម្ងន់ទោស ឌុច ត្រូវអង្គជំនុំជម្រះតុលាការកំពូលសម្រេចដាក់ក្នុងពន្ធនាគារអស់មួយជីវិត ។

ចំពោះសំណុំរឿង០០២ នាពេលបច្ចុប្បន្ន មានតែជនជាប់ចោទ ខៀវ សំផន និង នួន ជា តែប៉ុណ្ណោះ ដែលកំពុងទទួលការជំនុំជម្រះនៅក្នុងសវនាការដំណាក់កាលដំបូង ដោយផ្ដោតជាសំខាន់លើឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ។ ផ្នែកដំបូងដែលអង្គ

ជំនុំជម្រះលើកយកមកបើកសវនាការនេះ ត្រូវបានកំណត់ថាជាសំណុំរឿង០០២/០១ ។ អង្គហេតុពាក់ព័ន្ធ ដែលអង្គជំនុំជម្រះសាលាដំបូងលើកយកមកជំនុំជម្រះទាក់ទងនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅក្នុងសំណុំរឿង០០២/០១នេះ រួមមានការផ្លាស់ទីលំនៅប្រជាជនដោយបង្ខំ ដំណាក់កាលទី១ និងដំណាក់កាលទី២ និងការសម្លាប់អតីតទាហាន លន់ នល់ នៅទួលពោធិជ្រៃ ក្នុងខេត្តពោធិសាត់ បន្ទាប់ពីខ្មែរក្រហមបានឡើងកាន់អំណាចភ្លាមៗក្នុងឆ្នាំ១៩៧៥ ។ បទល្មើសជាក់លាក់នៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលអង្គជំនុំជម្រះលើកយកមកពិចារណាក្នុងសវនាការសំណុំរឿង០០២/០១ មានដូចជា ៖

១ ការធ្វើមនុស្សឃាត (នៅអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី១ និងការសម្លាប់អតីតទាហាន លន់ នល់ នៅទួលពោធិជ្រៃភ្លាមៗបន្ទាប់ពីខ្មែរក្រហមឡើងកាន់អំណាច) ។

២ ការសម្លាប់រង្គាល (នៅអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី១ និងដំណាក់កាលទី២ និងការសម្លាប់អតីតទាហាន លន់ នល់ នៅទួលពោធិជ្រៃភ្លាមៗបន្ទាប់ពីខ្មែរក្រហមឡើងកាន់អំណាច) ។

៣ ការធ្វើទុក្ខបុកម្នេញខាងនយោបាយ (នៅអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជន ដំណាក់កាលទី១ និងដំណាក់កាលទី២ និងការសម្លាប់អតីតទាហាន លន់ នល់ នៅទួលពោធិជ្រៃភ្លាមៗ បន្ទាប់ពីខ្មែរក្រហមឡើងកាន់អំណាច) ។

៤ អំពើអមនុស្សធម៌ផ្សេងៗទៀតក្រោមទម្រង់ជាការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស (នៅអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជន ដំណាក់កាលទី១ និងដំណាក់កាលទី២) ។

៥ អំពើអមនុស្សធម៌ផ្សេងៗទៀតក្រោមទម្រង់ជាការជម្លៀសដោយបង្ខំ (នៅអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី១ និងដំណាក់កាលទី២) ។

៦ ការបាត់ខ្លួនដោយបង្ខំ (នៅអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី២) ។[១៥]

អង្គជំនុំជម្រះគ្រោងនឹងបញ្ចប់ កិច្ចពិភាក្សាដេញដោលលើសំណុំរឿង០០២/០១ ដោយអនុញ្ញាតឲ្យភាគីធ្វើសេចក្តីសន្និដ្ឋានបិទបញ្ចប់ នៅក្នុងសវនាការចាប់ពីថ្ងៃទី១៦ ដល់ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៣ ។ អង្គជំនុំជម្រះអាចនឹងចេញសាលក្រមសម្រេចសេចក្តីលើសំណុំរឿង០០២/០១ ទាក់ទងនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៅក្នុងឆមាសទី១ ឆ្នាំ២០១៤ ។

[១] មាត្រា៥ នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានចែងទាក់ទងនឹង«ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ» ថា «ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលជាឧក្រិដ្ឋកម្មគ្មានអាជ្ញាយុកាល គឺអំពើណាមួយដូចខាងក្រោម ដែលវាយប្រហារជាទូទៅ ឬដោយមានការរៀបចំប្រឆាំងទៅលើប្រជាជនស៊ីវិល ដោយមូលហេតុជាតិ នយោបាយ ជាតិពន្ធុ ពូជសាសន៍ ឬសាសនាណាមួយ [...]» ។ រីឯមាត្រា៥ នៃលក្ខន្តិកៈតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី [ICTY] បានបញ្ញត្តិទាក់ទងនឹង«ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ» ថា «តុលាការ [ICTY] ត្រូវមានអំណាចដើម្បីកាត់សេចក្តីលើបុគ្គលនានាដែលទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដូចខាងក្រោម នៅពេលឧក្រិដ្ឋកម្មនោះបានប្រព្រឹត្តនៅក្នុងជម្លោះប្រដាប់អាវុធ ទោះបីជាមានចរិតលក្ខណៈជាអន្តរជាតិ ឬជាជម្លោះផ្ទៃក្នុង និងសំដៅប្រឆាំងលើប្រជាជនស៊ីវិលណាមួយ [...]» ។ ផ្ទុយពីតុលាការ [ICTY] និងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា [ECCC] តុលាការព្រហ្មទណ្ឌអន្តរជាតិ[ICC] បានចែងនៅត្រង់មាត្រា៧ នៃលក្ខន្តិកៈរបស់ខ្លួនថា «ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិមានន័យថា ជាអំពើណាមួយដូចខាងក្រោម ដែលបានប្រព្រឹត្តឡើងជាផ្នែកនៃការវាយប្រហារជាទូទៅ ឬដោយមានការរៀបចំសំដៅប្រឆាំងទៅលើប្រជាជនស៊ីវិលណាមួយ ដោយមានការដឹងពីការវាយប្រហារនោះ[...]» ។ សូមមើលផងដែរ សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃ ទី២៦ ខែកក្កដា ឆ្នាំ២០១០, ឯកសារE188, កថាខណ្ឌ២៨១, ២៨៩-២៩០ និងសូមមើលកំណត់សម្គាល់ជើងទំព័រលេខ៥៣៦ និង៥៣៩ ។

[២] មាត្រា៥ នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ សូមបញ្ជាក់ថា ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ដែលចូលជាធរមាននៅក្នុងឆ្នាំ២០១០ នៅ

ត្រង់មាត្រា១៨៨ ទាក់ទងនឹង"បទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ" ក៏បានចែងស្រដៀងគ្នាទៅនឹងមាត្រា៥ នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដែរ ។ មាត្រា១៨៨ បានចែងថា ៖ "បទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ គឺជាអំពើណាមួយក្នុងចំណោមអំពើដែលរៀបរាប់ខាងក្រោមនេះ កាលបើអំពើនេះត្រូវបានប្រព្រឹត្តនៅក្នុងក្របខ័ណ្ឌនៃការវាយលុយជាទូទៅ ឬជាប្រព័ន្ធ សំដៅប្រឆាំងប្រជាជនស៊ីវិល ៖

១) ឃាតកម្ម ។

២) ការសម្លាប់រង្គាល ។

៣) ការធ្វើឲ្យទៅជាទាសករ ។

៤) ការនិរទេស ឬជម្លៀសប្រជាជនដោយបង្ខំ ។

៥) ការដាក់ពន្ធនាគារ ឬគ្រប់រូបភាពដទៃទៀតនៃការដកហូតយ៉ាងធ្ងន់ធ្ងរនូវសេរីភាពដោយបំពានទៅលើបទប្បញ្ញត្តិគ្រឹះនៃនីតិអន្តរជាតិ ។

៦) ការធ្វើទារុណកម្ម ។

៧) ការចាប់បង្ខំសេពសន្ថវៈ ការធ្វើទាសកម្មខាងផ្លូវភេទ ពេស្យាចារដោយបង្ខំ ការមានគភ៌ដោយបង្ខំ វិញ្ញកម្មដោយបង្ខំ និងគ្រប់រូបភាពផ្សេងទៀតនៃអំពើហិង្សាខាងផ្លូវភេទ ដែលមានទម្ងន់ប្រហាក់ប្រហែលគ្នា ។

៨) ការធ្វើទុក្ខបុកម្នេញលើក្រុម ឬសមូហភាពដោយមូលហេតុនយោបាយ ពូជសាសន៍ ក្រុមជាតិ ជាតិពន្ធុ វប្បធម៌ សាសនា ឬភេទ ។

៩) ការបាត់ខ្លួនដោយបង្ខំ ។

១០) ការអនុវត្តនយោបាយប្រកាន់ពូជសាសន៍ជាប្រព័ន្ធតាមបែបអាប៉ាថេដ ។

១១) គ្រប់អំពើអមនុស្សធម៌ផ្សេងទៀត ដែលបង្កឲ្យមានការឈឺចាប់យ៉ាងខ្លាំង ឬការប៉ះពាល់យ៉ាងធ្ងន់ធ្ងរទៅលើបូរណភាពខាងរូបកាយ ។

យោងលើមាត្រា១៨៩ នៃក្រមព្រហ្មទណ្ឌដដែលនេះ ប្រសិនបើជនណាម្នាក់ត្រូវបានរកឃើញថាមានពិរុទ្ធភាព ទាក់ទងនឹងការប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនឹងត្រូវផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត ។

៣ សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង,សំណុំរឿង០០១ករណី កាំង ហ្គេកអ៊ាវ ហៅ ឌុច ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០, ឯកសារE188, កថាខណ្ឌ២៩៧ ។ [បន្ទាប់ពីនេះនឹងហៅថា សាលក្រម ឌុច]

៤ ដដែល ដូចខាងលើ ។ កថាខណ្ឌ២៩៨ ។

៥ ដដែល ដូចខាងលើ ។ កថាខណ្ឌ២៩៩ ។

៦ ដដែល ដូចខាងលើ ។ កថាខណ្ឌ៣០០ ។

៧ ដដែល ដូចខាងលើ ។ កថាខណ្ឌ៣០១ ។

៨ ដដែល ដូចខាងលើ ។ កថាខណ្ឌ៣០២-៣១២ ។

៩ ដីកាសន្និដ្ឋានស្តាពររបស់ព្រះរាជអាជ្ញា អនុលោមតាមវិធាន ៦៦, ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១០, ឯកសារ D390, កថាខណ្ឌទី១២៥០ ។

១០ សាលក្រម ឌុច, កថាខណ្ឌ៣១៨ ។

១១ ដដែល ដូចខាងលើ ។ កថាខណ្ឌ៣១៩ ។

១២ សូមមើលសៀវភៅ INTERNATIONAL CRIMINAL LAW, និពន្ធដោយ Antonio Cassese, ទំព័រ១១៥, បោះពុម្ពលើក ទី២ ឆ្នាំ២០០៨, បោះពុម្ពនៅសហរដ្ឋអាមេរិក ដោយ Oxford University Press Inc., New York ។

១៣ សាលក្រម ឌុច, កថាខណ្ឌ៦៧៧ ។

១៤ សំណុំរឿង០០១ សាលដីកា អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១២, ឯកសារF28, ទំព័រ៥៦២ ជាភាសាខ្មែរ ។

១៥ ឧបសម្ព័ន្ធ, បញ្ជីកថាខណ្ឌ និងផ្នែកនានានៃដីកាដំណោះស្រាយដែលទាក់ទងនឹងការជំនុំជម្រះដំណាក់កាលដំបូង នៅក្នុងសំណុំរឿង០០២/០១ ដែលបានធ្វើការកែប្រែបន្ទាប់ពីអង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្តីសម្រេចអំពីបញ្ហាសម្បទារបស់ អៀង ធីរិទ្ធ ក្នុងការចូលរួមសវនាការ និងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង លើសំណើរបស់សហព្រះរាជអាជ្ញា ក្នុងការបញ្ចូលទីតាំងឧក្រិដ្ឋកម្មបន្ថែមនៅក្នុងវិសាលភាពនៃការជំនុំជម្រះសំណុំរឿង០០២/០១, ឯកសារ E124/7.3 ។

# សិទ្ធិពិនិត្យមើលសំណុំរឿងក្តីព្រហ្មទណ្ឌ

ចាន់ ប្រាថ្នា

សិទ្ធិចូលពិនិត្យមើលសំណុំរឿងត្រូវបានទទួលស្គាល់ថាជាផ្នែកមួយនៃសិទ្ធិទទួលបានមធ្យោបាយគ្រប់គ្រាន់ក្នុងការតទល់ក្តីទាំងនៅក្នុងដំណាក់កាលស៊ើបអង្កេត និងដំណាក់កាលជំនុំជម្រះក្តី ។ លក្ខណៈសារវន្តនៃសិទ្ធិនេះ បានជួយដល់ភាគីនៃរឿងក្តីអនុវត្តសិទ្ធិផ្សេងៗទៀត (ដូចជា សិទ្ធិសុំឲ្យចៅក្រមបំពេញកិច្ចស៊ើបសួរបន្ថែម សិទ្ធិតទល់ជាមួយសាក្សី ឬគូភាគីបដិបក្ខ សិទ្ធិសុំឲ្យចុះទៅពិនិត្យដល់ទីកន្លែង ចាប់យកវត្ថុតាង ធ្វើកោសល្យវិច័យជាដើម) ឲ្យមានប្រសិទ្ធិភាព ។ សិទ្ធិទាំងនេះនឹងត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាពនៅពេលដែលភាគីនៃរឿងក្តីទទួលបានព័ត៌មានគ្រប់គ្រាន់ (ភស្តុតាងដែលត្រូវបានប្រមូល ឬដាក់ជូនដើម្បីគាំទ្រការចោទប្រកាន់) ដែលមាននៅក្នុងសំណុំរឿង ។

## ១) មូលដ្ឋានគតិយុត្ត

នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា សិទ្ធិចូលពិនិត្យមើលសំណុំរឿងមានចែងក្នុងមាត្រា១២៩, ១៣៥ និងមាត្រា៣១៩ ។ នៅក្នុងដំណាក់កាលស៊ើបសួរ មាត្រា១២៩ ចែងថា "សំណុំរឿងស៊ើបសួរត្រូវរក្សាទុកដោយក្រឡាបញ្ជី ។ [...] មេធាវី ឬលេខាធិការរបស់មេធាវី ត្រូវបានអនុញ្ញាត ដោយចៅក្រមស៊ើបសួរឲ្យធ្វើការថតចម្លង ដោយខ្លួនជាអ្នកចេញសោហ៊ុយ និងក្រោមការត្រួតពិនិត្យរបស់ក្រឡាបញ្ជី" ។ មាត្រានេះបញ្ជាក់យ៉ាងច្បាស់ថាសោហ៊ុយក្នុងការថតចម្លងសំណុំរឿងជាបន្ទុករបស់មេធាវី ។ គួរកត់សម្គាល់ថា វិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះពុំបានបញ្ជាក់អំពីបញ្ហានេះឡើយ ។ ដូច្នេះ ក្នុងការអនុវត្តអាចមានការខ្វែងគំនិតគ្នាក្នុងការបកស្រាយថាតើសោហ៊ុយនៃការថតចម្លងសំណុំរឿងនៅអង្គជំនុំជម្រះវិសាមញ្ញ ដែលមានឯកសារភស្តុតាងដ៏ច្រើនសន្ធឹកសន្ធាប់នោះ ជាបន្ទុករបស់មេធាវី ឬរបស់តុលាការ ។ ទាក់ទងនឹងមាត្រា១៣៥ ស្តីអំពីការបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញាចែងថា "នៅគ្រប់ពេលវេលា ព្រះរាជអាជ្ញាអាចពិនិត្យមើលសំណុំរឿងស៊ើបសួរ ឬស្នើសុំឲ្យបញ្ជូនសំណុំរឿងមកពិនិត្យ ប៉ុន្តែត្រូវមានភារកិច្ចបង្វិលសំណុំរឿងនេះទៅវិញ ក្នុងថិរវេលា២៤ម៉ោង" ។ ចំណែកមាត្រា៣១៩ (ចែងក្នុងបរិបទដែលសំណុំរឿងត្រូវបានបញ្ជូនទៅជំនុំជម្រះ) ស្តីអំពីការពិនិត្យមើលសំណុំរឿងបានចែងថា "មុនពេលសវនាការ មេធាវីអាចពិនិត្យមើលសំណុំរឿងនៅការិយាល័យក្រឡាបញ្ជីនៃតុលាការ នៅក្រោមការត្រួតពិនិត្យរបស់ក្រឡាបញ្ជី ។ មេធាវី ឬលេខាធិការរបស់មេធាវី អាចត្រូវបានអនុញ្ញាតដោយប្រធានតុលាការឲ្យធ្វើការថតចម្លងលិខិតនៃសំណុំរឿង ដោយខ្លួនជាអ្នកចេញសោហ៊ុយ និងនៅក្រោមការត្រួតពិនិត្យរបស់ក្រឡាបញ្ជី" ។ យោងតាមមាត្រានេះ អាចមានការបកស្រាយថា នៅក្នុងប្រព័ន្ធតុលាការកម្ពុជា មេធាវីអាចពិនិត្យមើលសំណុំរឿងបានតែនៅមុនពេលសវនាការតែប៉ុណ្ណោះ ។ វិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញពុំបានចែងរឹតត្បិតដូចមាត្រា៣១៩ឡើយ ។ បានន័យថា ទាំងនៅមុន និងក្នុងអំឡុងពេលដំណើរការជំនុំជម្រះក្តី មេធាវីអាចពិនិត្យមើល និងថតចម្លងសំណុំរឿងគ្រប់ពេលវេលា (ក្នុងម៉ោងធ្វើការ) ។ ពុំមានអ្វីចម្លែកនោះទេ ដែលវិធានផ្ទៃក្នុងផ្តល់ការអនុគ្រោះដូច្នេះ ព្រោះដំណើរការជំនុំជម្រះសេចក្តីទៅលើសំណុំរឿងនីមួយៗនៅអង្គជំនុំជម្រះវិសាមញ្ញ មានរយៈពេលយូរ បើធៀបទៅនឹងដំណើរការជំនុំជម្រះនៅតុលាការកម្ពុជាបច្ចុប្បន្ន ។

នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា សិទ្ធិចូលពិនិត្យមើសំណុំរឿងមានចែងនៅក្នុងវិធាន៥៥ និងវិធាន៨៦ នៃវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះ ។ វិធាន៥៥ កថាខណ្ឌទី៦ ចែងថា "ក្រឡាបញ្ជីរបស់សហចៅក្រមស៊ើបអង្កេត ត្រូវរក្សាទុកសំណុំរឿង រួមទាំងកំណត់ហេតុ និងរបាយការណ៍នៃការស៊ើបសួរ ។ សហព្រះរាជអាជ្ញា និងមេធាវីរបស់ភាគីទាំងអស់ មានសិទ្ធិគ្រប់ពេលវេលាក្នុងការពិនិត្យ និងថតចម្លងសំណុំរឿង ក្រោមការឃ្លាំមើលរបស់ក្រឡាបញ្ជីនៃការិយាល័យសហចៅក្រមស៊ើបអង្កេត ក្នុងពេលម៉ោងធ្វើការ និងគោរពទៅតាមបទបញ្ជារបស់អង្គជំនុំជម្រះវិសាមញ្ញ" ។ កថាខណ្ឌ១១ ក្នុងវិធានដដែលនេះ បានបញ្ជាក់បន្ថែមថា "សហព្រះរាជអាជ្ញា និងមេធាវីរបស់ភាគី

ពាក់ព័ន្ធ មានសិទ្ធិសុំមើលសំណុំរឿងច្បាប់ដើម ប៉ុន្តែត្រូវគោរពទៅតាមពេលវេលាកំណត់ ដើម្បីធានាដល់និរន្តរភាពនៃកិច្ចដំណើរការនីតិវិធី» ។ តាមរយៈវិធាននេះ សហព្រះរាជអាជ្ញា និងមេធាវីរបស់ភាគីទាំងអស់មានសិទ្ធិពិនិត្យមើល និងថតចម្លងសំណុំរឿងនៅក្នុងអំឡុងពេលស៊ើបសួរទាំងមូល ។ វិធាន៨៦ ដែលអនុញ្ញាតឲ្យពិនិត្យមើលសំណុំរឿងនៅដំណាក់កាលជំនុំជម្រះក្តីបានចែងថា «សហព្រះរាជអាជ្ញា និងមេធាវីរបស់ភាគីទាំងអស់ ត្រូវមានសិទ្ធិពិនិត្យមើល និងថតចម្លងសំណុំរឿង ដោយស្ថិតនៅក្រោមការត្រួតពិនិត្យរបស់ក្រឡាបញ្ជីនៃអង្គជំនុំជម្រះសាលាដំបូង នៅពេលម៉ោងធ្វើការ និងត្រូវគោរពទៅតាមលក្ខខណ្ឌតម្រូវសម្រាប់ដំណើរការល្អរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា» ។[1]

### ក) បុគ្គលដែលមានសិទ្ធិចូលពិនិត្យមើលសំណុំរឿង

បើពិនិត្យមើលវិធាន៨៥ និង៨៦ នៃវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញ បានបង្ហាញយ៉ាងច្បាស់ថា មានតែសហព្រះរាជអាជ្ញា និងមេធាវីរបស់ភាគីប៉ុណ្ណោះ ទើបមានសិទ្ធិចូលពិនិត្យមើលសំណុំរឿង ។ ចំណែក«ភាគី» ដែលបានបញ្ជាក់នៅក្នុងវិធានទាំងពីរនេះ គឺពុំត្រូវបានអនុញ្ញាតឲ្យចូលពិនិត្យមើលសំណុំរឿងឡើយ ។

យោងតាមសន្ទានុក្រមនៅក្នុងវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះ ពាក្យ«ភាគី»សំដៅទៅលើសហព្រះរាជអាជ្ញា ជនត្រូវចោទ ជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណី ។ ចំណែក«ជនសង្ស័យ» ពុំត្រូវបានរាប់បញ្ចូលជាភាគីនៃរឿងក្តីនោះទេ ។ នេះបញ្ជាក់ថា មេធាវីរបស់ជនសង្ស័យ ពុំមានសិទ្ធិចូលពិនិត្យមើល និងថតចម្លងសំណុំរឿង ដូចមានចែងក្នុងវិធាន៨៥ និង៨៦ឡើយ ។ ដូច្នេះ មានតែសហព្រះរាជអាជ្ញា មេធាវីរបស់ជនត្រូវចោទមេធាវីរបស់ជនជាប់ចោទ និងមេធាវីរបស់ដើមបណ្តឹងរដ្ឋប្បវេណីប៉ុណ្ណោះ ដែលមានសិទ្ធិចូលពិនិត្យមើល និងថតចម្លងសំណុំរឿងក្នុងអំឡុងពេលស៊ើបសួរ និងការជំនុំជម្រះសេចក្តី ។ សេចក្តីសម្រេចចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៣ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ម៉ាក ហាម៉ុន ទទួលស្គាល់ថា សិទ្ធិចូលពិនិត្យមើលសំណុំរឿង ត្រូវបានរក្សាទុកផ្តាច់មុខជូនសហព្រះរាជអាជ្ញា និងមេធាវីរបស់ភាគីតែប៉ុណ្ណោះ ។[2] គួរកត់សម្គាល់ថា បើយោងទៅលើមាត្រា១២៩ និងមាត្រា៣១៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ អាចមានការបកស្រាយទូលាយជាងនេះ ព្រោះមាត្រាទាំងពីរនេះគ្រាន់តែបញ្ជាក់ថា «មេធាវី ឬលេខាធិការមេធាវី» ដោយពុំបានភ្ជាប់ទៅនឹងពាក្យ«របស់ភាគី»ដូចវិធានផ្ទៃក្នុងឡើយ ។ ក្នុងករណីនេះ ប្រសិនបើមាត្រា១២៩ អាចអនុវត្តបាននៅអង្គជំនុំជម្រះវិសាមញ្ញ នោះមេធាវីការពារក្តីរបស់«ជនសង្ស័យ»នឹងមិនអាច



ប្រជាជនក្នុងតំបន់គ្រប់គ្រងដោយខ្មែរក្រហម កំពុងចូលរួមស្តាប់សន្ទរក
ថតដោយ ដេ. ខូហ្ម៉ាន់ (រូប

ត្រូវបានបកស្រាយ ដោយផាត់ចេញពីសិទ្ធិពិនិត្យមើល និងថតចម្លងសំណុំរឿងឡើយ ។

គួរបញ្ជាក់ថា សន្ទានុក្រមនៃវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញបានផ្តល់អត្ថន័យ និងប្រើប្រាស់ពាក្យ ជនសង្ស័យ ជនត្រូវចោទ ជនជាប់ចោទ នៅក្នុងបរិបទផ្សេងៗគ្នា ។ តាមរយៈពាក្យទាំងនេះ សហចៅក្រមស៊ើបអង្កេត និងអង្គបុរេជំនុំជម្រះ បានធ្វើការបកស្រាយយ៉ាងតឹងរ៉ឹងអំពីសិទ្ធិចូលពិនិត្យមើលសំណុំ

រឿងរបស់មេធាវីការពារក្ដីជនដែលមានឈ្មោះនៅក្នុងសំណុំរឿង ០០៣ និង០០៤ ដែលកំពុងស្ថិតនៅក្រោមការស៊ើបសួររហូតមកដល់ពេលបច្ចុប្បន្ននេះ (នឹងលើកឡើងលម្អិតនៅក្នុងចំណុចទី២) ។ ពាក្យទាំងបីនេះ ត្រូវបានសន្មានុក្រមនៃវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះបានផ្ដល់អត្ថន័យដូចខាងក្រោម៖[៣]

ជនសង្ស័យ (Suspect) “សំដៅទៅលើបុគ្គលដែលសហព្រះរាជអាជ្ញា ឬសហចៅក្រមស៊ើបអង្កេត ចាត់ទុកថា អាចធ្លាប់បានប្រព្រឹត្តបទឧក្រិដ្ឋ ដែលស្ថិតនៅក្នុងយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញ ប៉ុន្តែមិនទាន់ត្រូវបានចោទប្រកាន់នៅឡើយ” ។


ថារបស់ថ្នាក់ដឹកនាំខ្មែរក្រហមនៅជិតព្រំដែនថៃ ក្នុងអំឡុងឆ្នាំ១៩៨០ ។
ថតមជ្ឈមណ្ឌលឯកសារកម្ពុជា)

ជនត្រូវចោទ (Charged Person) “សំដៅទៅលើបុគ្គលណាម្នាក់ដែលត្រូវចោទប្រកាន់ចំពោះរឿងក្ដីណាមួយ ក្នុងចន្លោះពេលពីមានដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររហូតដល់ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ឬដីកាលើកលែងការចោទប្រកាន់” ។

ជនជាប់ចោទ (Accused) “សំដៅទៅលើបុគ្គលដែលត្រូវបានចោទប្រកាន់ (person who has been indicted) ដោយសហចៅក្រមស៊ើបអង្កេត ឬអង្គបុរេជំនុំជម្រះ” ។

### ១) អ្វីទៅជាសំណុំរឿង?

យោងតាមសន្ទានុក្រមនៅក្នុងវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះ សំណុំរឿង គឺសំដៅទៅដល់ “សំណុំឯកសារ ដែលរួមមានកំណត់ហេតុនៃកិច្ចដែលបានបំពេញនៅក្នុងអំឡុងពេលនៃការស៊ើបអង្កេតបឋម ឬការស៊ើបសួរ ក៏ដូចជាពាក្យសុំរបស់ភាគី សេចក្ដីសម្រេចទាំងឡាយដែលបានចេញ និងអ្វីដែលជាឧបសម្ព័ន្ធដែលមាននៅក្នុងគ្រប់ដំណាក់កាលនីតិវិធី រួមទាំងកំណត់ហេតុសវនាការផង” ។ ដូច្នេះ រាល់ឯកសារភស្តុតាង និងវត្ថុតាងទាំងអស់ដែលប្រមូលបាន ត្រូវតែដាក់បញ្ចូលទៅក្នុងសំណុំរឿង ។ វិធាន៨៧ នៃវិធានផ្ទៃក្នុងចែងថា “អង្គជំនុំជម្រះសាលាដំបូងធ្វើសេចក្ដីសម្រេចដោយផ្អែកលើភស្តុតាងដែលមាននៅក្នុងសំណុំរឿង (ប៉ុន្តែភស្តុតាងទាំងនោះត្រូវតែបានដាក់នៅចំពោះមុខអង្គជំនុំជម្រះ) ” ។ ដូច្នេះមានន័យថា ពុំមានភស្តុតាងណាមួយដែលមិនមាននៅក្នុងសំណុំរឿងត្រូវបានយកមកពិចារណាឡើយ ។ គួរបញ្ជាក់ថា ក្នុងអំឡុងពេលសវនាការលើអង្គសេចក្ដីក្នុងសំណុំរឿង ០០២ ភាគីនៃរឿងក្ដីពុំត្រូវបានអនុញ្ញាតឲ្យយកឯកសារភស្តុតាងណាមួយ ដែលមិនមាននៅក្នុងសំណុំរឿង យកមកសួរដេញដោលឡើយ ។

ដូចបានបញ្ជាក់រួចហើយថា វិធាន៥៥ និង៨៦ បានអនុញ្ញាតឲ្យសហព្រះរាជអាជ្ញា និងមេធាវីរបស់ភាគីមានសិទ្ធិពិនិត្យមើល និងថតចម្លងសំណុំរឿង ។ វិធានទាំងពីរនេះពុំបានរឹតត្បិតទៅលើវិសាលនៃសំណុំរឿង ពោលគឺពុំបានហាមឃាត់សិទ្ធិរបស់សហព្រះរាជអាជ្ញា និងមេធាវីរបស់ភាគី ក្នុងការពិនិត្យមើលវត្ថុតាង និងឯកសារសម្ងាត់ផ្សេងៗ ដែលមាននៅក្នុងសំណុំរឿងឡើយ ។ លើសពីនេះ នៅក្នុងអំឡុងពេលដំណើរការស៊ើបសួរ វិធាន៥៥ (១១) បានអនុញ្ញាតឲ្យពិនិត្យមើលសំណុំរឿង“ច្បាប់ដើម”ថែមទៀត ។ និយាយជារួម សហព្រះរាជអាជ្ញា និងមេធាវីរបស់ភាគីអាចពិនិត្យមើល និងថតចម្លងឯកសារទាំងអស់ដែលមាននៅក្នុងសំណុំរឿង ។

### ៧) ការអនុវត្តជាក់ស្តែងក្នុងការសុំចូលពិនិត្យមើលសំណុំរឿង ០០៣ និង០០៤

នៅថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១០ ប្រធានអង្គភាពគាំពារការការក្តីបានដាក់លិខិតមួយច្បាប់ ជូនទៅសហចៅក្រមស៊ើបអង្កេតសុំចូលពិនិត្យមើលសំណុំរឿង០០៣ និង០០៤ និងសិទ្ធិផ្សេងៗទៀតដូចមានចែងនៅក្នុងវិធាន៥៥ នៃវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះ ។ ប្រធានអង្គភាពនេះអះអាងថា ភាពចំបាច់នៃសំណើសុំនេះ គឺធ្វើឡើងដើម្បីធានាឲ្យមានការការពារសិទ្ធិរបស់ជនដែលមានឈ្មោះនៅក្នុងសំណុំរឿង០០៣ និង០០៤ ហើយការមិនឆ្លើយតបទាន់ពេលវេលាចំពោះសំណើទាំងនេះ បង្កឲ្យមានផលប៉ះពាល់ដល់សិទ្ធិទទួលបានការកាត់ក្តីដោយយុត្តិធម៌របស់ជនទាំងនោះ ។[៤] នៅថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១០ សហចៅក្រមស៊ើបអង្កេតចេញសេចក្តីសម្រេចបដិសេធសំណើសុំទាំងនោះចោល ដោយបញ្ជាក់ថា "សិទ្ធិការពារក្តីអាចអនុវត្តបានយ៉ាងពេញលេញ (ហើយគោលការណ៍សមភាពនៃមធ្យោបាយ តទល់ក្តីត្រូវតែគោរពយ៉ាងខ្ជាប់ខ្ជួន) នៅពេលជនម្នាក់ត្រូវបានចោទប្រកាន់ ហើយក្លាយជាភាគីនៃកិច្ចដំណើរការនីតិវិធី ។ ប៉ុន្តែ ដរាបណាជនណាម្នាក់មិនទាន់ត្រូវបានចោទប្រកាន់ជាផ្លូវការ សិទ្ធិរបស់ជននោះនៅមានកម្រិតនៅឡើយ" ។[៥]

នៅថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១១ មេធាវី គង់ សំអុន (ត្រូវបានចាត់តាំងជាមេធាវីជាតិ សម្រាប់តំណាងឲ្យផលប្រយោជន៍បុគ្គលដែលមានឈ្មោះនៅក្នុងសំណុំរឿង០០៣ និង០០៤កាលពីថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ២០១០) បានដាក់សំណើសុំចូលពិនិត្យមើលសំណុំរឿង០០៣ និង០០៤ ម្តងទៀត ។ ក្នុងការគាំទ្រសំណើសុំរបស់ខ្លួន មេធាវី គង់ សំអុន បានយោងទៅលើគោលការណ៍សមភាពនៃមធ្យោបាយតទល់ក្តី និងសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ ដោយអះអាងថា សិទ្ធិ និងគោលការណ៍ទាំងនេះត្រូវយកមកអនុវត្ត នៅពេលផលប្រយោជន៍របស់ជនសង្ស័យ "ត្រូវបានប៉ះពាល់ជាដុំកំភួន" ។ មេធាវី គង់ សំអុន បានអះអាងបន្ថែមទៀតថា ការណ៍ដែលក្រុមមេធាវីការពារក្តីមិនអាចតាមដានកិច្ចដំណើរការស៊ើបអង្កេត និងរៀបចំការការពារក្តីឲ្យបានប្រសិទ្ធិភាពនឹងធ្វើឲ្យប៉ះពាល់យ៉ាងខ្លាំងដល់សិទ្ធិរបស់ជនដែលមានឈ្មោះនៅក្នុងសំណុំរឿងទាំងពីរនេះ ។[៦] ទោះបីជាមានការបញ្ជាក់អះអាង ដូច្នេះក្តីសហចៅក្រមស៊ើបអង្កេតនៅតែសម្រេចបដិសេធ (សេចក្តីសម្រេចចុះថ្ងៃទី៥ ខែមេសា ឆ្នាំ២០១១) មិនឲ្យមេធាវី គង់ សំអុន ចូលមើលសំណុំរឿង០០៣ និង០០៤ដដែល ។ សហចៅក្រមស៊ើបអង្កេតបានផ្តល់ហេតុផលថា ជនដែលមានឈ្មោះនៅក្នុងសំណុំរឿងទាំងពីរនេះ ពុំទាន់ត្រូវបានចោទប្រកាន់ "តាមរយៈនីតិវិធីផ្លូវការដូចមានចែងនៅក្នុងវិធាន៥៧[៧] នៃវិធានផ្ទៃក្នុង" ហើយផលប្រយោជន៍របស់ជនទាំងនោះ ក៏ពុំទាន់ត្រូវបានប៉ះពាល់ធ្ងន់ធ្ងរដោយសារការស៊ើបអង្កេតដែរ ព្រោះជនទាំងនោះ "ពុំទាន់ត្រូវបានទាក់ទងសួរយកចម្លើយ ក្លាយជាកម្មវត្ថុនៃការឆែកឆេរនិងរឹបអូស ឃុំខ្លួន ឬត្រូវទទួលរងការប៉ះពាល់តាមវិធីដទៃទៀត ដោយការស៊ើបសួររបស់សហចៅក្រមស៊ើបអង្កេត" ។[៨]

នៅថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១ មេធាវី គង់ សំអុន ដាក់សំណើទៅសហចៅក្រមស៊ើបអង្កេត សុំឲ្យពិចារណាឡើងវិញទៅលើសេចក្តីសម្រេចចុះថ្ងៃទី៥ ខែមេសា ឆ្នាំ២០១១[៩] និងសុំការអនុញ្ញាតចូលមើលសំណុំរឿងជាថ្មីម្តងទៀត ដោយផ្តល់ហេតុផលថា មានបុគ្គលចំនួន២រូប (មិនបញ្ចេញឈ្មោះ) បានដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង០០៣ និង០០៤ ។ ប៉ុន្តែសំណើទាំងនេះត្រូវបានសហចៅក្រហមស៊ើបអង្កេតបដិសេធចោលនៅថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១១ (ក្នុងអំឡុងពេលចៅក្រម ស៊ីកហ្រ្វេដ ប្លុង កាន់ដំណែងជាសហចៅក្រមស៊ើបអង្កេតអន្តរជាតិ) ដោយផ្តល់ហេតុផលថា ការដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់បុគ្គលទាំងនោះ មិនបានធ្វើឲ្យមានការផ្លាស់ប្តូរកាលៈទេសៈ ហើយក៏ពុំបានបង្កឲ្យមានភាពអយុត្តិធម៌ចំពោះជនដែលមានឈ្មោះនៅក្នុងសំណុំរឿង០០៣ និង០០៤ដែរ ពីព្រោះ "ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទាំងពីរត្រូវបានច្រានចោល ហើយគ្មានអ្នកដាក់ពាក្យសុំណាម្នាក់ក្នុងចំណោមនេះ បានទទួលការអនុញ្ញាតចូលពិនិត្យមើលសំណុំរឿងឡើយ" ។[១០] គួរកត់សម្គាល់ថា នេះជាចំណុចមួយគួរឲ្យចាប់អារម្មណ៍ដែលថា តើសហចៅក្រមស៊ើបអង្កេតនឹងសម្រេចដូចម្តេច ប្រសិនបើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទាំងពីរ

នេះ (ឬពាក្យសុំតាំងខ្លួនជាដើមបណ្តឹងក្រោយៗទៀត) ត្រូវបានទទួលយក និងអនុញ្ញាតឲ្យចូលពិនិត្យមើលសំណុំរឿង ។[១១] ហាក់ដូចជាមានការអនុវត្តមិនស្មើសង្វាក់គ្នាក្នុងចំណោមសហចៅក្រមស៊ើបអង្កេត ។ ឧទាហរណ៍ជាក់ស្តែង បន្ទាប់ពីចៅក្រម ម៉ាក ហាម៉ុន ចូលកាន់ដំណែងជាសហចៅក្រមស៊ើបអង្កេតអន្តរជាតិ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួនត្រូវបានទទួលយក ហើយមេធាវីរបស់ដើមបណ្តឹងរដ្ឋប្បវេណី ត្រូវបានអនុញ្ញាតឲ្យចូលពិនិត្យមើលសំណុំរឿង ។[១២] ប៉ុន្តែ សំណើរបស់មេធាវីការពារក្តីសុំចូលពិនិត្យមើលសំណុំរឿង០០៤ (ដែលទំនងជាយោងទៅលើសេចក្តីសម្រេច ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១១ ខាងលើនេះ) នៅតែត្រូវបានបដិសេធចោលដដែល ។

នៅថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១២ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង ឡូរ៉ង់កាស្តេ អានសឺម៉េត (ដែលបានចូលបំពេញការងារបន្ទាប់ពីចៅក្រម ម៉ាសែល ឡឺម៉ុង និង ចៅក្រម ស៊ីកហ្វ្រេដ ប្លុង លាលែងជាបន្តបន្ទាប់ពីតួនាទីជាសហចៅក្រមស៊ើបអង្កេតអន្តរជាតិ) បានជូនដំណឹងទៅដល់ជនសង្ស័យម្នាក់នៅក្នុងសំណុំរឿង០០៤ (មិនបញ្ចេញឈ្មោះ) ថាគាត់មានសិទ្ធិមានមេធាវីការពារក្តី សិទ្ធិនៅស្ងៀមមិនឆ្លើយតបសំណួរ សិទ្ធិចាត់ទុកថាគ្មានទោសដរាបណាពិរុទ្ធភាពមិនទាន់ត្រូវបានរកឃើញ និងសិទ្ធិមានលទ្ធភាពទទួលបានឯកសារសំណុំរឿង (អនុវត្តស្រដៀងគ្នានឹងសិទ្ធិពិនិត្យមើលសំណុំរឿង) ។[១៣] ដោយតែសារមានភាពចម្រូងចម្រាស់គ្នាជាបន្តបន្ទាប់ជាមួយចៅក្រម យូ ប៊ុនឡេង (សហចៅក្រមស៊ើបអង្កេតជាតិ) នៅដើមខែឧសភា ឆ្នាំ២០១២ ចៅក្រម ឡូរ៉ង់កាស្តេ អានសឺម៉េត សម្រេចលាឈប់ពីការងារ ។[១៤] នៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១២ ចៅក្រម ម៉ាក ហាម៉ុន ត្រូវបានតែងតាំងជាសហចៅក្រមស៊ើបអង្កេតអន្តរជាតិ ដើម្បីស៊ើបសួរលើសំណុំរឿង០០៣ និង០០៤ ។

បន្ទាប់ពីចៅ ម៉ាក ហាម៉ុន ចូលកាន់ដំណែងជាសហចៅក្រមស៊ើបអង្កេតអន្តរជាតិ នៅថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១២ ក្រុមមេធាវីការពារក្តីក្នុងសំណុំរឿង០០៤ បានដាក់សំណើសុំជាថ្មីម្តងទៀតទៅសហចៅក្រមស៊ើបអង្កេត សុំការអនុញ្ញាតឲ្យចូលពិនិត្យមើលសំណុំរឿង (ហៅថាសំណើបន្ទាន់) ។ នៅក្នុងសំណើនេះ ក្រុមមេធាវីការពារក្តីបញ្ជាក់ថា ជនសង្ស័យដែលមានឈ្មោះនៅក្នុងសំណុំរឿង០០៤ (ដែលកំពុងស្ថិតនៅក្រោមការស៊ើបសួររបស់ចៅក្រមស៊ើបអង្កេត) ត្រូវបានចាត់ទុកថាជា«ជនត្រូវចោទ» ។[១៥] ដោយរង់ចាំអស់រយៈពេល២ខែ នៅតែពុំទាន់ទទួលបានការអនុញ្ញាតឲ្យចូលពិនិត្យមើលសំណុំរឿងនៅថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១៣ ក្រុមមេធាវីការពារក្តីបានប្តឹងឧទ្ធរណ៍ (បណ្តឹងឧទ្ធរណ៍ប្រឆាំងការបដិសេធតាមការសន្មត់លើ«សំណើបន្ទាន់»សុំចេញដីកាសម្រេចបើកមើលសំណុំរឿង) ទៅអង្គបុរេជំនុំជម្រះ ដោយបញ្ជាក់ថា «ការខកខានរបស់សហចៅក្រមស៊ើបអង្កេតមិនអនុញ្ញាតឲ្យជនត្រូវចោទបើកមើលសំណុំរឿង ទោះជាជនត្រូវចោទបានស្នើសុំដដែលៗយ៉ាងណាក៏ដោយ [...គឺ]បានបដិសេធគាត់មិនឲ្យមានសិទ្ធិដើរតួនាទីយ៉ាងសកម្មនៅក្នុងដំណាក់កាលស៊ើបសួរនៃកិច្ចដំណើរការនីតិវិធីនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ដូច្នេះ មិនឲ្យតម្លៃដល់សិទ្ធិដែលធានាដល់រូបគាត់ក្នុងនាមជាជនត្រូវចោទ» ។[១៦] ប៉ុន្តែបណ្តឹងឧទ្ធរណ៍នេះត្រូវបានក្រុមមេធាវីដកវិញបន្ទាប់ពីសហចៅក្រមស៊ើបអង្កេតអន្តរជាតិបញ្ជាក់ជូនអង្គបុរេជំនុំជម្រះថា គាត់«យល់ដឹងពីលក្ខខណ្ឌតម្រូវក្នុងការឆ្លើយតបទៅនឹងសំណើផ្សេងៗឲ្យបានឆាប់បំផុតតាមដែលអាចធ្វើទៅបាន ហើយនៅគ្រប់ករណីទាំងអស់ត្រូវចេញដីកានេះឲ្យបានមុនពេលបញ្ចប់កិច្ចស៊ើបសួរ ។ ប៉ុន្តែដំបូងត្រូវតែដោះស្រាយបញ្ហាបឋម និងសំខាន់ផ្សេងៗ ដែលជាលក្ខខណ្ឌចាំបាច់សម្រាប់ចេញសេចក្តីសម្រេចណាមួយទៅលើការអនុញ្ញាតឲ្យចូលពិនិត្យមើលសំណុំរឿង» ។[១៧] នៅថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៣ ក្រុមមេធាវីការពារក្តីបានដាក់លិខិតមួយទៀត ជូនទៅសហចៅក្រមស៊ើបអង្កេតអន្តរជាតិ ដោយផ្តល់ការបញ្ជាក់ថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ «បានអនុញ្ញាតមេធាវីដើមបណ្តឹងរដ្ឋប្បវេណីចូលពិនិត្យមើលសំណុំរឿង» ។ ដូច្នេះការមិនអនុញ្ញាតឲ្យជនសង្ស័យចូលពិនិត្យមើលសំណុំរឿងគឺ «មិនគ្រាន់តែខុសច្បាប់ប៉ុណ្ណោះទេ ប៉ុន្តែក៏បញ្ជូនសារសំខាន់ផងដែរ [...]អំពីឋានុក្រមរបស់ភាគី ក្នុងនោះ សិទ្ធិរបស់ជនសង្ស័យត្រូវបានចាត់ទុកថាតូចជាងសិទ្ធិរបស់សហព្រះរាជអាជ្ញា និងដើមបណ្តឹងរដ្ឋប្បវេណី» ។[១៨] សរុបសេចក្តីមក (យោងតាមសំណើបន្ទាន់របស់ក្រុមមេធាវីការ

ពារក្តី ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១២ និងលិខិតចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៣)

ក្នុងការស្នើសុំចូលពិនិត្យមើលសំណុំរឿង ក្រុមមេធាវីការពារក្តីបានលើកយកមូលដ្ឋានចំនួន២ មកធ្វើជាអំណះអំណាងគាំទ្រ គឺ ទី១) បុគ្គលដែលមានឈ្មោះនៅក្នុងសំណុំរឿង០០៤ ត្រូវបានចាត់ទុកថាជា«ជនត្រូវចោទ» (ដែលជាភាគីមួយក្នុងសំណុំរឿង) ។ ទី២) សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានអនុញ្ញាតឲ្យមេធាវីដើមបណ្តឹងរដ្ឋប្បវេណីចូលពិនិត្យមើលសំណុំរឿង ដែលករណីនេះ ក្រុមមេធាវីការពារក្តីត្រូវតែទទួលបានការអនុញ្ញាតដូចគ្នា ដើម្បីធានានូវសមភាពរវាងគូភាគីនៃរឿងក្តី ។

ជាលទ្ធផល សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ម៉ាក ហាម៉ុន នៅតែសម្រេចប្រានចោលចំពោះការលើកឡើងនូវអំណះអំណាងទាំងពីរខាងលើនេះ និងនៅតែបដិសេធមិនអនុញ្ញាតឲ្យក្រុមមេធាវីការពារក្តីចូលពិនិត្យមើលសំណុំរឿង០០៤ ។ ក្នុងការសម្រេចនេះ ចៅក្រម ហាម៉ុន បានធ្វើការបកស្រាយយ៉ាងម៉ឺងម៉ាត់ទៅលើការប្រើប្រាស់ពាក្យ «ជនសង្ស័យ» និង«ជនត្រូវចោទ» ដែលបានកំណត់ ដោយសន្ទានុក្រមនៃវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញ ។ នៅក្នុងសេចក្តីសម្រេចនេះ ចៅក្រម ហាម៉ុនបញ្ជាក់ថា *«ជនសង្ស័យ មិនមែនជាជនត្រូវចោទដូច្នេះហើយទើបមិនមែនជាភាគី[...]»* ។[19] ក្នុងន័យនេះ បុគ្គលទាំងឡាយដែលមានឈ្មោះនៅក្នុងសំណុំរឿង០០៤ នៅពុំទាន់ទទួលបានឋានៈជា«ជនត្រូវចោទ» នៅឡើយ ពោលគឺគ្រាន់តែជា«ជនសង្ស័យ» ហើយមេធាវីរបស់ជនទាំងនោះនឹងមិនទទួលបានការអនុញ្ញាតឲ្យចូលពិនិត្យមើលសំណុំរឿងឡើយ ។ យោងតាមសេចក្តីសម្រេចរបស់ចៅក្រម ហាម៉ុន បុគ្គលដែលមានឈ្មោះនៅក្នុងសំណុំរឿង០០៤ (ដែលត្រូវបានចៅក្រម ហាម៉ុន ហៅថាជា«ជនសង្ស័យ») នឹងទទួលបានឋានៈជា«ជនត្រូវចោទ» លុះត្រាតែ ៖ ទី១) ចាំបាច់ត្រូវមានតម្រុយច្បាស់លាស់ និងស៊ីសង្វាក់ ដែលបញ្ជាក់ថា ជននោះអាចទទួលខុសត្រូវចំពោះបទឧក្រិដ្ឋដែលបានចោទដោយព្រះរាជអាជ្ញានៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ។ ទី២) ជននោះ *«ត្រូវបានចោទដោយអនុវត្តតាមនីតិវិធីដូចមានចែងនៅក្នុងវិធាន៥៧ (វិធានស្តីពីការជូនដំណឹងអំពីបទចោទប្រកាន់)»* ។[20]

គួរបញ្ជាក់ថា លក្ខខណ្ឌទាំងនេះក៏ត្រូវបានចៅក្រម ម៉ាក ហាម៉ុន យកធ្វើជាមូលដ្ឋានក្នុងការលុបចោលនូវសេចក្តីសម្រេចរបស់ចៅក្រម ឡូរ៉ង់កាស្តេ អានសឺម៉េត ដែលបានអនុញ្ញាតឲ្យជនសង្ស័យម្នាក់ នៅក្នុងសំណុំរឿង០០៤ ចូលពិនិត្យមើលសំណុំរឿង ។ យោងតាមការលើកឡើងរបស់ចៅក្រម ម៉ាក ហាម៉ុន ការលុបចោលនេះគឺដោយសារចៅក្រម អានសឺម៉េត ពុំបានបំពេញតាមលក្ខខណ្ឌតម្រូវទាំងពីរខាងលើនេះ ហើយការដែលអនុញ្ញាតឲ្យជនសង្ស័យនោះចូលពិនិត្យមើលសំណុំរឿង គឺជាការរំលោភបំពានទៅលើវិធានផ្ទៃក្នុង ។[21]

ទាក់ទងនឹងការលើកឡើងរបស់ក្រុមមេធាវីការពារក្តី ដែលថា មេធាវីរបស់ដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានអនុញ្ញាតឲ្យចូលពិនិត្យមើលសំណុំរឿង ដូច្នេះខ្លួនគប្បីទទួលបានការអនុញ្ញាតឲ្យចូលពិនិត្យមើលសំណុំរឿងដែរនោះ ចៅក្រម ហាម៉ុន បានធ្វើការបំភ្លឺថា ដើមបណ្តឹងរដ្ឋប្បវេណីមានឋានៈជាភាគីមួយនៃរឿងក្តី ដូច្នេះមេធាវីរបស់គាត់មានសិទ្ធិចូលពិនិត្យមើល និងថតចម្លងសំណុំរឿង ។ ចំណែកជនសង្ស័យ នៅក្នុងសំណុំរឿង០០៤ គឺពុំមែនជាភាគីនៃរឿងក្តីឡើយ ។[22] មានន័យថា សិទ្ធិចូលពិនិត្យមើល និងថតចម្លងសំណុំរឿងគឺទុកសម្រាប់តែសហព្រះរាជអាជ្ញា និងមេធាវីរបស់ភាគីតែប៉ុណ្ណោះ ។

### ៣) គំនិតពិចារណា

នៅក្នុងកថាខណ្ឌ ៥៨ នៃសេចក្តីសម្រេចរបស់ចៅក្រម ម៉ាក ហាម៉ុន បានបញ្ជាក់យ៉ាងច្បាស់ថា *«សរុបមកក្នុងករណីដែលគ្មានការចោទប្រកាន់ជាផ្លូវការ ប្រឆាំងនឹងជនសង្ស័យ គឺគ្មានមូលហេតុណាដែលថា ចាំបាច់ត្រូវមានការចូលពិនិត្យមើលសំណុំរឿងដើម្បីការពារសិទ្ធិរបស់ជនសង្ស័យឡើយ»* ។ កថាខណ្ឌ៤១ នៃសេចក្តីសម្រេចដដែលនេះបានបញ្ជាក់ថា *«[...]ការចោទប្រកាន់ជាផ្លូវការអាចធ្វើឡើងតែក្នុងករណីដែលមានតម្រុយច្បាស់លាស់ និងស៊ីសង្វាក់ បញ្ជាក់ថា បុគ្គលនោះអាចជាអ្នកទទួលខុសត្រូវក្នុងការប្រព្រឹត្តបទឧក្រិដ្ឋដែលមានចែងក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ»* ។ វាពិតជាមានការលំបាកក្នុងការយល់នៅពេលដែលសហចៅក្រមស៊ើបអង្កេតប្រើពាក្យ*«ការចោទប្រកាន់ជាផ្លូវការ»* ក្នុងបរិបទសំណុំរឿង០០៣ និង០០៤ ដែលកំពុងស្ថិតនៅក្រោម

ការស៊ើបសួររហូតមកដល់ពេលបច្ចុប្បន្ននេះ ។ ដូចចៅក្រមស៊ើបអង្កេតបានបញ្ជាក់ខាងលើការចោទប្រកាន់ជាផ្លូវការ គឺតម្រូវឲ្យមានតម្រុយច្បាស់លាស់ និងស៊ីសង្វាក់ ដែលអាចបញ្ជាក់ថា ជននោះបានប្រព្រឹត្តបទឧក្រិដ្ឋដែលមានចែងក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ។ ដូច្នេះថាតើភាពមាន ឬគ្មាន“តម្រុយច្បាស់លាស់ និងស៊ីសង្វាក់”នៃភស្តុតាង ដែលត្រូវយកមកវាយតម្លៃក្នុង“ការចោទប្រកាន់ជាផ្លូវការ”លើសំណុំរឿង០០៣ និង០០៤ នឹងត្រូវបានបង្ហាញ ទ្រាប់ពីបិទបញ្ចប់ការស៊ើបសួរឬយ៉ាងណា? ប្រសិនបើដូច្នេះ មែន តើការចោទប្រកាន់ជាផ្លូវការនេះ ខុសគ្នាដូចម្តេច ជាមួយនឹងការចេញដីកាដំណោះស្រាយរបស់ចៅក្រមស៊ើបអង្កេត? វិធាន៦៧ នៃវិធានផ្ទៃក្នុងចែងថា “សហចៅក្រមស៊ើបអង្កេតត្រូវបញ្ចប់កិច្ចស៊ើបសួរ ដោយចេញដីកាដំណោះស្រាយថា ត្រូវចោទប្រកាន់ និងបញ្ជូនរឿងទៅជំនុំជម្រះ ឬលើកលែងការចោទប្រកាន់” ។ ក្នុងករណីនេះ ប្រសិនបើចៅក្រមស៊ើបអង្កេតសម្រេចចោទប្រកាន់ជនដែលមានឈ្មោះនៅក្នុងសំណុំរឿង០០៣ និង០០៤ និងបញ្ជូនរឿងទៅជំនុំជម្រះ ជនទាំងនោះនឹងត្រូវបានផ្តល់ឋានៈជា“ជនជាប់ចោទ” គឺពុំមែនជា“ជនត្រូវចោទ” នោះទេ ។ ដូច្នេះ សហចៅក្រមស៊ើបអង្កេតអាចនឹងវង្វេងការចោទប្រកាន់ថា បានធ្វើឲ្យជនសង្ស័យនៅក្នុងសំណុំរឿងទាំងពីរនេះ ថ្ងៃរះសិទ្ធិ ក្នុងការទទួលបានឋានៈជា“ជនត្រូវចោទ” ។ នៅក្នុងដំណើរការស៊ើបសួរ វិធានផ្ទៃក្នុងបានផ្តល់សិទ្ធិសំខាន់ៗមួយចំនួនជូនជនត្រូវចោទ ដូចជា សិទ្ធិសុំឲ្យសហចៅក្រមស៊ើបអង្កេតចេញដីកា ឬបំពេញកិច្ចស៊ើបសួរណាមួយដែលខ្លួន យល់ថាមានផលប្រយោជន៍ដល់ការស៊ើបសួរ ។[២៣] សិទ្ធិសុំឲ្យចៅក្រមស៊ើបអង្កេតស្តាប់ចម្លើយរបស់ខ្លួន ស្តាប់ចម្លើយសាក្សី ចុះទៅដល់ទីកន្លែងកើតហេតុ បន្ទាប់ឲ្យធ្វើកោសល្យវិច័យប្រមូលយកភស្តុតាង ។[២៤] សិទ្ធិតទល់ជាមួយដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សី ដែលចៅក្រមស៊ើបអង្កេតសួរយកចម្លើយ[២៥] និងសិទ្ធិចូលពិនិត្យមើល និងថតចម្លងសំណុំរឿង (តាមរយៈមេធាវីរបស់ខ្លួន) ជាដើម ។ តើសហចៅក្រមស៊ើបអង្កេតពិតជាអាចធានាផ្តល់សិទ្ធិទាំងនេះបានដែរ ឬទេ សម្រាប់ជនសង្ស័យនៅក្នុងសំណុំរឿង០០៣ និង០០៤ ក្រោយពេលជនទាំងនោះត្រូវបានចោទប្រកាន់ជាផ្លូវការ? ក្នុងករណីសិទ្ធិទាំងនេះ ត្រូវបានធានាផ្តល់ជូន តើការស៊ើបអង្កេតទៅលើសំណុំរឿងទាំងពីរនេះ អាចនឹងត្រូវបានបិទបញ្ចប់នៅពេល



ខៀវ សំផន (រូបទីបួនរាប់ពីឆ្វេង) នាំគណប្រតិភូមន្ត្រីដឹកនាំដោយព្រះអង្គម្ចាស់ សុផានុវង្ស (រូបទីបីពីឆ្វេង) ទស្សនកិច្ចអាងក្រពើនៅខេត្តសៀមរាបក្នុងឆ្នាំ១៩៧៨ ។ (រូបថតមជ្ឈមណ្ឌលឯកសារកម្ពុជា)

ណា? គួររំពឹកថា សំណុំរឿង០០៣ និង០០៤ ត្រូវបានសហព្រះរាជអាជ្ញាបញ្ជូនឲ្យសហចៅក្រម ស៊ើបអង្កេតបើកការស៊ើបសួរ តាំងពីថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០០៩មកម្ល៉េះ ។ បានន័យថា រហូតមកដល់ពេលនេះ សំណុំរឿងទាំងពីរនេះស្ថិតនៅក្នុងដៃរបស់សហចៅក្រមស៊ើបអង្កេតអស់រយៈពេលជាង៤ឆ្នាំមកហើយ ។

- វិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា វិសោធនកម្មលើកទី៨ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០១១ ហៅកាត់ថា«វិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញ» ។

  http://www.eccc.gov.kh/document/legal/15232
- សេចក្ដីសម្រេចលើសំណើរបស់ក្រុមមេធាវីការពារក្ដី [កោសលុប] សុំចូលពិនិត្យមើលសំណុំរឿង និងចូលរួមការស៊ើបអង្កេត ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៣ ឯកសារលេខ D121/4 កថាខណ្ឌ៣៧ ។

  http://www.eccc.gov.kh/document/court/27594
- វិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញ ទំព័រ១៣៣-១៣៧
- កថាខណ្ឌ៨ នៃឯកសារលេខ D121/4
- កថាខណ្ឌ៩ នៃឯកសារលេខ D121/4
- កថាខណ្ឌ១១ នៃឯកសារលេខ D121/4
- វិធាន៥៧ ស្ដីពីការជូនដំណឹងអំពីបទចោទប្រកាន់ ចែងថា «នៅពេលជនត្រូវចោទចូលបង្ហាញខ្លួនចំពោះមុខសហចៅក្រមស៊ើបអង្កេតជាលើកដំបូង សហចៅក្រមស៊ើបអង្កេត ត្រូវកត់ត្រានូវអត្តសញ្ញាណរបស់ជននោះ និងប្រាប់ជននោះអំពីបទចោទប្រកាន់ និងសិទ្ធិមានមេធាវី និងសិទ្ធិក្នុងការនៅស្ងៀមមិនឆ្លើយសំណួរ ។ ជនត្រូវចោទមានសិទ្ធិពិគ្រោះជាមួយមេធាវីមុនពេលដែលខ្លួនត្រូវបានសួរចម្លើយ និងមានមេធាវីអមជាមួយនៅក្នុងពេលសួរចម្លើយ[...]» ។
- កថាខណ្ឌ១២ នៃឯកសារលេខ D121/4
- ចៅក្រមមានអំណាច (អំណាចជាប់មកជាមួយ) ក្នុងការពិចារណាឡើងវិញលើសេចក្ដីសម្រេចមុនណាមួយ ក្នុងករណីដែលមានការផ្លាស់ប្ដូរកាលៈទេសៈ និងក្នុងករណីដែលសេចក្ដីសម្រេចមុននោះមានការភាន់ច្រឡំ ឬបណ្ដាលឲ្យមានភាពអយុត្តិធម៌ (ឯកសារលេខ D121/4 ទំព័រ១៨) ។
- កថាខណ្ឌ១៥ នៃឯកសារលេខ D121/4
- បញ្ជាក់ ៖ សេចក្ដីសម្រេចចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១១ នេះ មិនអាចរកបាននៅក្នុងគេហទំព័ររបស់អង្គជំនុំជម្រះវិសាមញ្ញឡើយ (ឯកសារលេខ D4/2/1) ។
- កថាខណ្ឌ២៨ នៃឯកសារលេខ D121/4
- កថាខណ្ឌ១៧ នៃឯកសារលេខ D121/4
- សេចក្ដីប្រកាសព័ត៌មានរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង ចេញផ្សាយថ្ងៃទី៤ ខែឧសភា ឆ្នាំ២០១២ ។

  http://www.eccc.gov.kh/articles/19368
- កថាខណ្ឌ២២ នៃឯកសារលេខ D121/4
- កថាខណ្ឌ២៤ នៃឯកសារលេខ D121/4
- កថាខណ្ឌ២៧ និង២៥ នៃឯកសារលេខ D121/4
- កថាខណ្ឌ២៨ និង៣៥ នៃឯកសារលេខ D121/4
- កថាខណ្ឌ៦២ នៃឯកសារលេខ D121/4
- កថាខណ្ឌ៣៩-៤៤ នៃឯកសារលេខ D121/4
- កថាខណ្ឌ៤៥-៤៩ នៃឯកសារលេខ D121/4
- កថាខណ្ឌ៦០ នៃឯកសារលេខ D121/4 affect
- វិធាន៥៥(១០) នៃវិធានផ្ទៃក្នុង
- វិធាន៥៨(៦) នៃវិធានផ្ទៃក្នុង
- វិធាន៥៩, ៦០ នៃវិធានផ្ទៃក្នុង

***សម្គាល់ ៖*** រាល់ខ្លឹមសារ និងការបកស្រាយទាំងអស់នៅក្នុងអត្ថបទនេះ គឺជាការយល់ឃើញរបស់ខ្ញុំផ្ទាល់ ពោលគឺពុំបានបង្ហាញជំហរ ឬទស្សនៈណាមួយរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាឡើយ ។

## ពន្យល់ពាក្យសំខាន់ៗ

**១**-ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ៖ សំដៅទៅលើដីកាជាលាយលក្ខណ៍អក្សរ ដែលចេញដោយសហព្រះរាជអាជ្ញា ស្នើសុំឲ្យសហចៅក្រមស៊ើបអង្កេតបើកការស៊ើបសួរ ចំពោះករណីបទល្មើសណាមួយ និងធ្វើការចោទប្រកាន់ ។

**២**-ដីកាសន្និដ្ឋានស្ថាពរ ៖ សំដៅទៅលើដីកាជាលាយលក្ខណ៍អក្សរ ដែលចេញដោយសហព្រះរាជអាជ្ញាស្នើសុំទៅសហចៅក្រមស៊ើបអង្កេតឲ្យធ្វើដីកាដំណោះស្រាយចំពោះសំណុំរឿងណាមួយ ។

**៣**-ដីកាដំណោះស្រាយ ៖ សំដៅទៅលើដីកាចុងក្រោយ ដែលធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេត ឬអង្គបុរេជំនុំជម្រះ នៅពេលបញ្ចប់ការស៊ើបសួរដែលអាចជាដីកាបញ្ជូនរឿងទៅជំនុំជម្រះ ឬដីកាលើកលែងការចោទប្រកាន់ ។


# មជ្ឈមណ្ឌលឯកសារកម្ពុជា

ប្រអប់សំបុត្រលេខ១១១០, ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទ ៖ (៨៥៥) ២៣ ២១១ ៨៧៥

ទូរសារ ៖ (៨៥៥) ២៣ ២១០ ៣៥៨

អ៊ីម៉ែល ៖ *dccam@online.com.kh*

គេហទំព័រ ៖ *www.dccam.org* ឬ *www.cambodiatribunal.org*

គម្រោងនេះទទួលជំនួយហិរញ្ញវត្ថុពីមូលនិធិ

*Bereau of Democracy, Human Rights, and Labor,*

*U.S. Department of State*


| ល.រ | ឈ្មោះដើម | ឈ្មោះបដិវត្ត | លេខសម្ងាត់ | ប្រភពឯកសារ |
|---|---|---|---|---|
| ១ | សាឡុត ស | ប៉ុល ពត, បងប៉ុល, បងទី១, | ៨៧០, ៨៧ | D427, E1/56.1 |
| ២ | នួន រិទ្ធ | នួន ជា, បងនួន, បងទី២ | (អត់ដឹង) | D427 |
| ៣ | គីម ត្រាង | អៀង សារី, វ៉ាន់ | (អត់ដឹង) | D427, E1/21.1 |
| ៤ | ខៀវ សំផន | ហែម, ខាង, ណន | (អត់ដឹង) | D427 |
| ៥ | សុន សេន | ខៀវ, ឃឹម | ៨៩, ៦២ | E1/54.1 |



**ឌី សុជាតា**

បរិញ្ញាបត្រច្បាប់ សិក្សាជាភាសាអង់គ្លេស ពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ។



**លឹម ជ័យទ័ត្ត**

បរិញ្ញាបត្រច្បាប់ និងបរិញ្ញាបត្រសេដ្ឋកិច្ចពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យា-សាស្ត្រសេដ្ឋកិច្ច និងជាជ័យលាភីថ្នាក់ជាតិ ទទួលបានពានរង្វាន់មេដាយមាសក្នុងការប្រកួតសវនាការប្រឌិត ឆ្នាំ២០១០ ។



**ទូន ឡៃហុល**

បរិញ្ញាបត្រច្បាប់ពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ។



**ចាន ប្រាថ្នា**

បរិញ្ញាបត្រច្បាប់ពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ។



(រូបថតមជ្ឈមណ្ឌលឯកសារកម្ពុជា)